**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ**

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្ម ខេត្តតាកែវ ២០១៩-២០២៣

ខែ កញ្ញា ឆ្នាំ ២០២០

អាស័យដ្ឋាន÷ ភូមិស្នោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ
ទូរស័ព្ទលេខ÷ ០៣២ ៩៣១ ២៣៨, Fax ០៣២ ៩៣១ ១៥៦

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាដើម្បីជម្រុញការអនុវត្ត "យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣" និងសម្រេចបាននូវសមិទ្ធផលគួរជាទីមោទនភាពនាពេលកន្លងមក។ ក្នុងអាណត្តិទី០៦ នេះរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ "យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤" បានចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ដោយបានកំណត់យ៉ាងច្បាស់ថា វិស័យកសិកម្មនៅតែមានតួនាទីសំខាន់ ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចធានាសមធមិ ធានាសន្តិសុខស្បៀង និងជម្រុញការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា ឱ្យមានលក្ខណៈប្រកួតប្រជែង បរិយាប័ន ធន់នឹងបម្រែបម្រួលអាកាសធាតុ និងនិរន្តរភាព បង្កើនប្រាក់ចំណូលដល់គ្រួសារកសិករ វិបុលភាព និង សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមអភិក្រម និង វិសាលភាពថ្មីដើម្បីប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍន៍តាមបែបវិបុលវប្បកម្ម ពោលគឺពឹងផ្អែកសំខាន់លើធនធានដែលមានស្រាប់ (ធនធានដី និងធនធានធម្មជាតិផ្សេងៗទៀត) ឈានទៅរកដំណាក់កាលថ្មី ដែលផ្តោតទៅលើប្រពលវប្បកម្ម ពោលគឺពឹងសំខាន់លើការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាថ្មី កសិកម្មឆ្លាតវៃ ការស្រាវជ្រាវ និងការអភិវឌ្ឍយន្តូបនីយកម្ម ព្រមទាំងការបង្កើនសមត្ថភាពស្រោចស្រព លើកកម្ពស់ផលិតភាពពិពិធកម្មដំណាំដែលមានសក្តានុពល និងទីផ្សាររួមទាំងការចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្ម។

ដើម្បីសម្រេចបាននូវទិសដៅអភិវឌ្ឍន៍វិស័យកសិកម្មក្នុងអាណត្តិទី ៦ របស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានកំណត់ទិសដៅគោលនយោបាយជាយុទ្ធសាស្ត្រគឺ បន្តជម្រុញកំណើនក្នុងវិស័យកសិកម្មប្រកបដោយការប្រកួតប្រជែងផលិតផលមានគុណភាព សុវត្ថិភាពនិង អាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព។

ដើម្បីចូលរួមចំណែកអនុវត្ត និងសម្រេចបាន នូវទិសដៅគោលនយោបាយដែលបានបានកំណត់នេះមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត បានរៀបចំកសាងនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្ត (២០១៩-២០២៣) ដោយមានសង្គតិភាពទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២១៩-២០២៣) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០១៩-២០២៣) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងឯកសារពាក់ព័ន្ធផ្សេងៗ ហើយដែលត្រូវបានចាត់ទុកជាឯកសារផែនការយុទ្ធសាស្ត្រដ៏សំខាន់មួយក្នុងការកំណត់ និងតម្រង់ទិសដៅសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលមធ្យម។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្តរយៈពេល ០៥ឆ្នាំនេះ ត្រូវបានរៀបចំឡើងដោយមានការចូលរួមពិគ្រោះយោបល់ពីការិយាល័យក្រោមឱវាទមន្ទីរ ទីប្រឹក្សារបស់ក្រុមហ៊ុន Young Development មន្ទីរពាក់ព័ន្ធនានា ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និង តំណាងវិស័យឯកជន។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្តរយៈពេល ០៥ឆ្នាំនេះគឺជាបណ្តុំនូវគម្រោងអាទិភាពដែលបានមកពីការវាយតម្លៃ ការប្រមូល និងវិភាគពត៌មាន វិភាគស្ថានភាព និងបញ្ហាប្រឈម របស់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត ដើម្បីកំណត់ឬសគល់បញ្ហា លើកនូវដំណោះស្រាយ ស្វែងរកការគាំទ្រពីបណ្តាប្រភពជំនួយនានា និងជាការបង្ហាញនូវតម្រូវការជាអាទិភាពរបស់ប្រជាជននៅក្នុងខេត្តនៃកិច្ចដំណើរការអភិវឌ្ឍន៍មូលដ្ឋាននៅបណ្តាឆ្នាំខាងមុខ។

សកម្មភាពដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្តរយៈពេល ០៥ឆ្នាំ (២០១៩-២០២៣) បានឆ្លុះបញ្ចាំងនូវតំរូវការធនធានដែលអាចធ្វើឱ្យគម្រោងទាំងឡាយ ដំណើរការអនុវត្តនៅក្នុងមូលដ្ឋានសម្រាប់ដោះស្រាយនូវរាល់

បញ្ហាជាអាទិភាពបន្ទាន់ដែលសំខាន់បំផុតសម្រាប់អ្នកទទួលផល គឺសហគមន៍មូលដ្ឋានក្នុងខេត្តនៅពេលគម្រោងទាំងឡាយដែលបានលើកឡើងនេះទទួលបានការគាំទ្រ និងការអនុវត្ត។

តាងនាមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានផែនការ-ស្ថិតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គម្រោង ASPIRE បណ្តាមន្ទីរជុំវិញខេត្ត ស្រុក ក្រុង អង្គការជាតិ អន្តរជាតិទាំងអស់ ក្រុមហ៊ុន young Development ដែលបានគាំទ្រ និងសហការគ្នាក្នុងការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មខេត្ត (២០១៩-២០២៣) ទទួលបានលទ្ធផលល្អប្រសើរ។សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍នានាដែលបានខិតខំប្រឹងប្រែងក្នុងការជួយគាំទ្រគម្រោងសកម្មភាពដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មក្នុងខេត្តនាពេលកន្លងមកដែលធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាកសិករ ត្រូវបានកែលម្អគួរជាទីមោទន ហើយសូមអំពាវនាវដល់គ្រប់តួអង្គអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់ រួមមានស្ថាប័នរបស់រដ្ឋ អង្គការជាតិ អន្តរជាតិ សមាគម សហគមន៍ អ្នកផ្តល់ជំនួយ សង្គមស៊ីវិលនានា ព្រមទាំងវិស័យឯកជន ជាពិសេសថ្នាក់ដឹកនាំមន្ត្រីរាជការគ្រប់ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋគ្រប់រូប សូមផ្តល់ការគាំទ្រ និងកិច្ចខិតខំបន្ថែមទៀត ដើម្បីសម្រេចឲ្យបាននូវគោលដៅទាំងឡាយដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្រ្ត អភិវឌ្ឍន៍វិស័យកសិកម្មខេត្ត រយៈពេល ០៥ឆ្នាំ (២០១៩-២០២៣)របស់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ។

ថ្ងៃ.........................ខែ...................ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅតាកែវ, ថ្ងៃទី.........ខែ...........ឆ្នាំ ២០....

**ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ**

## មាតិកា


អារម្ភកថា ........................................ 2

មាតិកា ........................................ 4

សេចក្តីផ្តើម ........................................ 10

ផ្នែកទី១ ........................................ 12

សមិទ្ធផលដែលសម្រេចបាន និងបញ្ហាប្រឈមនានាក្នុងការងារកសិកម្មខេត្ត ........................................ 12

១.១ ស្ថានភាពទូទៅ ........................................ 12

១.២ សមិទ្ធផលដែលសម្រេចបាន និងបញ្ហាប្រឈមក្នុងការងារកសិកម្ម ........................................ 15

១.២.១ ផលិតកម្មដំណាំស្រូវ ........................................ 15

ក. ការពណ៌នា ........................................ 15

ខ. ការវិភាគស្វត ........................................ 15

គ. តារាងស្ថិតិដំណាំស្រូវ ........................................ 16

១.២.២ ផលិតកម្មដំណាំរួមផ្សំ ........................................ 18

ក. ការពណ៌នា ........................................ 18

ខ. ការវិភាគស្វត ........................................ 18

គ. តារាងស្ថិតិដំណាំរួមផ្សំក្នុងខេត្តតាកែវ ........................................ 18

១.២.៣ ផលិតកម្មដំណាំបន្លែ ........................................ 20

ក. ការពណ៌នា ........................................ 20

ខ. ការវិភាគស្វត ........................................ 20

គ. តារាងស្ថិតិដំណាំបន្លែ ........................................ 21

១.២.៤ ផលិតកម្មដំណាំកសិឧស្សាកម្ម ........................................ 21

ក. ការពណ៌នា ........................................ 21

ខ. ការវិភាគស្វត ........................................ 22

គ. តារាងស្ថិតិដំណាំកសិឧស្សាហកម្ម ........................................ 22

១.២.៥ ផលិតកម្មសត្វ និងបសុព្យាបាល ........................................ 24

ក. ការពណ៌នា ........................................ 24

ខ. ការវិភាគស្វត ........................................ 24

គ. តារាងស្ថិតិផលិតកម្មសត្វក្នុងខេត្តតាកែវ ........................................ 25

១.២.៦ ផ្នែកផ្សព្វផ្សាយកសិកម្ម ........................................ 27

ក. ការពណ៌នា ........................................ 27

ខ. ការវិភាគស្វត ........................................ 27

១.២.៧ ការងារសហគមន៍កសិកម្ម ........................................ 28

ក. ការពណ៌នា ........ 28
ខ. ការវិភាគស្វ័ត ........ 29
គ. តារាងស្ថិតិសហគមន៍កសិកម្មក្នុងខេត្តតាកែវ (២០១៤-២០១៨) ........ 30
១.២.៨ ផ្នែកគ្រឿងយន្តកសិកម្ម ........ 30
ក. ការពណ៌នា ........ 30
ខ. ការវិភាគស្វ័ត ........ 31
គ. តារាងស្ថិតិគ្រឿងយន្តកសិកម្មក្នុងខេត្តតាកែវ ........ 32
១.២.៩ ផ្នែកខណ្ឌរដ្ឋបាលជលផល ........ 32
ក. ការពណ៌នា ........ 32
ខ. ការវិភាគស្វ័ត ........ 33
គ. តារាងស្ថិតិជលផលក្នុងខេត្តតាកែវ ........ 34
១.២.១០ ផ្នែកខ័ណ្ឌរដ្ឋបាលព្រៃឈើ ........ 35
ក. ការពណ៌នា ........ 35
ខ. ការវិភាគស្វ័ត ........ 36
គ. តារាងស្ថិតិការងារព្រៃឈើក្នុងខេត្តតាកែវ ........ 37
១.២.១១ ផ្នែកនីតិកម្មកសិកម្ម និងការគ្រប់គ្រងសម្ភារៈកសិកម្ម ........ 38
ក. ការពណ៌នា ........ 38
ខ. ការវិភាគស្វ័ត ........ 39
គ. តារាងស្ថិតិការងារនីតិកម្មកសិកម្មក្នុងខេត្តតាកែវ ........ 39
១.២.១២ ការងារផែនការ-គណនេយ្យ ........ 40
ក. ការពណ៌នា ........ 40
ខ. ការវិភាគស្វ័ត ........ 41
គ. តារាងស្ថិតិការងារគណនេយ្យ ........ 41
១.២.១៣ ការងាររដ្ឋបាល និងការគ្រប់គ្រងធនធានមនុស្ស ........ 42
ក. ការពណ៌នា ........ 42
ខ. ការវិភាគស្វ័ត ........ 43
គ. តារាងស្ថិតិមន្ត្រីរាជការរបស់មន្ទីរ ........ 43
១.២.១៤ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ........ 44
**១.៣ ការងារយេនឌ័រ និងកិច្ចការពារកុមារក្នុងវិស័យកសិកម្ម** ........ 44
១.៣.១ ការងារយេនឌ័រក្នុងវិស័យកសិកម្ម ........ 44
១.៣.២ ការការពារកុមារក្នុងវិស័យកសិកម្ម ........ 45
១.៣.៣ សកម្មភាព ........ 45
**១.៤ ការប្រែប្រួលអាកាសធាតុ** ........ 46
១.៤.១ ផលប៉ះពាល់នៃគ្រោះមហន្តរាយ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ........ 46
១.៤.២ សកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ........ 47

**១.៥ ភាពអំណោយផល និងបញ្ហាប្រឈម** ........ 48
១.៥.១ ភាពអំណោយផល ........ 48
១.៥.២ បញ្ហាប្រឈម ........ 48
**១.៦ ការវាយតម្លៃលទ្ធផល និងសេចក្តីសន្និដ្ឋាន** ........ 49
**ផ្នែកទី២** ........ 51
**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មខេត្តតាកែវ ឆ្នាំ២០១៩-២០២៣** ........ 51
**២.១ សេចក្តីផ្តើម** ........ 51
**២.២ ចក្ខុវិស័យ** ........ 52
**២.៣ បេសកកម្ម** ........ 52
**២.៤ គោលដៅយុទ្ធសាស្ត្រ** ........ 52
**២.៥ គាំទ្រយុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្មក្រសួង** ........ 52
២.៥.១ កម្មវិធីទី១÷ បង្កើនផលិតភាពពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច ........ 53
២.៥.១.១ អនុកម្មវិធីទី១.៩ ÷ ការជម្រុញផលិតកម្មដំណាំកសិកម្ម និងកសិធុរកិច្ច ........ 53
ក. គោលបំណង÷ ........ 53
ខ. សូចនាករ ........ 53
គ. ចង្កោមសកម្មភាពទី១÷ ១.៩.១.២១ កាលើកកម្ពស់ខ្សែច្រវាក់តម្លៃដំណាំកសិកម្ម ........ 53
ឃ. សកម្មភាព ........ 53
២.៥.២ កម្មវិធីទី២÷ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ ........ 54
២.៥.២.១ អនុកម្មវិធីទី២.៤ ÷ ការជម្រុញផលិតកម្មសត្វ និងសុខភាពសត្វ ........ 54
ក. គោលបំណង÷ ........ 54
ខ. សូចនាករ ........ 55
គ. ចង្កោមសកម្មភាពទី១ ÷ ២.៤.១.២១ ការជម្រុញការចិញ្ចឹមសត្វលើកកម្ពស់សុខភាពសត្វ និង សុខភាពសាធារណៈបសុព្យាបាល ........ 55
ឃ. សកម្មភាព ........ 55
២.៥.៣ កម្មវិធីទី៣÷ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម ........ 56
២.៥.៣.១ អនុកម្មវិធីទី៣.៤÷ ការពង្រឹងការគ្រប់គ្រងធនធានជលផល និងការជម្រុញវារីវប្បកម្ម ........ 56
ក. គោលបំណង÷ ........ 56
ខ. សូចនាករ ........ 56
គ. ចង្កោមសកម្មភាព១ ÷ ៣.៤.១.២១ ÷ ការការពារធនធានជលផល និងការអភិវឌ្ឍខ្សែច្រវាក់តម្លៃផលជលផល ........ 56
ឃ. សកម្មភាព ........ 56
២.៥.៤ កម្មវិធីទី៤÷ ការគ្រប់គ្រង និងអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ ........ 57
២.៥.៤.១ អនុកម្មវិធីទី៤.៤ ÷ ការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ ........ 57
ក. គោលបំណង÷ ........ 57

ខ. សូចនាករ ........ 58
គ. ចង្កោមសកម្មភាព១÷ ៤.៤.១.២១÷ ការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធាន ព្រៃឈើ និងសត្វព្រៃ ........ 58
ឃ. សកម្មភាព ........ 58
កម្មវិធីទី ៥÷ ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ........ 59
២.៥.៥. អនុកម្មវិធីទី៥.១៤ ÷ ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស ........ 59
ក. គោលបំណង÷ ........ 59
ខ. សូចនាករ ........ 59
គ. ចង្កោមសកម្មភាព១÷ ៥.១៤.១.២១ ÷ ការបង្កើនគុណភាពសេវាគាំទ្រ និងការអភិវឌ្ឍន៍ធនធានមនុស្ស ........ 59
ឃ. សកម្មភាព ........ 59
**២.៦ បញ្ហាដែលមានលក្ខណៈ ប្រទាក់ក្រឡាគ្នា** ........ 62
២.៦.១ ការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ........ 62
ក. សូចនាករ ........ 62
ខ. សកម្មភាព ........ 62
២.៦.២ ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ........ 62
ក. សកម្មភាព ........ 63
២.៦.៣ កិច្ចសហប្រតិបត្តិការអន្តរវិស័យ ........ 63
**២.៧ ផែនការថវិកា** ........ 64
**២.៨ ការត្រួតពិនិត្យ និងវាយតម្លៃ** ........ 65
**២.៩ សេចក្តីសន្និដ្ឋាន** ........ 66
**ឧបសម្ព័ន្ធ** ........ 67
**ឧបសម្ព័ន្ធ ១÷ គោលការណ៍បច្ចេកទេសក្នុងការរៀបចំផែនការអភិវឌ្ឍន៍កសិកម្មខេត្ត** ........ 67
**ឧបសម្ព័ន្ធ ២÷ ក្រុមការងាររៀបចំផែនការថ្នាក់ខេត្ត** ........ 69
**ឧបសម្ព័ន្ធ៣÷ អង្គការលេខថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត** .. 71

**បញ្ជីតារាង**

តារាងទី 1 ÷ បង្ហាញពីផលិតកម្មស្រូវក្នុងខេត្ត ឆ្នាំ២០១៤-២០១៨ ........ 16
តារាងទី 2 ÷ ផលិតកម្មស្រូវតាមរដូវ ........ 17
តារាងទី 3 ÷ ផ្ទៃដីដំណាំរួមផ្សំរបស់ខេត្តតាកែវ (ឆ្នាំ២០១៤-២០១៨) ........ 18
តារាងទី 4 ÷ ផ្ទៃដីដាំដុះដំណាំបន្លែរបស់ខេត្ត (២០១៤-២០១៨) ........ 21
តារាងទី 5 ÷ ផ្ទៃដីដាំដុះដំណាំឧស្សាហកម្ម (ឆ្នាំ២០១៤-២០១៨) ........ 22
តារាងទី 6 ÷ ទិន្នផលដំណាំឧស្សាហកម្ម (ឆ្នាំ២០១៤-២០១៨) ........ 23
តារាងទី 7 ÷ ផលិតកម្មសត្វក្នុងខេត្តតាកែវ (ឆ្នាំ២០១៤-២០១៨) ........ 25
តារាងទី 8 ÷ ការងារបង្កើតសហគមន៍កសិកម្មក្នុងខេត្តតាកែវ (ឆ្នាំ២០១៤-២០១៨) ........ 30

តារាងទី 9÷ ការប្រើប្រាស់គ្រឿងយន្តកសិកម្ម (ឆ្នាំ២០១៤-២០១៨) 32
តារាងទី 10÷ តារាងស្ថិតិការងារជលផលក្នុងខេត្តតាកែវ (ឆ្នាំ២០១៤-២០១៨) 34
តារាងទី 11÷ តារាងស្ថិតិការងារព្រៃឈើខេត្តតាកែវ (ឆ្នាំ២០១៤-២០១៨) 37
តារាងទី 12÷ តារាងស្ថិតិការងារនីតិកម្មកសិកម្មខេត្តតាកែវ (ឆ្នាំ២០១៤-២០១៨) 39
តារាងទី 13÷ ការប្រមូលចំណូល (ឆ្នាំ២០១៤-២០១៨) 41
តារាងទី 14÷ ចំនួនមន្ត្រីមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (ឆ្នាំ២០១៤-២០១៨) 43
តារាងទី 15÷ ផ្ទៃដីខូចខាត និងផ្ទៃដីស្តារឡើងវិញ 46
តារាងទី 16÷ សូចនាករ នៃអនុកម្មវិធីទី១ថ្នាក់ខេត្ត 53
តារាងទី 17÷ សូចនាករចង្កោមសកម្មភាពនៃអនុកម្មវិធីទី១ 53
តារាងទី 18÷ សូចនាករអនុកម្មវិធីទី២ (ថ្នាក់ខេត្ត) 55
តារាងទី 19÷សូចនាករចង្កោមសកម្មភាពនៃអនុកម្មវិធីទី២ 55
តារាងទី 20÷ សូចនាករអនុកម្មវិធីទី៣ (ថ្នាក់ខេត្ត) 56
តារាងទី 21÷សូចនាករចង្កោមសកម្មភាពនៃអនុកម្មវិធីទី៣ 56
តារាងទី 22÷ សូចនាករអនុកម្មវិធីទី៤ (ថ្នាក់ខេត្ត) 58
តារាងទី 23÷សូចនាករចង្កោមសកម្មភាពនៃអនុកម្មវិធីទី៤ 58
តារាងទី 24÷ សូចនាករអនុកម្មវិធីទី៥ (ថ្នាក់ខេត្ត) 59
តារាងទី 25÷ សូចនាករចង្កោមសកម្មភាពនៃអនុកម្មវិធីទី៥ 59
តារាងទី 26÷ ការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម 62
តារាងទី 27÷ តម្រូវការថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មថ្នាក់ខេត្ត ឆ្នាំ២០១៩-២០២៣ 64
តារាងទី 28÷ ការប៉ាន់ប្រមាណធនធានសរុបដែលមានសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មថ្នាក់ខេត្ត 64

## បញ្ជីក្រាហ្វិក

ក្រាហ្វិក 1÷ បរិមាណទឹកភ្លៀងក្នុងខេត្ត ចាប់ពីឆ្នាំ២០១៥-២០១៩ 14
ក្រាហ្វិក 2. ការវិវឌ្ឍន៍នៃកម្ពស់ទឹកទន្លេ 14
ក្រាហ្វិក 3. ការវិវឌ្ឍន៍ផ្ទៃដីដាំដុះដំណាំស្រូវ 17
ក្រាហ្វិក 4. ការវិវឌ្ឍន៍ផ្ទៃដីដំណាំរួមផ្សំ (៣ប្រភេទ) 19
ក្រាហ្វិក 5. ការវិវឌ្ឍន៍ផ្ទៃដីដំណាំរួមផ្សំ (៤ប្រភេទ) 20
ក្រាហ្វិក 6. ការវិវឌ្ឍន៍ផ្ទៃដីដាំដុះដំណាំបន្លែគ្រប់មុខ 21
ក្រាហ្វិក 7. ការវិវឌ្ឍន៍ផ្ទៃដីដាំដុះដំណាំកសិ-ឧស្សាហកម្ម 23
ក្រាហ្វិក 8. ការវិវឌ្ឍន៍ទិន្នផលតាមប្រភេទដំណាំកសិ-ឧស្សាហកម្ម 24
ក្រាហ្វិក 9. ការវិវឌ្ឍន៍ផលិតកម្មសត្វគោ ក្របី និងជ្រូក 25
ក្រាហ្វិក 10. ការវិវឌ្ឍន៍ផលិតកម្មសត្វមាន់-ទា 26
ក្រាហ្វិក 11. ការវិវឌ្ឍន៍នៃការបង្កើតសហគមន៍កសិកម្ម 30

ក្រាហ្វិក 12. ការវិវឌ្ឍន៍នៃគ្រឿងយន្តកសិកម្ម ................................ 32
ក្រាហ្វិក 13. ការវិវឌ្ឍន៍នៃបរិមាណផលជលផលក្នុងខេត្ត ................................ 35
ក្រាហ្វិក 14. ការវិវឌ្ឍន៍នៃផ្ទៃដីសហគមន៍ព្រៃឈើ ................................ 38
ក្រាហ្វិក 15. ការវិវឌ្ឍន៍នៃការប្រមូលចំណូល ................................ 42
ក្រាហ្វិក 16. ចំនួនមន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ................................ 44
ក្រាហ្វិក 17. ផ្ទៃដីដំណាំស្រូវរងការខូចខាតដោយគ្រោះធម្មជាតិ និងផ្ទៃដីស្តារឡើងវិញ ឆ្នាំ២០១៤-២០១៨................ 47

# សេចក្តីផ្តើម

ខេត្តតាកែវជាខេត្តមួយស្ថិតនៅប៉ែកនារតីនៃប្រទេសកម្ពុជា ចម្ងាយពីរាជធានីភ្នំពេញ ៨៧គ.ម តាមផ្លូវជាតិលេខ៣ និងចំងាយ៧៧ គីឡូម៉ែត្រ តាមបណ្តោយផ្លូវជាតិលេខ ២ ។ ខេត្តតាកែវមានព្រំប្រទល់ខាងកើតជាប់នឹងប្រទេសវៀតណាម ខាងលិច ជាប់នឹងខេត្តកំពង់ស្ពឺ ខាងជើងជាប់នឹងខេត្តកណ្តាល និងខាងត្បូង ជាប់នឹងខេត្តកំពត និងប្រទេសវៀតណាម។ ខេត្តតាកែវចែកចេញជា ១ក្រុង និង ៩ស្រុក ដែលមាន ៣សង្កាត់ និង ៩៧ឃុំ និង ១ ១១៩ភូមិ ដែលមានផ្ទៃដីធម្មជាតិសរុប ៣ ៦៨០,១៥គ.ម² ក្នុងនោះមានផ្ទៃដីដែលមានសក្តានុពលក្នុងផលិតកម្មកសិកម្មចំនួន ២៦៤ ០០០ហិចតា ដែលចែកចេញជាផ្ទៃដី ស្រូវវដូវវស្សាចំនួន ១៨០ ០០០ ហិចតា, ស្រូវវដូវប្រាំងចំនួន ៨០ ០០០ ហិចតា និងផ្ទៃដីចំការចំនួន ៤ ០០០ ហិចតា ក្រៅពីនោះជាផ្ទៃដីលំនៅដ្ឋាន ព្រៃ បឹង ស្ទឹង ប្រឡាយ និងសំណង់។ល។ ប្រជាជនសរុបមាន ១ ០២៦ ២០១នាក់ ស្មើនឹង២២១ ៧៣៦គ្រួសារក្នុងនោះស្រី៥២៧ ៦៨៩នាក់មានដង់ស៊ីតេប្រជាជន២៧៩នាក់ក្នុង១គ.ម²។ ចំណែកឯចំណូលរបស់ប្រជាពលរដ្ឋនៅក្នុងខេត្តតាកែវប្រមាណ ៥៥,៤% ដែលទទួលបានពីវិស័យកសិកម្មដោយធ្វើស្រែចំការនេសាទត្រី និងចិញ្ចឹមសត្វដែលជាវិស័យចម្បងក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួន។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្តតាកែវ(២០១៩-២០២៣)រៀបចំឡើងផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០១៩-២០២៣) របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ(២០១៤-២០១៨)របស់ខេត្តតាកែវផែនការវិនិយោគបីឆ្នាំរំកិលរបស់ខេត្ត និងឯកសារមួយចំនួនទៀតជាពិសេសផ្អែកលើសក្តានុពលរបស់ខេត្ត និងបញ្ហាប្រឈមនានាដែលកើតមានឡើងក្នុងដំណើរការអនុវត្តផែនការសកម្មភាពរយៈពេលកន្លងមក។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្តតាកែវ (២០១៩-២០២៣) រៀបចំឡើងដើម្បីតម្រង់ទិសក្របខ័ណ្ឌនានាដែលត្រូវអនុវត្តរយៈពេល០៥ឆ្នាំ ក្នុងការអភិវឌ្ឍន៍ការងារកសិកម្ម សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាកសិករ ។ ផែនការអភិវឌ្ឍន៍កសិកម្មខេត្តដែលបានរៀបចំឡើងនេះនឹងប្រើប្រាស់ជាមូលដ្ឋានដ៏សំខាន់ក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ផែនការយុទ្ធសាស្ត្រថវិកា (BSP) និងថវិកាកម្មវិធី (PB) ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ (២០១៩-២០២៣) នេះរៀបចំឡើងដោយមានការចូលរួមពីមន្ត្រីការិយាល័យជំនាញថ្នាក់ខេត្តនៃមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ការិយាល័យកសិកម្មក្រុង-ស្រុក អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងដៃគូអភិវឌ្ឍន៍ដើម្បីកំណត់អំពីលទ្ធផលដែលសម្រេចបានចំណុចខ្លាំង បញ្ហាប្រឈម ឱកាស កត្តាគម្រាមកំហែង និងយុទ្ធសាស្ត្រដែលត្រូវអនុវត្តបន្តដើម្បីដោះស្រាយបញ្ហាដែលនៅសេសសល់ និងត្រូវអនុវត្តស្របតាមសេចក្តីត្រូវការរបស់កសិករនៅតាមជនបទ និងកម្មវិធីកំណែទម្រង់ស៊ីជម្រៅលើវិស័យកសិកម្មរបស់រាជរដ្ឋាភិបាល។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មខេត្ត បានកំណត់អំពីចក្ខុវិស័យគោលដៅគោលបំណងសូចនាករជាក់លាក់ និងសកម្មភាពជាយុទ្ធសាស្ត្រដើម្បីអនុវត្តន៍ដែលជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត ក្នុងការប្រើប្រាស់ធនធានមនុស្សថវិកាមធ្យោបាយសម្ភារៈ និងសក្តានុពលដែលមានក្នុងខេត្តតាមរយៈការបញ្ចូលបច្ចេកទេសកសិកម្មសមស្របជូនកសិករ (ការដាំដំណាំ ការចិញ្ចឹមសត្វ ទីផ្សារលក់ផលិតផល និងការកែច្នៃ)ការពង្រឹងស្ថាប័នការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងការអភិវឌ្ឍធនធានមនុស្ស។

**ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មខេត្តតាកែវចែកចេញជា ២ផ្នែក ÷**

- **ផ្នែកទី១** រៀបរាប់អំពីសមិទ្ធផលសម្រេចបានរយៈពេល ០៥ឆ្នាំ (២០១៤-២០១៨) ដែលទទួលបានមកពីការខិតខំប្រឹងប្រែងរបស់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តកសិករ និងការរួមចំណែកឧបត្ថម្ភគាំទ្រពីស្ថាប័នរដ្ឋមន្ទីរជំនាញពាក់ព័ន្ធអាជ្ញាធរគ្រប់លំដាប់ថ្នាក់ផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍ទាំងអស់ដែលមានក្នុងខេត្ត។ ផ្នែកនេះក៏បានបង្ហាញផងដែរនូវនិន្នាការអភិវឌ្ឍន៍នៃបណ្តាអនុវិស័យនៃការងារកសិកម្មតាមបណ្តាឆ្នាំនីមួយៗចាប់តាំងពីឆ្នាំ ២០១៤-២០១៨ ជាពិសេសបានរំលេចផងដែរនូវចំណុចខ្លាំង បញ្ហាប្រឈម ឱកាស និងកត្តាគំរាមកំហែងក្នុងការអនុវត្តផែនការសកម្មភាពកន្លងមកដែលជាចំណុចសំខាន់ក្នុងការកំណត់យុទ្ធសាស្រ្ត និងសកម្មភាពដែលត្រូវអនុវត្តនៅពេលអនាគត។

- **ផ្នែកទី២** បង្ហាញអំពីក្របខ័ណ្ឌដែលត្រូវអនុវត្តបន្តដោយផ្អែកតាមកម្មវិធីកំណែទម្រង់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើការងារកសិកម្ម និងផ្អែកលើបញ្ហានៅសេសសល់កន្លងមកដែលពុំទាន់បានដោះស្រាយរួច និងត្រូវបន្តដោះស្រាយ។ ក្នុងផ្នែកនេះក៏បានរៀបរាប់អំពីទស្សនៈវិស័យបេសកកម្មយុទ្ធសាស្រ្ត និងសកម្មភាពដែលត្រូវអនុវត្តដោយការិយាល័យជំនាញពាក់ព័ន្ធទាំងអស់ក្នុងកម្មវិធីទី១ ស្តីពីបង្កើនផលិតភាពពិពិធកម្មដំណាំកសិកម្ម និងពង្រីកកសិធុរកិច្ច កម្មវិធីទី២ ស្តីពីលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វជាលក្ខណៈពាណិជ្ជកម្ម កម្មវិធីទី៣ ស្តីពីពង្រីកការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តរភាព កម្មវិធីទី៤ស្តីពីពង្រីកការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព និងកម្មវិធីទី៥ ស្តីពីបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងស្ថាប័នសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ការបញ្ជ្រាបយេនឌ័រក្នុងការងារកសិកម្ម ការបញ្ចូលបច្ចេកទេសកសិកម្មបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ និងការប៉ាន់ស្មានថវិកាសម្រាប់បណ្តាឆ្នាំនីមួយៗចាប់ពីឆ្នាំ ២០១៩-២០២៣ ក្រៅពីពត៌មានដូចបានរៀបរាប់ខាងលើផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មខេត្ត(២០១៩-២០២៣) នេះក៏បានភ្ជាប់នូវពត៌មានលម្អិតនៃអនុវិស័យកសិកម្មទាំងអស់ដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ។

# ផ្នែកទី១

# សមិទ្ធផលដែលសម្រេចបាន និងបញ្ហាប្រឈមនានាក្នុងការងារកសិកម្មខេត្ត

## ១.១ ស្ថានភាពទូទៅ

ការអភិវឌ្ឍន៍ផ្នែកកសិកម្ម គឺជាកិច្ចការមួយមានសារៈសំខាន់ ដែលបានកំណត់ក្នុងគោលនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល បានផ្តោតលើការយកចិត្តទុកដាក់ជាសំខាន់លើ÷ ១ ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទ ២ ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយចីរភាព ៣ ការពង្រឹងការគ្រប់គ្រងនគរូបនីកម្ម ៤ ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ចតុកោណដំណាក់កាលទី៤នេះគឺជាក្របខ័ណ្ឌមូលដ្ឋានសម្រាប់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទក៏ដូចជាមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទរៀបចំអភិវឌ្ឍន៍ក្នុងវិស័យនេះសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ។ ក្នុងទិសដៅកាត់បន្ថយភាពក្រីក្រនៅតាមសហគមន៍ជនបទដើម្បីទទួលបាននូវសន្តិសុខស្បៀង និងជម្រុញកំណើនសេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើន។

ក្នុងចំណោមប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្នុងខេត្តមានប្រមាណ ៧៥% ពឹងផ្អែកលើការធ្វើកសិកម្មមានជាអាទិ៍ការដាំដុះដំណាំស្រូវ ដំណាំរួមផ្សំ ដំណាំកសិ-ឧស្សាហកម្ម ការចិញ្ចឹមសត្វ ការនេសាទ និងអនុផលព្រៃឈើ។ រីឯចំណូលសរុបដែលទទួលបានវិស័យនេះប្រមាណ៥៥,៤% ក្នុងឆ្នាំៗដែលបានជួយកាត់បន្ថយភាពក្រីក្រដល់ប្រជាជនក្នុងខេត្ត។

ការអភិវឌ្ឍន៍ផ្នែកកសិកម្មក្នុងខេត្តតាកែវរយៈពេល០៥ឆ្នាំកន្លងមក (២០១៤-២០១៨) មានការរីកចម្រើនគួរឱ្យកត់សម្គាល់ដែលអាចបំពេញនូវសេចក្តីត្រូវការក្នុងខេត្ត និងនាំចេញក្រៅខេត្ត និងប្រទេសជិតខាងបានមួយចំនួន។ ក្រៅពីនេះក្រុមហ៊ុនឯកជនបានចូលរួមយ៉ាងសកម្មក្នុងដំណើរវិនិយោគផ្នែក កសិឧស្សាហកម្មព្រោះមានរោងម៉ាស៊ីនកិនស្រូវខ្នាតអន្តរជាតិដែលជាគន្លឹះជួយឲ្យវិស័យកសិកម្មក្នុងខេត្តរីកចម្រើនបានមួយកំរិតទៀត និងបានធ្វើឲ្យជីវភាពប្រជាពលរដ្ឋក្នុងខេត្តកាន់តែមានជីវភាពប្រសើរឡើង។ ស្រូវប្រាំងជាតំបន់មានប្រភពទឹកគ្រប់គ្រាន់ដីមានជីជាតិល្អលិចទឹករយៈពេលពី-បីខែទៅប្រាំមួយខែមានលក្ខណៈអំណោយផលសំរាប់៩ស្រុក និង១ក្រុង។ កសិករនិយមប្រើប្រាស់ពូជស្រូវស្រាលទំនើប (IR)មិនប្រកាន់រដូវចាប់ផ្តើមពាក់កណ្តាលខែតុលា រហូតដល់ខែមេសា ដែលទទួលទិន្នផលបានជាមធ្យម៤,៨តោន/ហិចតាលើផ្ទៃដីផែនការ៨០ ០០០ហិចតា តែកន្លែងខ្លះអាចប្រមូលបានផលពីរដងក្នុងមួយរដូវធ្វើឲ្យការអនុវត្តន៍លើសផែនការ។ដោយឡែកចំពោះស្រូវវស្សាមានសក្តានុពលភាពចំពោះស្រូវប្រណិត (ស្រូវក្រអូប) សំរាប់នាំចេញដែលអាចដាំដុះគ្របដណ្តប់គ្រប់ស្រុកក្រុងទូទាំងខេត្ត។ ជាតំបន់ខ្ពស់មានលក្ខណៈជាខ្ពង់រាប កសិករនិយមប្រើប្រាស់ពូជស្រូវ ស្រាល កណ្តាល ធ្ងន់ដែលមានផ្ទៃដីផែនការ ១៨០ ០០០ហិចតា តែដោយកន្លែងមួយចំនួនអាចអនុវត្តន៍បានពីរដងក្នុងមួយរដូវធ្វើឲ្យការ បង្ករបង្កើនផលទទួលបានលទ្ធផលលើសផែនការ និងទទួលបានទិន្នផលជាមធ្យម ៣,៣៥តោន/ហិចតា។ ការធ្វើស្រូវរដូវប្រាំង និងរដូវវស្សា ទទួលបានផលល្អដោយសារខេត្តមានសក្តានុពលនៃប្រព័ន្ធស្រោចស្រពធំធេង គឺខេត្តតាកែវមានស្ទឹងតាកែវភ្ជាប់ពីទន្លេបាសាក់ និងប្រឡាយមេ ២៧២ខ្សែ និងប្រឡាយរងចំនួន ៤៥៤ខ្សែ ព្រមទាំងអាងទឹកចំនួន ១២១ កន្លែងដែលធានាស្រោចស្រពបានទូទាំងស្រុងនៅរដូវប្រាំង និងអនុវត្តស្រូវដើមរដូវ និងសង្គ្រោះស្រូវវស្សាបានមួយចំនួនធំទៀត។ ការចិញ្ចឹមសត្វក៏មានការរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំទោះបីស្ថិតិសត្វគោ-ក្របីធ្លាក់ចុះបន្តិចដោយសាការអភិវឌ្ឍន៍ផ្នែកយន្តូបនីយកម្មនៅតាមបណ្តាមូលដ្ឋាននានាក៏ដោយក៏អត្រាសត្វឈី-ងាប់ លើសត្វគ្រប់ប្រភេទមានការថយចុះគួរឲ្យកត់ សម្គាល់ដោយនៅក្នុងភូមិនីមួយៗយើងមានភ្នាក់ងារសុខភាពសត្វភូមិពី១-២នាក់ សំរាប់បំរើសុខភាពសត្វភូមិ និងផ្សព្វផ្សាយ បច្ចេកទេសទៅកសិករ។ ក្រៅពីនេះយើងមានវិធីបង្កាត់គោដោយសិប្បនិម្មិតនៅថ្នាក់ខេត្ត និងបង្កាត់ជ្រូកដល់ថ្នាក់ស្រុក និងមូលដ្ឋាន

(ភូមិ) ព្រមទាំងមានកម្មវិធីដាំស្មៅចំណីសត្វដែលផ្តល់ប្រូតេអ៊ីនខ្ពស់ដល់សត្វពាហនៈ។ សមត្ថភាពគ្រប់គ្រងសម្ភារៈកសិកម្ម និងការផ្តល់សេវាកម្មកសិកម្មពីសំណាក់មន្ត្រីជំនាញកាន់តែមានភាពល្អប្រសើរ និង ខិតជិតប្រជាកសិករ។ ការយល់ដឹងរបស់ប្រជាកសិករលើបច្ចេកទេសដាំដុះដំណាំ ការចិញ្ចឹមសត្វ ការជ្រើសរើសពូជ ការគ្រប់គ្រងដី និងការ ប្រើប្រាស់សម្ភារៈកសិកម្មគ្រប់ប្រភេទក៏មានការវិវឌ្ឍន៍ទៅមុខដែរ។

ទោះបីជាបច្ចុប្បន្ននេះ ការអភិវឌ្ឍន៍កសិកម្មក្នុងខេត្តមានការរីកចម្រើនយ៉ាងណាក៏ដោយក៏យើងនៅ ពិនិត្យឃើញថាលទ្ធផលដែលសម្រេចបានពុំទាន់ឆ្លើយតបទៅនឹងសក្តានុពលធនធានដែលមានក្នុងខេត្ត និងតម្រូវការរបស់ប្រជាពលរដ្ឋនៅឡើយដែលទាមទារត្រូវអភិវឌ្ឍន៍បន្ថែមទៀត។ ទិន្នផលគ្រប់មុខដំណាំទាំងអស់ទទួលបាននៅមានកម្រិតទាបដោយសារលក្ខ-ខណ្ឌធម្មជាតិគ្រោះធម្មជាតិ (ទឹកជំនន់ រាំងស្ងួត) តែងកើតឡើងជារឿយៗកសិករនៅអនុវត្តការដាំដុះដំណាំ និងចិញ្ចឹមសត្វតាមទំលាប់ចាស់ (ប្រើប្រាស់ពូជដំណាំប្រពៃណីមានអាយុកាលវែងផ្តល់ទិន្នផលទាប និងពូជសត្វប្រពៃណីមានមាឌតូចលូតលាស់យឺត ។ល។ )សេវាគាំទ្របច្ចេកទេសកសិកម្មនៅមានកម្រិតទាប ហើយតម្លៃផលិតផលកសិកម្មឡើងចុះពុំទៀងទាត់ និងពុំមានទីផ្សារច្បាស់លាស់។

**អាកាសធាតុ និងដី**

អាកាសធាតុខេត្តតាកែវចែកចេញជារដូវវស្សានិងរដូវប្រាំងបរិមាណទឹកភ្លៀងសរុបប្រចាំឆ្នាំមានការប្រែប្រួលប្រមាណពី ១ ៥៩២ ម.ម ក្នុងឆ្នាំ២០១៨ និង១ ៤០១ម.ម ក្នុងឆ្នាំ ២០១៩ រដូវវស្សាជាទូទៅចាប់ផ្តើម ពីខែឧសភា ដល់ខែតុលា។ រយៈពេលនេះកសិករ ជាទូទៅមានការរវល់ច្រើនក្នុងការបង្កបង្កើនផល។ នៅក្នុងរដូវវស្សាតែងតែមានកួនរដូវប្រាំងមួយដែលតែងតែកើតឡើងក្នុងរយៈពេលពី ២-៣សប្តាហ៍ក្នុងខែមិថុនាឬកក្កដា ហើយពេលខ្លះកើតឡើងក្នុងខែសីហា។ បរិមាណទឹកភ្លៀងច្រើនមាននៅក្នុង ខែមិថុនា និងកក្កដា។ រដូវប្រាំងចាប់ផ្តើមពីខែវិច្ឆិការហូតដល់ខែមេសា។ បរិមាណទឹកភ្លៀងច្រើនជាងគេមាននៅក្នុងខែវិច្ឆិកា ។ ក្នុងរដូវនេះដីកសិកម្មមួយចំនួនធំ បានទុកចោលទំនេរលើកលែងនៅតំបន់ដែលមានប្រភពទឹកដើម្បីស្រោចស្រព ។ បរិមាណទឹកភ្លៀងដើរតួយ៉ាងសំខាន់លើការលូតលាស់ដាំដុះគ្រប់ប្រភេទការបង្កើនទិន្នផល និងបរិមាណផលរបស់ដំណាំ ។ របបទឹកភ្លៀងនៅប្រទេសកម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងរបបខ្យល់មូសុងខ្យល់បក់ពីទិសនិរតីទៅទិសឦសាន្តគឺពីខែឧសភាដល់ខែតុលា ដែលខ្យល់បាននាំទឹកភ្លៀងមកជាមួយ។

**បរិមាណទឹកភ្លៀង**

ការអភិវឌ្ឍវិស័យកសិកម្មក្នុងខេត្ត នៅរណបរបបទឹកភ្លៀងនៅឡើយ ព្រោះការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រក្នុងខេត្តនៅមានកម្រិតទាបដែលទាមទារនូវការអភិវឌ្ឍបន្ថែម និងស្តារឡើងវិញ។ ផ្អែកតាមក្រាហ្វិកទី ១ ពីបរិមាណទឹកភ្លៀងឆ្នាំ ២០១៤-២០១៨ បានបង្ហាញថាឆ្នាំ២០១៨ បរិមាណទឹកភ្លៀងខ្ពស់ជាអតិបរិមា និងមានរហូតទៅ ១ ៥៩២ម.ម ដែលអំណោយផលដល់ការលូតលាស់ដំណាំគ្រប់ប្រភេទផ្ទុយទៅវិញនៅឆ្នាំ២០១៤បរិមាណទឹកភ្លៀងមានត្រឹមតែ ១ ០២០ម.ម ដែលជះឥទ្ធិពលអាក្រក់ដល់ដំណាំគ្រប់ប្រភេទ និងសត្វគ្រប់ប្រភេទ។ ក្រៅពីនេះ មន្ទីរកសិកម្មសង្កេតឃើញមានកត្តាអវិជ្ជមានមួយចំនួនទៀតដូចជា÷ របាយទឹកភ្លៀងធ្លាក់ពុំបានស្មើសព្វគ្រប់ក្រុង-ស្រុក កម្រិតទឹកភ្លៀងបានធ្លាក់តិចតួចនៅដើមរដូវនិងច្រើនខ្លាំងនៅពាក់កណ្តាលរដូវ និងចុងរដូវដែលជះឥទ្ធិពលទៅលើល្បឿនដាំដុះ និងទិន្នផលដំណាំគ្រប់ប្រភេទ។




*ក្រាហ្វិក 1 ÷ បរិមាណទឹកភ្លៀងក្នុងខេត្ត ចាប់ពីឆ្នាំ២០១៥-២០១៩*

**កម្ពស់ទឹកទន្លេ**

របបទឹកទន្លេជាប្រភពធនធានដ៏សំខាន់សម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មក្នុងខេត្ត ពិសេសបណ្ដាក្រុង-ស្រុកដែលស្ថិតនៅតំបន់ទំនាបដែលជារៀងរាល់ឆ្នាំ ទឹកទន្លេមេគង្គតែងជន់លិចនាំដីល្បាប់កម្ទេចកំទីផ្សេងៗដែលជាដីមានជីជាតិនៅពេលដែលស្រកទៅវិញបន្សល់ទុកនូវដីមានជីជាតិសម្រាប់ប្រកបការដាំដុះដំណាំគ្រប់ប្រភេទ ជាពិសេសការដាំដុះស្រូវវស្សា ស្រូវប្រដេញទឹក និងដំណាំរួមផ្សំគ្រប់ប្រភេទជាអាទិ៍ ស្រូវ ពោត សណ្ដែក បន្លែគ្រប់ប្រភេទ ។ល។ ក្រៅពីសារៈសំខាន់ដូចបានរៀបរាប់ខាងលើរបបទឹកទន្លេក៏បានរួមចំណែកបំផ្លាញកត្តាចង្រៃផ្សេងៗដែលតែងតែយាយីដល់ដំណាំគ្រប់ប្រភេទ និងសត្វដូចជាសត្វកណ្ដុរ សត្វល្អិតចង្រៃ ជំងឺផ្សេងៗ។




*ក្រាហ្វិក 2. ការវិវឌ្ឍន៍នៃកម្ពស់ទឹកទន្លេ*

**សណ្ឋានដី**

ផ្អែកតាមលក្ខណៈសណ្ឋានដីខេត្តតាកែវចែកចេញជាដីធម្មជាតិសរុប ៣ ៦៨០,១៥គ.ម² ក្នុងនោះមានផ្ទៃដីដែលមានសក្តានុពលភាពក្នុងផលិតកម្មកសិកម្មចំនួន ២៦៤ ០០០ ហិចតា ដែលចែកចេញជាផ្ទៃដី ស្រូវរដូវវស្សាចំនួន ១៨០ ០០០ ហិចតា, ស្រូវរដូវប្រាំងចំនួន ៨០ ០០០ ហិចតា និងផ្ទៃដីចំការចំនួន ៤ ០០០ ហិចតា ក្រៅពីនោះជាផ្ទៃដីលំនៅដ្ឋាន ព្រៃ បឹងស្ទឹង ប្រឡាយ និងសំណង់។ល។ ប្រភេទដីទាំងអស់ខាងលើមានអំណោយផលដល់ការដាំដំណាំស្រូវ ដំណាំរួមផ្សំ និងដំណាំកសិ-ឧស្សាហកម្ម គ្រប់ប្រភេទ និងចិញ្ចឹមសត្វ។

## ១.២ សមិទ្ធផលដែលសម្រេចបាន និងបញ្ហាប្រឈមក្នុងការងារកសិកម្ម

### ១.២.១ ផលិតកម្មដំណាំស្រូវ

#### ក. ការពណ៌នា

ចំពោះការងារបង្កបង្កើនផលតាមរដូវស្រូវវស្សា-ប្រាំង និងបង្កើនរដូវ ទោះបីជាមានឧបសគ្គខ្លះៗ ដូចជា គ្រោះរាំងស្ងួតទឹកជំនន់ ការយាយីពីសំណាក់តក្កាចង្រៃផ្សេងៗទៀតដូចជា សត្វល្អិតចង្រៃ ជំងឺផ្សិត បាក់តេរី និងជំងឺខ្លះៗក៏ដោយ តែការបង្កបង្កើនផលស្រូវទទួលបានលទ្ធផលល្អស្របតាមគោលដៅរបស់មន្ទីរ កសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តដែលបានកំណត់ក្នុងផែនការ។

#### ខ. ការវិភាគស្វត

| ចំណុចខ្លាំង | ឱកាស |
|---|---|
| - ផ្ទៃដីដាំដុះធំទូលាយនិងមានដីជាតិសម្រាប់ការផលិត<br>- សហគមន៍ផលិតពូជ<br>- មានពូជត្រូវការទីផ្សារ<br>- អង្ករជាអាហារចំបងរបស់ប្រជាពលរដ្ឋ<br>- ស្រូវអង្ករជាប្រភេទចំណូលសេដ្ឋកិច្ចគ្រួសារ<br>- ប្រើប្រាស់គ្រឿងចក្រដើម្បីកាត់បន្ថយថ្លៃដើម និងកំលាំងពលកម្ម ដើម្បីផលិតលឿនទាន់រដូវកាល<br>- បរិមាណផលស្រូវគ្រប់ត្រូវការក្នុងខេត្ត និងសល់លក់ទៅទីផ្សារខាងក្រៅ<br>- មានអ្នកបច្ចេកទេសពីថ្នាក់ខេត្តដល់ថ្នាក់ស្រុក ចុះផ្សព្វផ្សាយដល់មូលដ្ឋាន<br>- អាចផលិតបាន២-៣ដងក្នុង១ឆ្នាំ (បង្កើនរដូវ)<br>- កសិករមានកាយល់ដឹងពីបច្ចេកទេសកសិកម្មថ្មីៗ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ (មន្ទីរបានបណ្តុះបណ្តាល និងមានឯកសារបច្ចេកទេសដំណាំស្រូវ)<br>- កសិករមានចំណេះដឹងក្នុងការជ្រើសរើសពូជសុទ្ធទទួលបានទិន្នផលខ្ពស់បង្កើតសហគមន៍ និងបណ្តុំអាជីវកម្ម ក្នុងការធ្វើកសិកម្មតាមកិច្ចសន្យាមានអំណាច ក្នុងការចរចារតម្លៃទីផ្សារ | - មានការគាំទ្រពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា<br>- រដ្ឋាភិបាលមិនយកពន្ធលើដីស្រែ<br>- មានទីផ្សារស្រូវ អង្ករនៅក្រៅប្រទេស<br>- មានការចូលរួមវិនិយោគពីវិស័យឯកជន<br>- គ្រឿងយន្ត និងសម្ភារៈកសិកម្មនាំចូលរដ្ឋមិនត្រូវឲ្យបង់ពន្ធលើកលែងតែគ្រឿងបន្លាស់<br>- ទីតាំងផ្គត់ផ្គង់សម្ភារៈកសិកម្មច្រើនប្រភេទមានលក់នៅតាមមូលដ្ឋាន<br>- មានសក្តានុពលទីផ្សារស្រូវទាំងក្នុងខេត្ត/ទូទាំងប្រទេស<br>- រាជរដ្ឋាភិបាលមានយុទ្ធសាស្ត្រ និងគោលនយោបាយលើកកម្ពស់ដំណាំស្រូវ និងអង្ករ<br>- រាជរដ្ឋាភិបាលលើកទឹកចិត្តក្នុងការធ្វើកសិកម្មកិច្ចសន្យាសម្រាប់ស្រូវ និងអង្ករវាងក្រុមហ៊ុនឯកជន និងសហគមន៍កសិកម្មមានទីតាំងជាប់ប្រទេសជិតខាងងាយស្រួលដល់ការលក់ដូរ។ |

| ដែលមានការគាំទ្រនិងទទួលស្គាល់ពីមន្ទីរ។ | |
|---|---|
| **ចំណុចខ្សោយ** | **ការគំរាមកំហែង** |
| - បច្ចេកទេសកសិករនៅមានកំរិត<br>- មិនមានទឹកគ្រប់គ្រាន់ទាំងរដូវវស្សានិងរដូវប្រាំង<br>- ថ្លៃដើមផលិតខ្ពស់<br>- កសិករនៅប្រើពូជប្រពៃណី<br>- ថវិកាជាតិនៅមានកំរិតសំរាប់ទ្រទ្រង់ផលិតពូជក្នុងស្ថានីយ៍ និងសហគមន៍<br>- ធនធានដីជាតិដីក្នុងខេត្តភាគច្រើនជាប្រភេទដីខ្សាច់ដីជាតិ<br>- មិនមានកិច្ចព្រមព្រៀងក្នុងការផលិត<br>- ខ្វះកំលាំងពលកម្ម<br>- ប្រជាកសិករមួយចំនួនមានការយល់ដឹងតិចតួចពីបច្ចេកទេសកសិកម្មទំនើប<br>- ប្រជាកសិករក្នុងនៅពឹងអាស្រ័យលើទឹកភ្លៀងសម្រាប់ផលិតកម្មស្រូវ<br>- ប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រពដំណាំស្រូវនៅមិនទាន់គ្រប់គ្រាន់<br>- ប្រជាកសិករមានផ្ទៃដីដាំដុះដំណាំស្រូវតិច<br>- ថវិកាសម្រាប់គាំទ្រក្នុងការផ្តល់សេវាកម្មគាំទ្រកសិករមានកម្រិតដែលមិនទាន់សមស្របនឹងតម្រូវការរបស់កសិករ។ | - ការប្រែប្រួលអាកាសធាតុ ( បរិមាណទឹកភ្លៀងថយចុះកំដៅឡើងខ្លាំង រាំងស្ងួត ទឹកជំនន់ )<br>- ការផ្តល់ថវិការបស់ធនាគារអភិវឌ្ឍន៍ជនបទ (RDB) មិនបានដល់ដៃសហគមន៍កសិករ<br>- ខ្វះទុនវិនិយោគ ( ខ្ចីទុនពីធនាគារការប្រាក់ខ្ពស់)<br>- តម្លៃស្រូវអង្ករមិនមានស្ថេរភាព( ឡើងចុះអាស្រ័យលើឈ្មួញ )<br>- ប្រព័ន្ធស្រោចស្រពមិនគ្រប់គ្រាន់តាមតម្រូវការ<br>- មានផ្ទុះដង្កូវ និងសត្វល្អិតចង្រៃញឹកញាប់ និងមានប្រភេទថ្មីៗ<br>- ថ្លៃដើមក្នុងការផលិតក្នុងមួយឯកតាក្នុងផលិតកម្មស្រូវមានកម្រិតខ្ពស់<br>- កង្វះខាតកំលាំងពលកម្មក្នុងផលិតកម្មស្រូវ<br>- ដីដាំដុះដំណាំស្រូវមួយចំនួនត្រូវបានលក់ឲ្យឈ្មួញសម្រាប់ការអភិវឌ្ឍន៍<br>- ផ្ទៃដីផលិតកម្មស្រូវបង្វែរមកបំរើឲ្យវិស័យឧស្សាហកម្ម និងសំណង់<br>- ខ្វះកំលាំងពលកម្មសកម្មក្នុងផលិតកម្មស្រូវដោយសារចំណាកស្រុក និងការធ្វើការក្នុងរោងចក្រ។ |

### គ. តារាងស្ថិតិដំណាំស្រូវ

**តារាងទី 1 ÷ បង្ហាញពីផលិតកម្មស្រូវក្នុងខេត្ត ឆ្នាំ២០១៤-២០១៨**

| ការពិពណ៌នា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | អត្រាផ្លាស់ប្តូរ(%) ២០១៤-២០១៨ |
|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ( ហិកតា) | 296,739 | 295,843 | 296,114 | 298,507 | 302,858 | 2.06% |
| ផ្ទៃដីប្រមូលផល ( ហិកតា) | 296,739 | 295,843 | 296,101 | 297,879 | 302,546 | 1.59% |
| ទិន្នផលស្រូវប្រចាំឆ្នាំ( គោន/ ហ.ត) | 3,760 | 3,808 | 3,836 | 3,852 | 3,913 | 4.06% |
| បរិមាណផលស្រូវ ( តោន) | 1,115,722 | 1,126,470 | 1,135,852 | 1,146,840 | 1,183,898 | 6.11% |
| អតិរេកអង្ករ ( តោន) | 484,449 | 487,898 | 490,642 | 494,999 | 513,888 | 6.07% |
| អតិរេកស្រូវ ( តោន) | 756,952 | 762,341 | 766,628 | 773,436 | 802,950 | 6.07% |

តារាងខាងលើបានបង្ហាញថាឆ្នាំ២០១៤ ផ្ទៃដីដាំដុះស្រូវសរុបមានតែចំនួន ២៩៦ ៧៣៩ ហ.ត និងបានកើនដល់ចំនួន ៣០២ ៨៥៨ ហ.ត ក្នុងឆ្នាំ២០១៨ ដែលមានអត្រាកំណើនប្រមាណចំនួន ២,០៦%។ ក្នុងរយៈពេល ០៥ឆ្នាំនេះផ្ទៃដីប្រមូលផលស្រូវមានកំណើនជាមធ្យម ០,៤៩% និងទិន្នផលសម្រេចបានកំណើនពុំទាន់ទៀងទាត់នៅឡើយទេក្នុង ០១ឆ្នាំៗ ដោយមានអត្រាកំណើន ៤,០៦%។ ដោយឡែកបរិមាណផលស្រូវសរុបមានអត្រាកំណើនប្រមាណ ៦,១១%ក្នុងរយៈពេល ០៥ឆ្នាំកន្លងមកនេះ។

ផ្អែកតាមលទ្ធផលខាងលើយើងអាចវាយតម្លៃថាពីមួយឆ្នាំទៅមួយឆ្នាំ ផលិតកម្មដំណាំស្រូវមានការកើនឡើងជាលំដាប់ទាំងផ្ទៃដីដាំដុះទិន្នផល និងបរិមាណផល។សមិទ្ធផលដែលទទួលបាននេះបានបង្ហាញពីប្រសិទ្ធភាពនៃការគាំទ្រពីសំណាក់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និង គម្រោងអភិវឌ្ឍន៍នានា ដូចជាគម្រោង PADEE និង ការបញ្ចូលសកម្មភាពក្នុងកម្មវិធីវិនិយោគឃុំ-សង្កាត់ នៅតាមមូលដ្ឋាននានា ដោយធ្វើឱ្យកសិករ កាន់តែមានចំណេះដឹងអំពីបច្ចេកទេសថ្មីទំនើប ដូចជា ការប្រើប្រាស់ពូជសុទ្ធល្អផ្តល់ទិន្នផលខ្ពស់ វិធានការគ្រប់គ្រងកត្តាចង្រៃ តាមរយៈការទស្សនកិច្ចសិក្សា ការបណ្តុះបណ្តាល ការធ្វើបង្ហាញផ្ទាល់ ការផ្សព្វផ្សាយតាមរយៈការចែក ព្រឹត្តិបត្របច្ចេកទេសកសិកម្ម និងផ្សព្វផ្សាយតាមវិទ្យុខេត្ត ។

**ផ្ទៃដីដាំដុះដំណាំស្រូវ ឆ្នាំ២០១៤-២០១៨**




*ក្រាហ្វិក 3. ការវិវឌ្ឍន៍ផ្ទៃដីដាំដុះដំណាំស្រូវ*

**តារាងទី 2 ÷ ផលិតកម្មស្រូវតាមរដូវ**

| ដំណាំ | ផ្ទៃដីប្រមូលផល (ហិកតា) | ទិន្នផល (តោន/ហ.ត) | បរិមាណផល (តោន) | អត្រាផ្លាស់ប្តូរ(%) ២០១៤-២០១៩ |
|---|---|---|---|---|
| ដើមរដូវវស្សា (គ្មានប្រព័ន្ធធារាសាស្រ្ត) | 70,018 | 3,505 | 245,441 | 70% |
| ដើមរដូវវស្សា (មានប្រព័ន្ធធារាសាស្រ្ត) | 30,007 | 3,505 | 105,189 | 30% |
| ពាក់កណ្តាលរដូវវស្សា (គ្មានប្រព័ន្ធធារាសាស្រ្ត) | 68,514 | 3,253 | 222,865 | 75% |
| ពាក់កណ្តាលរដូវវស្សា (មានប្រព័ន្ធធារាសាស្រ្ត) | 22,838 | 3,253 | 74,288 | 25% |
| ស្រូវប្រាំង | 102,903 | 4,897 | 503,885 | 100% |

តាមតារាងខាងលើបានបង្ហាញឲ្យដឹងថា ផ្ទៃដីដាំដុះដំណាំស្រូវវស្សាពុំមានប្រព័ន្ធធារាសាស្រ្ត ដើម្បីស្រោចស្រព អាចជួបគ្រោះរាំងស្ងួតមានប្រមាណ ៧០ ០១៨ហ.ត ស្មើនឹង ៧០% នៃផ្ទៃដីសរុបដើមរដូវស្រូវវស្សា (មាន និងគ្មាន ប្រព័ន្ធធារា សាស្រ្ត) ស្មើនឹង ១០០ ០២៥ហ.ត ។ ផ្ទៃដីពាក់កណ្ដាលរដូវវស្សាដែលមាន និងគ្មានប្រព័ន្ធធារាសាស្រ្តស្រោច ស្រពមាន ចំនួន ៩១ ៣៥២ ហ.ត ក្នុងនោះផ្ទៃដី ៧៥%គ្មានប្រព័ន្ធធារាសាស្រ្ត ។

### ១.២.២ ផលិតកម្មដំណាំរួមផ្សំ

#### ក. ការពណ៌នា

ខេត្តតាកែវជាខេត្តមួយមានសណ្ឋានដី ក្រៅពីដំណាំស្រូវនៅមានសក្ដានុពលទៅលើការដាំដុះដំណាំរួមផ្សំ និងដំណាំហូបផ្លែមួយចំនួនដូចជា ដំឡូងមី ដំឡូងជ្វា ពោត សណ្ដែកបាយ សណ្ដែកដី បន្លែគ្រប់ប្រភេទ អំពៅ ល្ង ត្រាវ ស្វាយ ខ្នុរ ចេក និងឪឡឹក ដែលកសិករដាំទៅតាមរដូវកាល និងប្រភេទដីមានលក្ខណៈគ្រួសារផង និងសំរាប់ពាណិជ្ជកម្មផងដែល កសិករបានទាញយកប្រាក់ចំណូលមួយផ្នែកធំបន្ទាប់ពីស្រូវសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារបន្ថែម និងសម្រាប់ហូបផងដែរ។ ចំពោះផ្ទៃដីក៏មានការប្រែប្រួលឡើងចុះនៅតាមឆ្នាំនីមួយៗដោយយោងទៅតាមទំនោរនៃតម្លៃនិងទីផ្សារផលិតផល។

#### ខ. ការវិភាគស្វត

| ចំណុចខ្លាំង | ឱកាស |
|---|---|
| - មានផ្ទៃដីស្រែ ចំការ អាចធ្វើពិពិធកម្មកសិកម្ម<br>- មានការចុះបណ្ដុះបណ្ដាលបច្ចេកទេសការដាំដុះ និងទីផ្សារពីមន្ត្រីជំនាញពាក់ព័ន្ធ<br>- មានការចូលរួមពីកសិករ<br>- មានការគាំទ្រពីស្ថាប័ន។ | - គោលនយោបាយរបស់រាជរដ្ឋាភិបាល យុទ្ធសាស្រ្តចតុកោណ<br>- មានតំរូវការទីផ្សារ<br>- ផ្ដោតទៅលើគុណភាព និងផលិតកម្មតាមកិច្ចសន្យា<br>- មានមន្ត្រីជំនាញតាមស្ថាប័ន<br>- មានកិច្ចសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ |
| **ចំណុចខ្សោយ** | **ការគំរាមកំហែង** |
| - ខ្វះប្រភពទឹក ខ្វះប្រព័ន្ធស្រោចស្រព<br>- កសិករពុំសូវទទួលយកបច្ចេកទេសកសិកម្មថ្មី<br>- មានការយាយីពីកត្តាចង្រៃផ្សេងៗ និងគ្រោះធម្មជាតិ<br>- ទទួលរងការបំរែបំរួលអាកាសធាតុ<br>- តំលៃផលិតផលមិនទៀងទាត់<br>- ថ្លៃដើមផលិតកម្មខ្ពស់<br>- ក្រុមកសិករផលិតពុំទាន់ធានាបាននូវបរិមាណនិងគុណភាព។ | - បរិមាណផលថយចុះ<br>- កំណើនដែលទទួលបានពីកសិកម្មនៅមានកំរិត<br>- មានការប្រកួតប្រជែងពីខាងក្រៅ<br>- មានចំណាកស្រុក និងបាត់បង់ពលកម្មសំរាប់ប្រកបអា ជីវកម្មដាំដុះ<br>- មានការនាំចូលពីប្រទេសជិតខាង<br>- ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាមានចំនួនតិច។ |

#### គ. តារាងស្ថិតិដំណាំរួមផ្សំក្នុងខេត្តតាកែវ

**តារាងទី 3 ÷ ផ្ទៃដីដំណាំរួមផ្សំរបស់ខេត្តតាកែវ (ឆ្នាំ២០១៤-២០១៨)**

| ការពិពណ៌នា | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | អត្រាផ្លាស់ប្ដូរ (%) ២០១៤-២០១៨ |
|---|---|---|---|---|---|---|---|
| ពោត | ហិកតា | 350 | 1,133 | 239 | 243 | 276 | -21.14% |
| ដំឡូងមី | ហិកតា | 664 | 1,355 | 1,830 | 1,836 | 1,810 | 172.59% |
| ដំឡូងជ្វា | ហិកតា | 407 | 262 | 559 | 564 | 524 | 28.74% |
| សណ្ដែកបាយ | ហិកតា | 526 | 553 | 263 | 273 | 331 | -37.07% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សណ្តែកដី | ហិកតា | 228 | 170 | 111 | 121 | 43 | -81.14% |
| ឪឡឹក | ហិកតា | 825 | 653 | 669 | 263 | 269 | -67.39% |
| អំពៅ | ហិកតា | 636 | 422 | 350 | 364 | 376 | -40.88% |
| **សរុប** | | **3,610** | **4,613** | **4,021** | **3,664** | **3,629** | |

តាមតារាងខាងលើបានបង្ហាញឲ្យឃើញថាក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ផ្ទៃដីដំណាំរួមផ្សំមានការប្រែប្រួលដូចជា ពោតមានការថយចុះប្រមាណ ២១,១៤% ដំឡូងមីកើនឡើងប្រមាណ ១៧២,៥៩% ដំឡូងជ្វាមានការកើនឡើងប្រមាណ ២៨,៧៤% សណ្តែកបាយថយចុះប្រមាណ ៣៧,០៧% សណ្តែកដីថយចុះប្រមាណ ៨១,១៤% ឪឡឹកថយចុះប្រមាណ ៦៧,៣៩% និងអំពៅមានការថយចុះប្រមាណ ៤០,៨៨%។ ការប្រែប្រួលមិនទៀងបែបនេះគឺបណ្តាលមកពីកត្តាផ្សេងៗ ដូចជា ការប្រែប្រួលតម្លៃទីផ្សារ ខ្វះកំលាំងពលកម្មដោយសារចំណាកស្រុក បញ្ហាសត្វល្អិតបំផ្លាញ និងការប្រែប្រួលអាកាសធាតុជាដើម។




*ក្រាហ្វិក 4. ការវិវឌ្ឍន៍ផ្ទៃដីដំណាំរួមផ្សំ (៣ប្រភេទ)*




### ១.២.៣ ផលិតកម្មដំណាំបន្លែ

#### ក. ការពណ៌នា

ចំពោះការដាំដុះ ដំណាំបន្លែនៅខេត្តតាកែវរួមមាន សណ្តែក ត្រសក់ ស្ពៃ ខាត់ណា ម្រះ ឆៃថាវ ត្រកួន ត្រឡាច ល្ពៅ ននោង ប៉េងប៉ោះ ត្រប ។ល។ ជាទូទៅកសិករបានដាំដុះជាប្រចាំ តាមស្ថានភាពភូមិសាស្ត្រ ចំពោះផ្ទៃដីដាំដុះមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ និងទៅតាមការប្រែប្រួលអាកាសធាតុ។ តែទោះជាយ៉ាងណាក៏ដោយខេត្តតាកែវ មានស្ថានភាពដីដែលមានសក្តានុពលទៅលើការដាំដុះបន្លែផ្សេងៗតាមលក្ខណៈគ្រួសារសំរាប់ហូប និងលក់ដែលមានផ្ទៃដីសរុបចំនួន ៣ ៩៣៨ ហ.ត ក្នុងឆ្នាំ ២០១៤ ដែលជាឆ្នាំមានកសិករដាំដុះបន្លែច្រើនបំផុតក្នុងរយៈពេល ០៥ ឆ្នាំនេះ(២០១៤-២០១៨)។

#### ខ. ការវិភាគស្វត

| ចំណុចខ្លាំង | ឱកាស |
| --- | --- |
| - មានសក្តានុពលទៅលើការដាំដុះបន្លែ<br>- កសិករទទួលបានបច្ចេកទេសពីមន្ទីរកសិកម្ម និងដៃគូអភិវឌ្ឍន៍<br>- មានការគាំទ្រពីរាជរដ្ឋាភិបាល និងផ្នែកពាក់ព័ន្ធ<br>- មន្ត្រីមានជំនាញ សមត្ថភាពគ្រប់គ្រាន់ និងមានឆន្ទះ។ | - បំពេញតំរូវការនៅលើទីផ្សារ<br>- បរិមាណផលិតផលធានាបាននូវគុណភាព<br>- ឈានទៅធ្វើផលិតកម្មតាមកិច្ចសន្យា<br>- មានការប្រកួតប្រជែង<br>- កសិករទទួលបានប្រាក់ចំណូលបន្ថែម។ |
| **ចំណុចខ្សោយ** | **ការគំរាមកំហែង** |
| - ខ្វះកំលាំងពលកម្មសម្រាប់អនុវត្តការងារកសិកម្ម<br>- ខ្វះប្រភពទឹកស្រោចស្រពនៅរដូវប្រាំង<br>- កសិករមានការដាំដុះដូចៗគ្នាតាមរដូវកាលមិនមានប្រតិទិនដាំដុះច្បាស់លាស់<br>- ខ្វះការសិក្សាទំនាក់ទំនងទីផ្សារ<br>- ផលិតផលបន្លែខ្វះគុណភាព។ | - មានការបំផ្លាញពីកត្តាចង្រៃជាច្រើនដូចជាជំងឺនិងសត្វល្អិត<br>- មិនឆ្លើយតបនឹងតម្រូការទីផ្សារមានការនាំចូលបន្លែពីប្រទេសជិតខាង<br>- កសិផលមានតំលៃថោក<br>- បំរែបំរួលអាកាសធាតុ។ |

### គ. តារាងស្ថិតិដំណាំបន្លែ

**តារាងទី 4 ÷ ផ្ទៃដីដាំដុះដំណាំបន្លែរបស់ខេត្ត (២០១៤-២០១៨)**

| ការពិពណ៌នា | ឯកតា (ហិកតា) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | អត្រាផ្លាស់ប្តូរ (%) ២០១៤-២០១៨ |
|---|---|---|---|---|---|---|---|
| ដំណាំបន្លែគ្រប់មុខ | ហិកតា | 3,938 | 2,833 | 1,606 | 1,620 | 2,668 | -32.24% |
| **សរុប** | | **3,938** | **2,833** | **1,606** | **1,620** | **2,668** | |

តាមតារាងនេះបង្ហាញថាក្នុងឆ្នាំ២០១៤ ដំណាំបន្លែគ្រប់មុខមានផ្ទៃដីដាំដុះចំនួន ៣ ៩៣៨ហិកតា ហើយថយចុះមកត្រឹម២ ៨៣៣ ហិកតានៅឆ្នាំ ២០១៥ និង ១ ៦០៦ហិកតា នៅឆ្នាំ ២០១៦។ ប៉ុន្តែនៅឆ្នាំ ២០១៧ ការដាំដុះបន្លែគ្រប់មុខមានការកើនឡើងលើសឆ្នាំ ២០១៦ ដែលសម្រេចបានរហូតដល់ ១ ៦២០ ហិកតា និងក្នុងឆ្នាំ ២០១៨ ការដាំដុះបន្លែមានការកើនដល់ត្រឹម២ ៦៦៨ហិកតា ការប្រែប្រួលនេះបណ្តាលមកកត្តាផ្សេងៗតាមឆ្នាំដូចជាសត្វល្អិត អាកាសធាតុ បញ្ហាតម្លៃទីផ្សារ ។ល។ តាមរយៈការវិវឌ្ឍន៍ដំណាំក្នុងរយៈពេល ០៥ឆ្នាំ (២០១៤-២០១៨) យើងសង្កេតឃើញថាការដាំដុះដំណាំបន្លែមាននិន្នាការថយចុះ និងកើនឡើងតាមបណ្តាលឆ្នាំនីមួយៗ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយមន្ទីរនឹងនៅតែខិតខំប្រឹងប្រែងបន្តជម្រុញការដាំបន្លែឲ្យមានកំណើនក្នុងរង្វង់៣% ក្នុងមួយឆ្នាំៗតាមរយៈការបង្កើនការផ្សព្វផ្សាយ វេទិកាពិគ្រោះយោបល់រវាងកសិករ និងកសិករ បណ្តុះបណ្តាលបច្ចេកទេស និងធ្វើបង្ហាញ។

**ផ្ទៃដីដាំដុះដំណាំបន្លែគ្រប់មុខ ឆ្នាំ២០១៤-២០១៨**




*ក្រាហ្វិក 6. ការវិវឌ្ឍន៍ផ្ទៃដីដាំដុះដំណាំបន្លែគ្រប់មុខ*

## ១.២.៤ ផលិតកម្មដំណាំកសិឧស្សាហកម្ម

### ក. ការពណ៌នា

ខេត្តតាកែវជាខេត្តមួយស្ថិតនៅវាលទំនាបដែលមានលក្ខណៈ អំណោយផលទៅលើដំណាំស្រូវ ពិសេសដំណាំស្រូវប្រាំង ប៉ុន្តែស្ថានភាពភូមិសាស្ត្រមិនអំណោយផលដល់ដំណាំឧស្សាហកម្មឡើយ ចាប់ពីឆ្នាំ ២០១៤ មកផ្ទៃដាំដុះ (ពោតដំឡូងមី និងអំពៅ) មាន ១ ៦២៤ ហិចតា ដែលក្នុងនោះពោតទទួលបានទិន្នផលជាមធ្យម ២ ២៩០ តោន/ហិកតា

ដំឡូងមី ទទួលបានទិន្នផលជាមធ្យម៩តោន/ហិកតា និងអំពៅទទួលបានទិន្នផលមធ្យម ៦២តោន/ហិកតា ប៉ុន្តែមកដល់ឆ្នាំ ២០១៨ ផ្ទៃដីដាំដុះបានកើនដល់ ២ ៤៦២ ហិចតា គឺកើនឡើងចំនួន ៨៣៨ ហិចតា ដែលក្នុងនោះពោតទទួលបានទិន្នផលចំនួន២,៦៦០ តោន/ហិកតា ដំឡូងមី បានចំនួន ១៥ តោន/ហិកតា និង អំពៅទទួលបានចំនួន ៧០ តោន/ហិកតា។

### ខ. ការវិភាគស្វត

| ចំណុចខ្លាំង | ឱកាស |
|---|---|
| - មានគោលនយោបាយជម្រុញការអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម<br>- ផ្ទៃដីដាំដុះធំទូលាយ និងភាគច្រើនអំណោយផលដំណាំ ដំណាំឧស្សាហកម្ម<br>- ផលិតផលកែច្នៃក្នុងស្រុកមានការកើនឡើង<br>- មានស្តង់ដាសុវត្ថិភាពថ្នាក់ជាតិ<br>- ការកាត់បន្ថយការហូរចូលផលិតផលដំណាំបន្ទាប់បន្សំ និងដំណាំឧស្សាហកម្ម ពីប្រទេសជិតខាង<br>- មានបច្ចេកទេសទំនើបក្នុងការដាំដុះ<br>- មានផ្ទៃដី និងវិសាលភាពក្នុងការបង្កើតរោងចក្រកែច្នៃ ចំណីអាហារពីកសិផល។ | - ទាក់ទាញក្រុមហ៊ុនវិនិយោគ<br>- រាជរដ្ឋាភិបាលកម្ពុជាបានឲ្យក្រុមហ៊ុន/វិស័យឯកជន ចុះកិច្ចព្រមព្រៀងទិញផលិតផលកសិកម្មពីប្រជាកសិករដើម្បីលក់ទៅកាន់ប្រទេសផ្សេងៗទៀតតាមរយៈការធ្វើពាណិជ្ជកម្ម<br>- ផ្តល់ឱកាសការងារ និងប្រាក់ចំណូលដល់ប្រជាជន<br>- មានអនុក្រិត្យលេខ ៣៦ អនក្រ.បក ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា និងការគាំទ្ររបស់រាជរដ្ឋាភិបាល លើការជម្រុញឲ្យមានការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា<br>- មានការស្រាវជ្រាវបច្ចេកទេសតាមប្រព័ន្ធពត៌មានវិទ្យា។ |
| **ចំណុចខ្សោយ** | **ការគំរាមកំហែង** |
| - គុណភាពកសិផលនៅមានកម្រិត<br>- តម្លៃកែច្នៃកសិផលមានកម្រិតខ្ពស់<br>- ខ្វះធនធានមនុស្ស និងថវិកាសម្រាប់គាំទ្រ<br>- តម្លៃអគ្គិសនីនៅមានកម្រិតបើធៀបនឹងប្រទេសជិតខាង<br>- ខ្វះរោងចក្រកែច្នៃផលិតផលកសិកម្ម<br>- ចំណេះដឹងពីបច្ចេកទេសកែច្នៃរបស់កសិករនៅមានកំរិត<br>- ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាមិនទាន់បានអនុវត្តឲ្យបានគ្រប់ផលិតផលឧស្សាហកម្ម<br>- ទទួលបានប្រាក់ចំណេញតិចដោយសារតែការចំណាយលើផលិតកម្មច្រើន<br>- ខ្វះការចេញវិញ្ញាបនប័ត្រភូគ្គតាមអនាម័យ។ | - តម្លៃផលិតផលលើទីផ្សារមានការប្រែប្រួលធ្វើឲ្យកសិករមួយចំនួនត្រូវផ្លាស់ប្តូរដាំដំណាំផ្សេងទៀត<br>- មានការបំផ្លាញដំណាំដោយសារតែការប្រែប្រួលអាកាសធាតុមិនទៀងទាត់ដូចជាមានទឹកជំនន់ ខ្យល់ព្យុះ គ្រោះរាំងស្ងួត<br>- ការជ្រៀតចូលផលិតផលកែច្នៃពីប្រទេសជិតខាង នាំឲ្យការកែច្នៃក្នុងស្រុកមានការធ្លាក់ចុះ<br>- ប្រព័ន្ធធារាសាស្ត្រមិនទាន់គ្រប់គ្រាន់។ |

### គ. តារាងស្ថិតិដំណាំកសិឧស្សាហកម្ម

**តារាងទី 5 ÷ ផ្ទៃដីដាំដុះដំណាំឧស្សាហកម្ម (ឆ្នាំ២០១៤-២០១៨)**

| ការពិពណ៌នា | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | អត្រាផ្លាស់ប្តូរ (%) ២០១៤-២០១៨ |
|---|---|---|---|---|---|---|---|
| ពោត | ហិកតា | 350 | 1,133 | 239 | 243 | 276 | -21.14% |
| ដំឡូងមី | ហិកតា | 664 | 1,355 | 1,830 | 1,836 | 1,810 | 172.59% |
| អំពៅ | ហិកតា | 633 | 422 | 350 | 364 | 376 | -40.88% |
| **សរុប** | | **1,650** | **2,910** | **2,419** | **2,443** | **2,462** | **សរុប** |

តាមតារាងខាងលើបង្ហាញថា ផ្ទៃដីដាំដុះមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំអាស្រ័យទៅតាមការប្រែប្រួល អាកាសធាតុក្នុងឆ្នាំនីមួយជាក់ស្តែង ពោតក្នុងឆ្នាំ២០១៤ មានចំនួនប្រមាណ ៣៥០ហិកតា ក្នុងឆ្នាំ២០១៥ មានចំនួនប្រមាណ ១ ១៣៣ហិកតា ក្នុងឆ្នាំ២០១៦ មានចំនួនប្រមាណ ១៣៩ហិកតា ក្នុងឆ្នាំ២០១៧ មានចំនួនប្រមាណ ២៤៣ហិកតា និងក្នុងឆ្នាំ២០១៨ មានចំនួនប្រមាណ ២៧៦ហិកតា។ ចំណែកផ្ទៃដីដាំដំឡូងមីក្នុងឆ្នាំ២០១៤ មានចំនួន ៦៦៤ហិកតា ក្នុងឆ្នាំ២០១៥ មានចំនួន ១ ៣៥៥ហិកតា ក្នុងឆ្នាំ២០១៦ មានចំនួន ១ ៨៣០ហិកតា ក្នុងឆ្នាំ២០១៧ មានចំនួន ១ ៨៣៦ ហិកតា និងក្នុងឆ្នាំ២០១៨ មានចំនួន ១ ៨១០ហិកតា។ រីឯផ្ទៃដីដាំអំពៅវិញក្នុងឆ្នាំ២០១៤ មានចំនួន ៦៣៦ហិកតា ក្នុងឆ្នាំ២០១៥ មានចំនួន ៤២២ហិកតា ក្នុងឆ្នាំ២០១៦ មានចំនួន ៣៥០ហិកតា ក្នុងឆ្នាំ២០១៧ មានចំនួន ៣៦៤ហិកតា និងក្នុងឆ្នាំ២០១៨ មានចំនួន ៣៧៦ហិកតា។

**ផ្ទៃដីដាំដុះដំណាំកសិ-ឧស្សាហកម្ម ឆ្នាំ២០១៤-២០១៨**




*ក្រាហ្វិក 7. ការវិវឌ្ឍន៍ផ្ទៃដីដាំដុះដំណាំកសិ-ឧស្សាហកម្ម*

**តារាងទី 6 ÷ ទិន្នផលដំណាំឧស្សាហកម្ម (ឆ្នាំ២០១៤-២០១៨)**

| ការពិពណ៌នា | ឯកតា (តោន/ហ.ត) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | អត្រាផ្លាស់ប្តូរ (%) ២០១៤-២០១៨ |
|---|---|---|---|---|---|---|---|
| ពោត | តោន/ហិកតា | 2.29 | 2.59 | 2.68 | 2.90 | 2,66 | 16.15% |
| ដំឡូងមី | តោន/ហិកតា | 8.96 | 9.04 | 14.63 | 14.62 | 15 | 67.41% |
| អំពៅ | តោន/ហិកតា | 61.61 | 64.69 | 62.57 | 59.36 | 73 | 18.48% |
| **សរុប** | | **72.86** | **76.32** | **79.88** | **76.88** | **90.66** | |

ចំពោះទិន្នផលដែលបង្ហាញក្នុងឆ្នាំនីមួយៗខាងលើនេះមានការប្រែប្រួលពីមួយឆ្នាំ ទៅមួយឆ្នាំដោយសារកត្តាផ្សេងៗ ដូចបញ្ហាអាកាសធាតុ សត្វល្អិត និងជម្ងឺតាមរដូវកាលជាដើមដែលធ្វើឲ្យមានអត្រាផ្លាស់ប្តូរពីឆ្នាំ (២០១៤ ដល់២០១៨) មានការកើនឡើង១៦,១៥% សម្រាប់ដំណាំពោត ៦៧,៤១% សម្រាប់ដំណាំដំឡូងមី និង៦៧,៤១% សម្រាប់ដំណាំអំពៅ។




*ក្រាហ្វិក 8. ការវិវឌ្ឍន៍ទិន្នផលតាមប្រភេទដំណាំកសិ-ឧស្សាហកម្ម*

### ១.២.៥ ផលិតកម្មសត្វ និងបសុព្យាបាល

#### ក. ការពណ៌នា

ជាទូទៅការចិញ្ចឹមសត្វរបស់ប្រជាកសិករខេត្តតាកែវគឺភាគច្រើនចិញ្ចឹមតាមលក្ខណៈគ្រួសារមានចិញ្ចឹមសត្វ គោ-ក្របី ជ្រូក និងបក្សីសត្វផ្សេងៗ និងមួយចំនួនទៀតចិញ្ចឹមជាលក្ខណៈកសិដ្ឋានខ្នាតតូច និងមធ្យមក្នុងនោះកសិដ្ឋានកំពុងដំណើរការដូចជាកសិដ្ឋានចិញ្ចឹមគោមាន៦កន្លែង, កសិដ្ឋានចិញ្ចឹមជ្រូកចំនួន៦០កន្លែង, កសិដ្ឋានចិញ្ចឹមមាន់មានចំនួន៥៨កន្លែង, និងកសិដ្ឋានចិញ្ចឹមទា១៧២កន្លែង។ ផលិតកម្មសត្វសំខាន់ៗ រួមមានការចិញ្ចឹមគោ-ក្របី, ជ្រូក និងមាន់-ទា។ ក្នុងរយៈពេល០៥ឆ្នាំ ចុងក្រោយនេះការមានការវិវឌ្ឍន៍គួរឲ្យកត់សម្គាល់ដែលអាចធានាបាននូវ ការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុក ហើយមានសត្វមួយចំនួនត្រូវបាននាំចេញក្រៅខេត្តផងដែរ។

#### ខ. ការវិភាគស្ថិត

| **ចំណុចខ្លាំង** | **ឱកាស** |
|---|---|
| - មានការប្រែប្រួលផ្នត់គំនិតពីការចិញ្ចឹមជាលក្ខណៈ គ្រួសារទៅជាការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម<br>- មានអ្នកបច្ចេកទេសថ្នាក់ខេត្តដល់ថ្នាក់មូលដ្ឋាន (ភ្នាក់ងារសុខភាពសត្វភូមិ)<br>- ផលិតផលសត្វអាចផ្គត់ផ្គង់តំរូវការក្នុងខេត្ត និងក្រៅខេត្ត<br>- មានការសហការល្អពីស្ថាប័នពាក់ព័ន្ធទាំងការចិញ្ចឹមសត្វការព្យាបាល និងការពារជម្ងឺសត្វ<br>- កសិករមួយចំនួនធំ បានទទួលចំណេះដឹងស្តីពីបច្ចេកទេសថ្មីៗក្នុងការចិញ្ចឹមសត្វ។ | - មានច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងលិខិតបទដ្ឋានគតិយុត្តិ<br>- មានការលើទឹកចិត្តពីរាជរដ្ឋាភិបាលក្នុងការចិញ្ចឹមសត្វ (មិនយកពន្ធលើការចិញ្ចឹមសត្វ)<br>- មានការគាំទ្រពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្ម សត្វមន្ទីរកសិកម្មអង្គការជាតិ និង អន្តជាតិ<br>- មានដៃគូឯកជនវិនិយោគវិស័យផលិតកម្មសត្វ<br>- មានតម្រូវការទីផ្សារល្អ។ |
| **ចំណុចខ្សោយ** | **ការគំរាមកំហែង** |
| - ថ្លៃដើមផលិតកម្មសត្វខ្ពស់ (ចំណីសត្វ ពូជ វត្ថុធាតុដើមផលិតចំណីសត្វ បសុឱសថ អគ្គីសនី ថ្លៃដឹកជញ្ជូន...)<br>- ការអភិវឌ្ឍបង្កាត់ពូជសត្វនៅមានកំរិត (មាន់ ជ្រូក និងគោ) | - ការបម្រែបម្រួលអាកាសធាតុ (ក្តៅខ្លាំងធ្វើឲ្យសត្វងាប់)<br>- ជំងឺឆ្លងសត្វនៅតែជាបញ្ហាក្នុងផលិតកម្មសត្វ<br>- តំលៃសត្វនៅទីផ្សារគ្មានស្ថេរភាព (ក្រោមតម្លៃផលិត) |

| | |
|---|---|
| - បាត់បង់វាលស្មៅរួម ក្នុងការចិញ្ចឹមសត្វ<br>- ពូជដំណាំចំណីសត្វផ្តល់ជូនកសិករ នៅមានកំរិត<br>- គ្មានមន្ទីរពិសោធន៍ កន្លែងពិនិត្យ និងព្យាបាលសត្វ<br>- ភ្នាក់ងារពេទ្យសត្វភូមិមិនទាន់គោរពការអនុវត្តវិជ្ជាជីវៈរបស់ខ្លួនបាន ពេញលេញ<br>- ការធ្វើវ៉ាក់សាំងមិនបានគ្រប់គ្រាន់ វ៉ាក់សាំងមានតម្លៃថ្លៃ(អុតក្តាម)។ | - គុណភាពនៃការរក្សា និងដឹកជញ្ជូនវ៉ាក់សាំង<br>- ការបង្កើនទីតាំងចិញ្ចឹមសត្វទាំងខ្នាតតូច មធ្យម និងខ្នាតធំ ធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន។ |

### គ. តារាងស្ថិតិផលិតកម្មសត្វក្នុងខេត្តតាកែវ

**តារាងទី 7 ÷ ផលិតកម្មសត្វក្នុងខេត្តតាកែវ (ឆ្នាំ២០១៤-២០១៨)**

| ប្រភេទសត្វ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | អត្រាផ្លាស់ប្តូរ (%) ២០១៤-២០១៨ |
|---|---|---|---|---|---|---|
| គោ (ក្បាល) | 357,499 | 358,129 | 359,189 | 355,736 | 334,173 | -6.52% |
| ក្របី (ក្បាល) | 4,225 | 4,056 | 3,514 | 1,209 | 3,777 | -10.60% |
| ជ្រូក (ក្បាល) | 256,111 | 264,279 | 234,898 | 248,801 | 250,627 | -2.14% |
| មាន់-ទា (ក្បាល) | 2,235,084 | 2,246,418 | 2,346,801 | 2,396,019 | 3,499,613 | 56.57% |
| **សរុប** | **2,852,919** | **2,872,882** | **6,149,826** | **5,854,684** | **4,088,190** | |

ការចិញ្ចឹមសត្វគោ ក្របី ក្នុងរយៈពេលប្រាំឆ្នាំ (២០១៤-២០១៨)កន្លងមកមានការប្រែប្រួលគួឲ្យគាត់សម្គាល់ផងដែរ ជាក់ស្តែងក្នុងឆ្នាំ២០១៤ សត្វគោមានចំនួនប្រមាណ ៣៥៧ ៤៩៩ក្បាល សត្វក្របីមានចំនួនប្រមាណ ៤ ២២៥ក្បាល ក្នុងឆ្នាំ ២០១៥ សត្វគោមានចំនួនប្រមាណ ៣៥៨ ១២៩ក្បាល សត្វក្របីមានចំនួនប្រមាណ ៤ ០៥៦ក្បាល ក្នុងឆ្នាំ២០១៦ សត្វគោមានចំនួនប្រមាណ ៣៥៩ ១៨៩ក្បាល សត្វក្របីមានចំនួនប្រមាណ ៣ ៥១៤ក្បាល ក្នុងឆ្នាំ២០១៧ សត្វគោមានចំនួនប្រមាណ ៣៥៥ ៧៣៦ក្បាល សត្វក្របីមានចំនួនប្រមាណ ១ ២០៩ក្បាល និងឆ្នាំ២០១៨ សត្វគោមានចំនួនប្រមាណ ៣៣៤ ១៧៣ក្បាល សត្វក្របីមានចំនួនប្រមាណ ៣ ៧៧៧ក្បាល។ ការប្រែប្រួលនេះគឺបណ្តាលមកពីកត្តាផ្សេងៗដូចជា កសិករមួយចំនួនផ្លាស់ប្តូរទម្លាប់ដោយប្រើប្រាស់គ្រឿងយន្តជាកំលាំងអូសទាញជំនួសការប្រើប្រាស់កំលាំងសត្វ ការផ្គត់ផ្គង់សាច់សត្វនៅលើទីផ្សារជាដើម។ ចំពោះជ្រូក មាន់-ទា ក៏មានការប្រែប្រួលផងដែរដោយសារតែតម្លៃនៅលើទីផ្សារឡើងចុះមិនទៀង និងជម្ងឺជាដើម។




*ក្រាហ្វិក 9. ការវិវឌ្ឍន៍ផលិតកម្មសត្វគោ ក្របី និងជ្រូក*

ក្រាហ្វិក៩ បង្ហាញថាការចិញ្ចឹមសត្វគោ ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ មានការប្រែប្រួលអត្រាកំណើនជាមធ្យមប្រមាណ -១,៦៤% ដោយបានថយចុះពី ៣៥៧ ៤៩៩ក្បាលនាឆ្នាំ២០១៤ មកត្រឹម ៣៣៤ ១៧៣ក្បាល នៅឆ្នាំ២០១៨។ ចំណែកក្របីក៏មានការប្រែប្រួលអត្រាកំណើនជាមធ្យមប្រមាណ៣២,៣៦%គឺមានចំនួនប្រមាណ ៤ ២២៥ក្បាល ក្នុងឆ្នាំ២០១៤ ថយដល់ ៣ ៧៧៧ក្បាល នៅឆ្នាំ២០១៨។ ការប្រែប្រួលផលិតកម្មគោ-ក្របីនេះ គឺបណ្ដាលមកពីការថយចុះកម្លាំងអូសទាញ ព្រោះកសិករបានបោះបង់ការភ្ជួររាស់ដោយប្រើកម្លាំងគោ-ក្របី មកប្រើប្រាស់គ្រឿងយន្តវិញកង្វះ កម្លាំងពលកម្មការធ្វើចំណាកស្រុកខ្វះខាតប្រភពទឹក និងវាលស្មៅសម្រាប់ការចិញ្ចឹមគោ-ក្របី។

ការចិញ្ចឹមជ្រូកមានការប្រែប្រួលថយចុះក្នុងរយៈពេល ៥ឆ្នាំ ចុងក្រោយនេះពោលគឺផលិតកម្មជ្រូកបានថយចុះប្រមាណ -០,៣២% ដោយថយពី ២៥៦ ១១១ក្បាល នៅឆ្នាំ២០១៤ មកត្រឹម ២៥០ ៦២៧ក្បាល នៅឆ្នាំ២០១៨។ ការថយចុះនេះ គឺដោយសារតម្លៃនៅលើទីផ្សារមានការប្រែប្រួលមិនទៀង និងកត្តាចង្រៃដោយសារជម្ងឺ ។

ការចិញ្ចឹមសត្វស្លាបជាលក្ខណៈគ្រួសារ ក្នុងរយៈពេល ០៥ឆ្នាំ (ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨) មានការប្រែប្រួលកើនឡើងប្រមាណ ១៣,២៨% គឺបានកើនឡើងពី ២ ២៣៥ ០៨៤ក្បាល ក្នុងឆ្នាំ២០១៤ មកដល់ ៣ ៤៩៩ ៦១៣ក្បាលក្នុងឆ្នាំ២០១៨។ការកើនឡើងក្នុងរយៈពេលប្រាំឆ្នាំនេះមានអត្រាខ្ពស់គួរឲ្យគាត់សម្គាល់ហេតុដូចនេះមន្ទីរក៏នៅតែបន្តជម្រុញកំណើនពីមួយឆ្នាំទៅមួយឆ្នាំបន្ថែមទៀតដោយបន្តផ្សព្វផ្សាយអំពីបច្ចេកទេស និង ពង្រឹងបន្ថែមទៀតដល់កសិករអំពីការយល់ដឹងនូវ បច្ចេកទេសចិញ្ចឹមសត្វតាមគោលការណ៍ជីវសុវត្ថិភាព ដែលពិតជារួមចំណែក យ៉ាងសំខាន់ក្នុងការទប់ស្កាត់ជំងឺឆ្លងសត្វ ជំងឺឆ្លងពីសត្វទៅមនុស្ស និងពីមនុស្សទៅសត្វ ដែលធ្វើឲ្យអត្រាសត្វឈឺ-ងាប់ មានការថយចុះ។ ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វត្រូវបានយកចិត្តទុកដាក់អនុវត្តចាប់ពីនៅកសិដ្ឋាន កន្លែងពិឃាតដល់ទីផ្សារដើម្បីការពារដល់សុខភាពសាធារណះ។

**ផលិតកម្មសត្វមាន់-ទា ឆ្នាំ២០១៤-២០១៨**




*ក្រាហ្វិក 10. ការវិវឌ្ឍន៍ផលិតកម្មសត្វមាន់-ទា*

ការផ្សព្វផ្សាយបច្ចេកទេសដល់កសិករត្រូវបានអនុវត្តយ៉ាងសកម្ម និងមានប្រសិទ្ធភាព ជាលទ្ធផលស្ថិតិ សត្វមាន់ និងសត្វទាមានការកើនឡើងគួរឲ្យកត់សម្គាល់ ដោយមានការរីកចម្រើនជាបណ្តើរៗនូវកសិដ្ឋានចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មដែលអាចបំពេញតម្រូវការសាច់ក្នុងខេត្ត និងកាត់បន្ថយការនាំចូលពីក្រៅខេត្ត។

ទន្ទឹមនឹងការអភិវឌ្ឍន៍លើផ្នែកចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់លាមកសត្វ ក៏ត្រូវបានយកចិត្តទុកដាក់ផងដែរ តាមរយៈការអប់រំណែនាំផ្សព្វផ្សាយ និងជ្រើសរើសកសិករធ្វើបង្ហាញដោយសាងសង់ឡជីវឧស្ម័ន តាមគ្រួសារ។ ជាលទ្ធផលបានសាងសង់ឡជីវឧស្ម័នសរុបចំនួន ៥ ១២៨ ឡនៅឆ្នាំ ២០១៨។

ការកែលម្អពូជ និងកែលម្អចំណីសត្វ បាននឹងកំពុងមានការចាប់អារម្មណ៍ពីប្រជាកសិករជាបណ្តើរៗ ព្រោះកសិករកាន់តែមានការយល់ដឹងច្រើនពីសារសំខាន់ក្នុងការជ្រើសរើសពូជ បង្កាត់ពូជ និងកែលម្អគុណភាពចំណីសត្វ ដែលជាកត្តាចំបងក្នុងផលិតកម្មសត្វឲ្យទទួលបានទិន្នផលខ្ពស់ លូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារកាន់តែប្រសើរឡើង។

### ១.២.៦ ផ្នែកផ្សព្វផ្សាយកសិកម្ម

#### ក. ការពណ៌នា

ឆ្លងតាមការអនុវត្តកន្លងមកមន្ត្រីផ្សព្វផ្សាយកសិកម្មកាន់តែមានបទពិសោធន៍ល្អ ប្រកបដោយសមត្ថភាពខ្ពស់ដែលធ្វើឲ្យកសិករកាន់តែមានជំនឿទុកចិត្តលើបច្ចេកទេសប្រើប្រាស់ពូជស្រូវថ្មី ផ្តល់ទិន្នផលខ្ពស់ហើយកសិករមួយចំនួនធំបានយកទៅអនុវត្តធ្វើឲ្យផលិតកម្មកសិកម្មមានការប្រែប្រួលគួរឱ្យកត់សម្គាល់។ លទ្ធផលដែលសម្រេចបានកន្លងមករួមមាន÷

-បានផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករតាមមូលដ្ឋាន

-បណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិឲ្យក្លាយជាភ្នាក់ងារផ្សព្វផ្សាយភូមិ/ឃុំ

-ត្រួតពិនិត្យ និងកែសម្រួលឡើងវិញនូវវិធីសាស្ត្រផ្សព្វផ្សាយដើម្បី ធានាឲ្យមានប្រសិទ្ធភាពនៃការផ្សព្វផ្សាយបច្ចេកទេសតាមក្បួនខ្នាតដល់គ្រប់ស្រទាប់កសិករ វិធីសាស្ត្របណ្តុះបណ្តាលតាមរបៀបសាលារៀនស្រែ-ចំការកសិករ វិធីសាស្ត្រធ្វើស្រែចំការបង្ហាញ ការផ្សព្វផ្សាយដោយប្រើរូបគំនូរផ្ទាំងធំៗ ខិតប័ណ្ណ កូនសៀវភៅបច្ចេកទេស ការផ្សព្វផ្សាយតាមវិទ្យុខេត្ត និងការផ្សព្វផ្សាយតាមវេទិកាអ្នកបច្ចេកទេស និងកសិករ ។ល។

-បានយកចិត្តទុកដាក់ផ្សព្វផ្សាយបច្ចេកទេសមួយចំនួន ជូនកសិករដូចជាការធ្វើប្រពលវប្បកម្មដំណាំស្រូវពូជផ្តល់ទិន្នផលខ្ពស់ពូជដែលមានអាយុកាលខ្លី ធន់និងការប្រែប្រួលអាកាសធាតុ

-វាយតម្លៃប្រសិទ្ធភាពនៃការផ្សព្វផ្សាយការទទួលយករបស់កសិករ និងការងារសាយភាយ (PIA) នៅតាមភូមិសាស្ត្រមួយចំនួនក្នុងខេត្ត

-ប្រមូលពត៌មានកសិកដ្ឋានចំរុះ

-បានពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយការិយាល័យជំនាញ និងមន្ទីរពាក់ព័ន្ធអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ និងដៃគូអភិវឌ្ឍន៍ទាំងអស់លើដំណើរការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម។

#### ខ. ការវិភាគស្វត

| ចំណុចខ្លាំង | ឱកាស |
|---|---|
| - មន្ទីរកសិកម្មមានរចនាសម្ព័ន្ធសម្រាប់បម្រើសេវាផ្សព្វផ្សាយកសិកម្ម (អនុការិយាល័យជំនាញ និងខណ្ឌទាំងពីរ សហគមន៍ | - មានច្បាប់ស្តីពីការរៀបចំស្ថាប័នគតិយុត្តិ<br>- មានឯកសារគោលការណ៍ណែនាំអំពីមធ្យោបាយ វិធីសាស្ត្រ |

| | |
|---|---|
| កសិកម្ម កសិករ...)<br>- មានភ្នាក់ងារផ្សព្វផ្សាយឃុំ ភ្នាក់ងារផ្សព្វផ្សាយភូមិ និងកសិករគម្រូ ឬកសិករឆ្នើម និងគ្រូបង្គោលដែលជាកសិករនៅកម្រិតមូលដ្ឋាន<br>- មានឯកសារផ្សព្វផ្សាយកសិកម្ម សម្រាប់ផ្តល់ភាពងាយស្រួលដល់កសិករសំបូរបែប<br>- មានទិរង់សម្រាប់ផ្តល់សេវាផ្សព្វផ្សាយកសិកម្ម តាមប្រពន្ធ័ទូរគមនាគមន៍ (អាយស៊ីតធី)<br>- កសិករមានជំនឿលើបច្ចេកទេសទំនើបថ្មីៗ<br>- មានការសហការល្អជាមួយមន្ត្រីជំនាញពាក់ព័ន្ធ។ | ឧបករណ៍ រូបភាពនានា...<br>- ទទួលបានពត៌មានផ្សព្វផ្សាយកសិកម្មពី មនុស្ស ឬស្ថាប់ន័ដែលផ្តល់សេវាផ្សព្វផ្សាយ (កសិករ ភ្នាក់ងារផ្សព្វផ្សាយឃុំ សហគមន៍កសិកម្ម មន្ត្រីមន្ទីរកសិកម្មខេត្ត មន្ត្រីអង្គការ ឬ ដៃគូអភិវឌ្ឍន៍នានា សកលវិទ្យាល័យ ស្ថាបន័ស្រាវជ្រាវ)<br>- ពត៌មានផ្សព្វផ្សាយកសិកម្មបានទទួលពីមធ្យោបាយដូចជា (បណ្ណាល័យនៅឃុំ/ភូមិ ការធ្វើបង្ហាញកសិករ សាលារៀនស្រែកសិករ សេវាផ្តល់ពត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិជន បណ្តុះបណ្តាលកសិករ ប្រពន្ធ័ផ្សព្វផ្សាយសាធារណៈ (គេហទំព័រផ្សព្វផ្សាយកសិកម្ម) ក្តារពត៌មានទីផ្សារនៅតាមបណ្តុំអាជីវកម្មភូមិ/ឃុំ និងវេទិកាកសិករ<br>- មានគោលនយោបាយផ្សព្វផ្សាយកសិកម្ម<br>- មានការគាំទ្រពីដៃគូ អភិវឌ្ឍន៍មានការយកចិត្តទុកដាក់របស់ក្រសួងកសិកម្ម និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។ |
| **ចំណុចខ្សោយ** | **ការគំរាមកំហែង** |
| - មន្ត្រីផ្សព្វផ្សាយកសិកម្ម មិនទាន់បានទទួលវគ្គបណ្តុះបណ្តាលជំនាញអាយស៊ីធីឱ្យមានសមត្ថភាពគ្រប់គ្រាន់<br>- ខ្វះមន្ត្រីធ្វើអង្កេតជាប្រចាំជាមួយផ្នែកពាក់ពន្ធ័ផ្សេងៗលើសេវាផ្សព្វផ្សាយកសិកម្ម<br>- ថវិកាមិនបានគ្រោងគ្រប់គ្រាន់ឱ្យស្របនឹងគោលការណ៍ណែនាំពីសេវាផ្សព្វផ្សាយកសិកម្ម<br>- ការរៀបចំផែនការអនុត្តការងារសហការរវាងមន្ទីរ និងដៃគូអភិវឌ្ឍន៍ អង្គការ និងសេវាឯកជននៅមានកម្រិត<br>- ខ្វះខាតចំនួនមន្ត្រីដើម្បីអនុវត្តការងារផ្សព្វផ្សាយកសិកម្ម<br>- កសិករមួយចំនួនតូចពុំទាន់យកចិត្តទុកដាក់លើការងារផ្សព្វផ្សាយកសិកម្ម។ | - គ្មានឧបករណ៍នៃប្រពន្ធ័ត្រួតពិនិត្យវាយតម្លៃ និងសិក្សាដកស្រង់បទពិសោធន៍អំពីប្រសិទ្ធភាពសេវាផ្សព្វផ្សាយកសិកម្ម<br>- ការធ្វើបច្ចុប្បន្នភាពបច្ចេកទេសមិនទាន់ពេលវេលាលើ សេវាផ្សព្វផ្សាយកសិកម្ម<br>- ទំហំថវិកាមានកំរិតមិនឆ្លើយតបនឹងសេវាផ្សព្វផ្សាយកសិកម្ម<br>- ទីផ្សារលក់ផលិតផលនៅមានកម្រិត<br>- បច្ចេកទេសកសិកម្មមួយចំនួនត្រូវប្រើទុនច្រើន និងចំណាយប្រតិបត្តិការច្រើន<br>- មិនមានស្ថេរភាពទីផ្សារ។ |

## ១.២.៧ ការងារសហគមន៍កសិកម្ម

### ក. ការពណ៌នា

ការរៀបចំ និងបង្កើតសហគមន៍ជាយុទ្ធសាស្ត្រចំបងរបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ ដែលតែងតែយកចិត្តទុកដាក់ខ្ពស់ ដើម្បីជួយគាំទ្រកសិករឲ្យទទួលបានឱកាសពីសេវាបច្ចេកទេសកសិកម្ម ផ្តល់ដោយស្ថាប័នពាក់ព័ន្ធអង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

លើសពីនេះទៀតសហគមន៍អាចជួយដល់សមាជិកសហគមន៍ជាពិសេសកសិករក្រីក្រងាយរងគ្រោះ ទទួលបានអំណាចចរចាតម្លៃជាមួយឈ្មួញគ្រប់ប្រភេទអាចកាត់បន្ថយថ្លៃដើមក្នុងការផលិតកម្មអាចផលិតបាននូវកសិផល ដែលទីផ្សារត្រូវការ ទទួលបានឱកាសទីផ្សារ និងពង្រីកទីផ្សារកសិផល និងអាចលើកកម្ពស់គុណភាពកសិផលផលិតផលតាមតម្រូវការទីផ្សារ ។

ការបង្កើតសហគមន៍កសិកម្មមានការវិវឌ្ឍន៍ល្អ ស្របតាមគោលការណ៍ និងគោលនយោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្តែងនៅឆ្នាំ២០១៤ មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានបង្កើតសហគមន៍ថ្មីបានចំនួន ១៨ ក្នុងឆ្នាំ២០១៥ មានចំនួន១៨សហគមន៍ ក្នុងឆ្នាំ២០១៦ និងក្នុងឆ្នាំ២០១៧ មានចំនួន៧សហគមន៍ និងក្នុងឆ្នាំ២០១៨ មានចំនួន៦១សហគមន៍។ យើងសង្កេតឃើញថាក្នុងរយៈពេល៥ឆ្នាំ (២០១៤-២០១៨)សហគមន៍កសិកម្មដែលបានបង្កើតឡើងថ្មីមានចំនួនសរុបចំនួន ១១១សហគមន៍។

### ខ. ការវិភាគស្វត

| ចំណុចខ្លាំង | ឱកាស |
|---|---|
| - មានការិយាល័យទទួលបន្ទុកសហគមន៍កសិកម្ម និងមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់<br>- មានសាមគ្គីភាព និងសហការល្អក្នុងការិយាល័យ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់<br>- មានការទទួលស្គាល់ និងចុះបញ្ជីពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- មានសមាជិកចូលរួម និងជាវភាគហ៊ុន<br>- មានកិច្ចសន្យាផលិតកម្មរវាងសហគមន៍កសិកម្ម និងវិស័យឯកជន<br>- មានការបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗ ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រីការិយាល័យ និងថ្នាក់ដឹកនាំ សហគមន៍កសិកម្ម<br>- មានការរៀបចំមហាសន្និបាត និងអង្កេតវាយតម្លៃសកម្មភាពសហគមន៍កសិកម្មរៀងរាល់ឆ្នាំដើម្បីពង្រឹងការគ្រប់គ្រងសហគមន៍ឱ្យបានរឹងមាំ។ | - មានច្បាប់ស្តីពីសហគមន៍កសិកម្ម និងប្រកាសនានាស្តីពីការរៀបចំ និងដំណើរការសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម<br>- មានការលើកទឹកចិត្ត និងមានការគាំទ្រពីថ្នាក់ដឹកនាំក្រសួង និងថ្នាក់ដឹកនាំមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត ព្រមទាំងគម្រោងអភិវឌ្ឍន៍នានា<br>- មានការគាំទ្រពីគ្រប់មជ្ឈដ្ឋាន ទាំងកសិករ អាជីវករ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ អង្គការក្រៅរដ្ឋាភិបាល ក្នុងការរបៀបចំនិងដំណើរការ សហគមន៍កសិកម្ម<br>- មានទីផ្សារផលិតផលកសិកម្មរបស់សហគមន៍កសិកម្ម។ |
| **ចំណុចខ្សោយ** | **ការគំរាមកំហែង** |
| - កង្វះមន្ត្រីក្នុងការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម នាំឱ្យការអនុវត្តការងារមិនបានគ្រប់ជ្រុងជ្រោយ ពិសេសការត្រួតពិនិត្យសហគមន៍កសិកម្មតាមមូលដ្ឋាន<br>- កម្មវិធីបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពីការងារដឹកនាំ និងគ្រប់គ្រងសហគមន៍កសិកម្ម មានតិចតួច<br>- សហគមន៍កសិកម្មមួយចំនួនមានទំហំតូចដែលសមាជិក ភាគច្រើនជាកសិករមានជីវភាពក្រីក្រ ឬមធ្យមធ្វើឱ្យដើមទុនសរុបរបស់សហគមន៍ នៅមានកម្រិតទាប<br>- កង្វះសមត្ថភាព ការយល់ដឹង និងភាពជឿជាក់នាំឱ្យសហគមន៍កសិកម្មមួយចំនួន មានភាពអសកម្ម<br>- កង្វះកិច្ចសហការរវាងសហគមន៍កសិកម្ម និងវិស័យឯកជន ឬក្នុង | - ការប្រែប្រួលអាកាសធាតុជាឧបសគ្គចម្បងក្នុងការផលិតនូវកសិផលប្រកបដោយគុណភាព<br>- តម្រូវការពូជដំណាំដែលបន្សុាំនឹងការប្រែប្រួលអាកាសធាតុការប្រើធាតុចូលកសិកម្មដែលមានតម្លៃថ្លៃ បង្កជាឧបសគ្គក្នុងការប្រកួតប្រជែងក្នុងទីផ្សារ<br>- កិច្ចសន្យាទិញលក់ផលិតផលរបស់សហគមន៍មិនទាន់មានប្រសិទ្ធភាព<br>- ការប្រកួតប្រជែងក្នុងទីផ្សារតម្លៃកសិផលមិនមានស្ថេរភាពធ្វើឱ្យសហគមន៍កសិកម្មមួយចំនួនបោះបង់ការផលិតដោយសារដើមទុនតិចមិនអាចប្រកួតប្រជែងបាន។ |

| | |
|---|---|
| មុខរបរជំនួញនៅមានកំរិតទាបនៅឡើយ<br>- កង្វះធនធានហិរញ្ញវត្ថុសម្រាប់ពង្រីកមុខរបរជំនួញ ដែលសហគមន៍មួយចំនួនត្រូវស្វែងរកប្រាក់កម្ចីពីធនាគារឯកជន ឬ គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗក្នុងតម្លៃការប្រាក់ខ្ពស់។ | |

### គ. តារាងស្ថិតិសហគមន៍កសិកម្មក្នុងខេត្តតាកែវ (២០១៤-២០១៨)

**តារាងទី 8 ÷ ការងារបង្កើតសហគមន៍កសិកម្មក្នុងខេត្តតាកែវ (ឆ្នាំ២០១៤-២០១៨)**

| ប្រភេទសកម្មភាព | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | អត្រាផ្លាស់ប្តូរ(%) ២០១៤-២០១៨ |
|---|---|---|---|---|---|---|---|
| សហគមន៍កសិកម្មបង្កើតថ្មី | សហគមន៍ | 18 | 18 | 7 | 7 | 61 | 238.88% |
| **សរុប** | **សហគមន៍** | **18** | **18** | **7** | **7** | **61** | |

ការរៀបចំបង្កើតសហគមន៍ជាការចាំបាច់មួយផងដែរសំរាប់អភិវឌ្ឍ វិស័យកសិកម្មឲ្យមានការរីកចំរើនហេតុដូចនេះ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក៏បានយកចិត្តទុកដាក់លើការបង្កើតសហគមន៍ថ្មីបន្ថែមទៀត។ ក្នុងការបង្កើតសហគមន៍ថ្មីនេះយើងសង្កេតឃើញថា ឆ្នាំ២០១៨ មានរហូតដល់៦១សហគមន៍ដែលជាអត្រាខ្ពស់បំផុតសម្រាប់រយៈពេល ០៥ឆ្នាំកន្លងមកនេះ មូលហេតុនៃការកើនឡើងបែបនេះគឺដោយសារតែមានការគាំទ្រពីគម្រោងក្រៅរដ្ឋាភិបាល។




*ក្រាហ្វិក 11. ការវិវឌ្ឍន៍នៃការបង្កើតសហគមន៍កសិកម្ម*

## ១.២.៨ ផ្នែកគ្រឿងយន្តកសិកម្ម

### ក. ការពណ៌នា

ក្នុងទិសដៅជម្រុញផលិតភាពកសិកម្មឲ្យបានកាន់តែរីកចម្រើនទាំងបរិមាណ និងគុណភាពការបញ្ចូលបច្ចេកវិទ្យាយន្តូបនីយកម្មកសិកម្មទៅក្នុងផលិតកម្មកសិកម្មគឺជាសកម្មភាពអាទិភាពដែលត្រូវយកចិត្តទុកដាក់ជាពិសេសក្នុងដំណើរការ

ភ្ជួររាស់ដឹកជញ្ជូន ច្រូតកាត់ បោកបែន និងការសម្ងួត។ល។ មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានសង្កេតឃើញថានៅដំណាក់កាលចុងក្រោយនេះកសិករចាប់ផ្តើមនិយមប្រើប្រាស់គ្រឿងយន្ត និងឧបករណ៍កសិកម្មខ្នាតតូច និងមធ្យមជាបណ្តើរៗហើយ។ ម្យ៉ាងទៀតសិប្បកម្មផលិតឧបករណ៍កសិកម្ម និងសាខាក្រុមហ៊ុនលក់គ្រឿងយន្តកសិកម្មក៏មានច្រើននៅតាមបណ្តាទីផ្សារនានាក្នុងខេត្ត។

កំណើន នៃការប្រើប្រាស់គ្រឿងយន្តមានការកើនឡើងជាបន្តបន្ទាប់ក្នុង១ឆ្នាំៗ ដែលជាហេតុធ្វើឲ្យកសិករមានភាពងាយស្រួលជាងមុនក្នុងការងារបង្កបង្កើនផល។

**ខ. ការវិភាគស្វត**

| **ចំណុចខ្លាំង** | **ឱកាស** |
|---|---|
| - ការប្រើប្រាស់គ្រឿងយន្តកសិកម្មមានការកើនឡើង<br>- កសិករនិយមប្រើប្រាស់គ្រឿងយន្ត និងឧបករណ៍កសិកម្មក្នុងខ្សែច្រវាក់ផលិតកម្មរបស់ពួកគេ<br>- មានសេវាកម្មជួលភ្ជួររាស់ដោយគ្រឿងយន្តកសិកម្មដល់ដីស្រែកសិករ<br>- ផ្ទៃដីធំអំណោយផលដល់ការប្រើប្រាស់គ្រឿងយន្តកសិកម្ម<br>- កសិករមួយចំនួនចេះកែច្នៃឧបករណ៍ប្រើប្រាស់ក្នុងវិស័យកសិកម្ម<br>- ងាយស្រួលក្នុងការទទួលបានសេវាកម្មគ្រឿងយន្តកសិកម្មតាមបណ្តាស្រុក និងឃុំសម្រាប់បម្រើការងារផលិតកម្ម<br>- មានសិប្បកម្មតម្លើងគ្រឿងយន្តកសិកម្មកែច្នៃសម្រាប់បម្រើក្នុងផលិតកម្មតាមបណ្តាឃុំ និងស្រុក។ | - រាជរដ្ឋាភិបាលមានគោលនយោបាយនាំចូលគ្រឿងយន្តកសិកម្មដោយគ្មានការបង់ពន្ធ<br>- ឆ្លើយតបទៅនឹងការប្រមូលទិន្នផលស្រូវ និងផ្គត់ផ្គង់អង្ករទាន់ពេលវេលាសម្រាប់តម្រូវការទីផ្សារនាំចេញ<br>- មានសេវាកម្មបង់រំលោះគ្រឿងយន្តកសិកម្ម<br>- មានការជម្រុញលើទឹកចិត្តលើការស្រាវជ្រាវ និងកែច្នៃឧបករណ៍គ្រឿងយន្តកសិកម្ម<br>- មានសេវាបង់រំលោះគ្រឿងយន្តកសិកម្មសម្រាប់កសិករ<br>- គ្រឿងយន្តកសិកម្មរួមចំណែកពន្លឿននូវល្បឿនផលិត។ |
| **ចំណុចខ្សោយ** | **ការគំរាមកំហែង** |
| - ពុំទាន់មានកិច្ចសហការល្អជាមួយសិប្បកម្មកែច្នៃគ្រឿងយន្តកសិកម្ម និងអ្នកប្រើប្រាស់<br>- កង្វះការស្រាវជ្រាវផលិត និងកែច្នៃឧបករណ៍គ្រឿងយន្តកសិកម្ម<br>- ខ្វះការផ្សព្វផ្សាយបច្ចេកទេសដល់ប្រជាពលរដ្ឋ<br>- មិនមានរោងជាង និងសេវាជួសជុលគ្រឿងយន្តកសិកម្មនៅតាមសហគមន៍<br>- ដីស្រែរបស់កសិករពុំទាន់មានប្រព័ន្ធភ្លឺស្រែ និងផ្លូវសម្រាប់ចេញចូលបានល្អ<br>- ខ្វះធនធានមនុស្សលើជំនាញគ្រឿងយន្តកសិកម្ម។ | - គ្រឿងយន្តមួយចំនួនយកមកលក់ មិនទាន់សាកល្បង និងធ្វើការផ្សព្វផ្សាយដល់កសិករពីគុណភាព និងប្រសិទ្ធភាពការប្រើប្រាស់<br>- កង្វះខាតច្បាប់គ្រប់គ្រងគ្រឿងយន្តកសិកម្មនាំឲ្យមានការនាំចូលខុសច្បាប់ ការក្លែងបន្លំគុណភាពប្រើប្រាស់ឆាប់ខូច<br>- សេវាកម្មជួលជុលគ្រឿងយន្តកសិកម្មមិនបានទូលំទូលាយ និងមានតម្លៃថ្លៃ<br>- អត្រាការប្រាក់ឥណទានលើការបង់រំលោះគ្រឿងយន្តកសិកម្មនៅមានកំរិតខ្ពស់<br>- មានការបង់ពន្ធលើការនាំចូលគ្រឿងបន្លាស់គ្រឿងយន្តកសិកម្ម។ |

### គ. តារាងស្ថិតិគ្រឿងយន្តកសិកម្មក្នុងខេត្តតាកែវ

**តារាងទី 9 ៖ ការប្រើប្រាស់គ្រឿងយន្តកសិកម្ម (ឆ្នាំ២០១៤-២០១៨)**

| ការពណ៌នា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | អត្រាផ្លាស់ប្តូរ (%) ២០១៤-២០១៨ |
|---|---|---|---|---|---|---|
| ត្រាក់ទ័រ | 440 | 568 | 651 | 628 | 858 | 95% |
| គោយន្ត | 14,124 | 17,132 | 17,007 | 18,908 | 22,734 | 60.96% |
| ម៉ាស៊ីនច្រូត | 1,294 | 1,089 | 678 | 617 | 901 | -30.37% |
| ម៉ាស៊ីនបោកស្រូវ | 607 | 533 | 305 | 243 | 581 | -4.28% |
| ម៉ាស៊ីនបូមទឹក | 45,744 | 49,703 | 42,856 | 43,790 | 57,639 | 26.10% |
| ម៉ាស៊ីនសំងួតស្រូវ | 3 | 20 | 17 | 17 | 17 | 466.66% |
| **សរុប** | **62,212** | **69,045** | **61,514** | **64,203** | **81,829** | |

តាមរយៈតារាងខាងលើបង្ហាញថាក្នុងត្រាក់ទ័រឆ្នាំ២០១៤ មានចំនួនប្រមាណ ៤៤០គ្រឿង និងកើនដល់ ៨៥៨គ្រឿងក្នុងឆ្នាំ២០១៨។ គោយន្តមានចំនួនប្រមាណ ១៤ ១២៤គ្រឿងក្នុងឆ្នាំ២០១៤ កើនដល់ ២២ ៧៣៤គ្រឿងក្នុងឆ្នាំ២០១៨ ។ ម៉ាស៊ីនបូមទឹកមានចំនួនប្រមាណ ៤៥ ៧៤៤គ្រឿងក្នុងឆ្នាំ២០១៤ កើនដល់ ៥៧ ៦៣៩គ្រឿងក្នុងឆ្នាំ២០១៨។ ម៉ាស៊ីនសំងួតស្រូវមានចំនួនប្រមាណ៣គ្រឿងក្នុងឆ្នាំ២០១៤ កើនដល់ប្រមាណ ១៧គ្រឿងក្នុងឆ្នាំ២០១៨។ ចំណែកឯម៉ាស៊ីនច្រូតនិងម៉ាស៊ីនបោកស្រូវមានការថយចុះដោយម៉ាស៊ីនច្រូតក្នុងឆ្នាំ២០១៤ មានប្រមាណ ១ ២៩៤គ្រឿង ថយមកត្រឹមប្រមាណ ៩០១គ្រឿងក្នុងឆ្នាំ២០១៨។ ឯម៉ាស៊ីនបោកស្រូវក្នុងឆ្នាំ២០១៤ មានប្រមាណ៦០៧គ្រឿង ថយមកត្រឹមប្រមាណ៥៨១គ្រឿងក្នុងឆ្នាំ២០១៨។

**ការប្រើប្រាស់គ្រឿងយន្តកសិកម្ម (ឆ្នាំ២០១៤-២០១៨)**




*ក្រាហ្វិក 12. ការវិវឌ្ឍន៍នៃគ្រឿងយន្តកសិកម្ម*

## ១.២.៩ ផ្នែកខណ្ឌរដ្ឋបាលជលផល

### ក. ការពណ៌នា

នៅក្នុងខេត្តតាកែវមានសហគមន៍នេសាទចំនួន ១៨សហគមន៍ ដែលក្នុងនោះមាន ១០សហគមន៍ បានចុះបញ្ជីរួចរាល់ហើយ និង៨សហគមន៍មិនទាន់ចុះបញ្ជី ហើយខេត្តនឹងបន្តកិច្ចការចុះបញ្ជីសហគមន៍នៅឆ្នាំបន្ទាប់ៗទៀត។ ចំពោះ

បរិមាណផលត្រីមានការថយចុះ និងកើនឡើងទៅតាមឆ្នាំនីមួយៗអាស្រ័យទៅតាមទំហំទឹកដោយសារមានបរិមាណផលត្រីមិនទាន់មានការកើនឡើងគួជាទីពេញចិត្តនៅឡើយទេ ដូច្នេះខេត្តនឹងបន្តជម្រុញវារីវប្បកម្មបន្ថែមទៀត ដើម្បីទទួលបានបរិមាណផលត្រីគ្រប់គ្រាន់សំរាប់ហូបចុកក្នុងខេត្ត ព្រមទាំងនាំចេញទៅក្រៅខេត្ត។ ដោយឡែកការចិញ្ចឹមត្រីក្នុងស្រែមានចំនួន ២២៥ គ្រួសារនៅឆ្នាំ ២០១៤ និងបានបោះបង់ចោលទាំងស្រុងនៅឆ្នាំ ២០១៥ ការបោះបង់នេះដោយសារមានគ្រោះរាំងស្ងួតអូសបន្លាយយូរដែលធ្វើឲ្យមានការពិបាកក្នុងការចិញ្ចឹមហើយខេត្ត នឹងបន្តជម្រុញការចិញ្ចឹមត្រីក្នុងស្រែនៅតំបន់ដែលមានប្រភពទឹកគ្រប់គ្រាន់ដើម្បីរុញកំណើនបរិមាណផលត្រី និងវារីវប្បកម្ម។ ចំពោះការជីកស្រះចិញ្ចឹមត្រីមានចំនួន៨ ១៣៥ស្រះត្រី ក្នុងឆ្នាំ២០១៤ និងកើនដល់ត្រឹម ៩ ១៨០ស្រះត្រី នៅឆ្នាំ២០១៨ គឺមានការកើនឡើងចំនួន ១ ០៤៥ស្រះ ដើម្បីជម្រុញកំណើនស្រះចិញ្ចឹមត្រី ខេត្តមានផែនការចែកពូជត្រីដល់កសិករដើម្បី ជំរុញកំណើនស្រះត្រីឲ្យបានកើនពីមួយឆ្នាំទៅមួយឆ្នាំ។ នៅពេលកន្លងមកដើម្បីរួមចំណែកអភិវឌ្ឍន៍វិស័យជលផល ក្នុងខេត្តខំណ្ឌរដ្ឋបាលជលផលបានសហការណ៍ជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដូចជាអង្គការ BIRDLIFE អភិរក្ស សត្វស្លាប, អង្គការចំរើនជាតិខ្មែរ CCK និងអង្គការ UNDP ការងារអភិរក្ស។

### ខ. ការវិភាគស្ថានភាព

| ចំណុចខ្លាំង | ឱកាស |
| --- | --- |
| - មានប្រភពទឹកទន្លេ បឹង ព្រែក ស្ទឹង ជាអំណោយផលល្អដល់ការនេសាទ និងការអភិវឌ្ឍន៍វារីវប្បកម្ម<br>- បានរៀបចំសហគមន៍នេសាទ ស្របតាមការកែទម្រង់របស់រាជរដ្ឋាភិបាល<br>- បានបង្កើតកន្លែងអភិរក្សត្រីមេពូជនៅតាមបណ្តាសហគមន៍នេសាទ និងបានបង្កើតស្រះជម្រកត្រី សហគមន៍<br>- ការអភិវឌ្ឍន៍វារីវប្បកម្មតាមរយៈអ្នកផលិតខ្នាតតូច ខ្នាត មធ្យម និងខ្នាតធំស្របទៅតាមផែនការយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍វារីវប្បកម្ម<br>- ការអនុវត្តលើវិធានការគ្រប់គ្រងធនធានធម្មជាតិរបស់ស្ថាប័នជំនាញនិងមានកិច្ចសហការពីអាជ្ញាធរដែនដី និងអ្នកពាក់ពន្ធ័<br>- សហគមន៍នេសាទមានរចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួនតាមរយៈមហាសន្និបាតបោះឆ្នោតចេញពីប្រជានេសាទព្ធ ហើយបានដើរតួនាទីសំខាន់លើការងារសហគ្រប់គ្រងធនធានជលផលនៅតាមមូលដ្ឋាន<br>- គណៈកម្មការ និងសមាជិកសហគមន៍មានការយល់ដឹង និងចូលរួមសកម្មភាពជាមួយមន្ត្រីជំនាញ និងអាជ្ញាធរមានសមត្ថកិច្ចក្នុងការរៀបចំផែនការគ្រប់គ្រង និងកន្លែងអភិរក្សជលផលតាមសហគមន៍<br>- ធនធានមនុស្ស រចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ពីខណ្ឌរហូតដល់សង្កាត់រដ្ឋបាលជលផល។ | - មានច្បាប់ស្តីពីជលផល និងច្បាប់ពាក់ព័ន្ធដទៃទៀត<br>- ព្រះរាជក្រឹត្រសម្រាប់បង្កើតសហគមន៍នេសាទ<br>- អនុក្រិត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ<br>- ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល រយៈពេល១០ឆ្នាំ<br>- មានការគាំទ្រដល់វារីវប្បករ ក្នុងសកម្មភាពធ្វើឲ្យប្រសើរឡើងដល់កម្មវិធីចិញ្ចឹម និងបង្កាត់ភ្ញាស់ពូជត្រី និងការអនុវត្ត គោលការណ៍វារីវប្បកម្មល្អ<br>- មានការគាំទ្រពីដៃគូពីអង្គការនានា<br>- មានទីផ្សារសម្រាប់នាំចេញផលិតផលជលផល<br>- មានតម្រូវការទីផ្សារខ្ពស់<br>- មានគោលនយោបាយបើកទូលាយក្នុងការចិញ្ចឹមត្រី (ត្រីឆ្តោរ ត្រីរស់.....)។ |

| ចំណុចខ្សោយ | ការគំរាមកំហែង |
| --- | --- |
| - នៅមានភាពខ្វះចន្លោះបទដ្ឋានគតិយុទ្ធមួយចំនួនដែលច្បាប់ស្តីពីជលផលចង្អុលបង្ហាញ<br>- ការចូលរួមរបស់ប្រជានេសាទ និងអ្នកពាក់ព័ន្ធក្នុងវិស័យជលផលនៅមានកម្រិតនៅឡើយ<br>- អភិបាលកិច្ច និងការអនុវត្តច្បាប់នៅមានកំរិត<br>- ខ្វះខាតថវិកាជួយគាំទ្រក្នុងការស្តារ និងពង្រឹងការយាមល្បាតឲ្យមានប្រសិទ្ធភាព<br>- ខ្វះខាតថវិកាសម្រាប់សហគមន៍នេសាទអនុវត្តផែនការគ្រប់គ្រងរបស់ខ្លួនក្រោយផែនការសកម្មភាពត្រូវបាន អនុម័តរួច<br>- ប្រើជីគីមី ថ្នាំពុលលើដំណាំកសិកម្មនៅក្នុងដែននេសាទ<br>- ចំណីត្រីមានតម្លៃថ្លៃ ឯត្រីចិញ្ចឹមមានតម្លៃថោក<br>- មានទំនាស់លើការប្រើប្រាស់ទឹក ក្នុងសហគមន៍ស្រះជម្រកត្រីសម្រាប់ស្រោចស្រពស្រូវ និងដំណាំផ្សេងៗដែលធ្វើឲ្យប៉ះពាល់ដល់ការអភិរក្សត្រីពូជ<br>- មន្ត្រីជំនាញមានចំនួនតិចលំបាកក្នុងការការពារទប់ស្កាត់បទល្មើសក្នុងដែននេសាទឲ្យបានគ្រប់ជ្រុងជ្រោយ<br>- ភាពរាំងស្ងួត ខ្វះប្រភពទឹកនៅរដូវប្រាំង ហើយមានទឹកជំនន់នៅរដូវវស្សា<br>- ខ្វះមធ្យោបាយនិងថវិកាចុះទប់ស្កាត់បង្ក្រាបបទល្មើសជលផល។ | - ការប្រែប្រួលអាកាសធាតុ ខ្យល់ព្យុះញឹកញាប់ ភ្លៀងខ្លាំង<br>- បម្រែបម្រួលអាកាសធាតុ និងរបបទឹកទន្លេមេគង្គ បឹង អូរព្រែកត្រូវបានគោករាក់និងប្រព័ន្ធអេកូឡូស៊ីបាត់បង់<br>- សកម្មភាពកាប់រាន និងដុតទន្ទ្រានព្រៃលិចទឹកដើម្បីពង្រីកផ្ទៃដីកសិកម្ម<br>- ការប្រើឧបករណ៍នេសាទខុសច្បាប់ របាំងសាច់មងមានក្រឡាញឹក និងលើសប្រវែងកំណត់ និងប្រើឧបករណ៍ចល័ត<br>- កន្លែងអភិរក្សមួយចំនួនមានសភាពរីងរាក់ខ្លាំងនៅរដូវប្រាំងដែលជាហេតុបណ្តាលឲ្យត្រីមេពូជងាប់ និងងាយស្រួលបង្កឲ្យជនខិលខូចចូលលួចនេសាទ<br>- មានការប្រកួតប្រជែង ការនាំចូលផលិតផលជលផលពីប្រទេសជិតខាង<br>- មានបទល្មើសកើតឡើងនៅរដូវប្រាំង មានដូចជាការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ ការបង្កឲ្យភ្លើងឆេះព្រៃ ការឈូសឆាយរានដីព្រៃលិចទឹកក្នុងកន្លែងនេសាទសហគមន៍។ |

### គ. តារាងស្ថិតិជលផលក្នុងខេត្តតាកែវ

**តារាងទី 10 ÷ តារាងស្ថិតិការងារជលផលក្នុងខេត្តតាកែវ (ឆ្នាំ២០១៤-២០១៨)**

| ការពណ៌នា | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | អត្រាផ្លាស់ប្តូរ (%) ២០១៤-២០១៨ |
| --- | --- | --- | --- | --- | --- | --- | --- |
| សហគមន៍នេសាទ | សហគមន៍ | 18 | 18 | 18 | 18 | 18 | 0% |
| បង្ក្រាបបទល្មើសជលផល | ករណី | 390 | 378 | 126 | 131 | 142 | -63.59% |
| កសិដ្ឋានផលិតកូនត្រី | កសិដ្ឋាន | 37 | 28 | 37 | 37 | 24 | -35.14% |
| បរិមាណផលត្រី | ពាន់តោន | 14.186 | 10.522 | 13.193 | 15.337 | 38.918 | 174.34% |
| បរិមាណផលបង្កង | តោន | 97 | 62 | 73 | 84 | 23 | -76.29% |
| ការចិញ្ចឹមត្រីក្នុងស្រែ | គ្រួសារ | 225 | 225 | 0 | 0 | 0 | -100.00% |
| ស្រះចិញ្ចឹមត្រី | ស្រះ | 8,135 | 8,135 | 9,180 | 9,180 | 9,180 | 12.85% |

### បរិមាណផលជលផលក្នុងខេត្ត (ឆ្នាំ២០១៤-២០១៨)

## ១.២.១០ ផ្នែកខណ្ឌរដ្ឋបាលព្រៃឈើ

### ក. ការពណ៌នា




*ក្រាហ្វិក 13. ការវិវឌ្ឍន៍នៃបរិមាណផលជលផលក្នុងខេត្ត*

រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ លើកម្មវិធីកំណែទម្រង់ផ្នែកព្រៃឈើ ខណ្ឌរដ្ឋបាលព្រៃឈើខេត្តតាកែវខិតខំយកចិត្តទុកដាក់ចូលរួមចំណែក បង្កើនសមត្ថភាពមន្ត្រីលើការត្រួតពិនិត្យ និងគ្រប់គ្រងព្រៃឈើក្នុងដែនសមត្ថកិច្ចសំដៅថែរក្សាការពារព្រៃឈើ ប្រកបដោយនិរន្តរភាព ។

ដោយផ្អែកលើច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានផ្សេងៗខណ្ឌរដ្ឋបាលព្រៃឈើតាកែវ បានផ្តោតជាពិសេសលើការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើសារាចរណែនាំលេខ០៥សរណន ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ផ្សព្វផ្សាយឲ្យបានទូលំទូលាយចូលជ្រៅដល់គ្រប់ប្រជាពលរដ្ឋ ជាពិសេស អ្នកដែលរស់នៅក្បែរ និងក្នុងតំបន់ព្រៃឈើ បង្កើនអភិបាលកិច្ចល្អ បន្តជម្រុញការកំណត់ដែនព្រៃសហគមន៍ខិតខំលើកកម្ពស់ប្រសិទ្ធិភាពការគ្រប់គ្រងការអភិរក្សព្រៃឈើ និងសត្វព្រៃក្នុងដែនសមត្ថកិច្ចខណ្ឌរដ្ឋបាលព្រៃឈើខេត្តតាកែវ ជម្រុញការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ បង្កើនការដាំនិង ស្តារព្រៃឈើឡើងវិញ កសាងសមត្ថភាព ធ្វើការអភិវឌ្ឍន៍ធនធានមនុស្ស សិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយអំពីព្រៃឈើ ។

ទិសដៅខណ្ឌរដ្ឋបាលព្រៃឈើខេត្តតាកែវខិតខំបណ្តុះកូនឈើដាំឈើឡើងវិញ សំដៅទាញយកប្រយោជន៍ច្រើនបំផុតពីការរួមចំណែកដាំឈើឡើងវិញនៅក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច ។

នៅក្នុងការរួមចំណែកការគ្រប់គ្រង ការរក្សាការពារ ការត្រួតពិនិត្យព្រៃឈើ និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងការប្រើប្រាស់ធនធានព្រៃឈើខណ្ឌរដ្ឋបាលព្រៃឈើបានសម្រេចជោគជ័យ នូវសមិទ្ធិផលមួយចំនួន ក្នុងរយៈពេល ០៥ឆ្នាំ (២០១៤ ដល់ ២០១៨) ដូចជា÷ សកម្មភាព បណ្តុះកូនឈើ សំរាប់ចែកចាយជូនប្រជាពលរដ្ឋតាមវត្តអារាម សាលារៀន ទីសាធារណៈ និងតាមស្រុកក្នុងខេត្ត ចាប់ពីខែកក្កដាបុណ្យរុក្ខទិវារៀងរាល់ឆ្នាំ និងដាំដុះដើមឈើឡើងវិញ និងជម្រុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋសហគមន៍ ចូលរួមដាំឈើការពារព្រៃឈើ ។

ជាក់ស្តែងក្នុងរយៈពេល០៥ឆ្នាំពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ដាំកូនឈើរុក្ខទិវាចំនួន ១០,៧៨ហត សកម្ម ភាពបណ្តុះកូនឈើមានចំនួន ៤៨៦ ៣២៣ដើម ។

ខេត្តតាកែវមានសហគមន៍ព្រៃឈើចំនួន១៣ លើស្រុកចំនួន០២ (ស្រុកគីរីវង់ និងស្រុកត្រាំកក់) ឃុំចំនួន១៣មានសមាជិក ចំនួន៧ ៩៧៧គ្រួសារស្មើនឹង ២២ ២៤៣នាក់ ( ស្រី១០ ០៤៤នាក់ ) តាមប្រកាសលេខ៥៥០ ប្រក.កសក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០ ស្តីពីការបង្កើត និង ការគ្រប់គ្រង តំបន់ព្រៃសហគមន៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរហូតមកដល់ឆ្នាំ២០១៥ ដីព្រៃសហគមន៍មួយចំនួនត្រូវបានអនុវត្តតាមបទបញ្ញាលេខ០១បបបនៅឆ្នាំ២០១១ ។

ទន្ទឹមនេះខេត្តតាកែវ មានតំបន់សក្តានុពល អាចបង្កើតសហគមន៍ព្រៃឈើមានចំនួន១០កន្លែងទៀតដែលមានផ្ទៃដីប្រហាក់ប្រហែល ២ ៤២៦ហត លើស្រុកចំនួន០១ ឃុំចំនួន០៣ និង៤៤ភូមិ ។

ក្នុងចំណោមសហគមន៍ទាំង១៣នេះ សហគមន៍មួយចំនួនបានចុះកិច្ចព្រមព្រៀង និងសហគមន៍មួយចំនួនទៀតមិនទាន់ចុះកិច្ចព្រមព្រៀងហើយ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានផែនការចុះកិច្ចព្រមព្រៀងសហគមន៍ដែលនៅសេសសល់បន្ថែមទៀតក្នុងឆ្នាំបន្តបន្ទាប់ ។

បន្ថែមលើនេះទៀត កិច្ចសហប្រតិបត្តិការ ជាមួយសមត្ថកិច្ចមូលដ្ឋាន ត្រូវបង្កើនក្នុងការរៀបចំធ្វើបង្គោលព្រំសម្រាប់ធ្វើបច្ចុប្បន្នភាពសហគមន៍ព្រៃឈើ ឲ្យមានស្ថេរភាពគង់វង់។ មានការចូលរួមពីស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធរដ្ឋបាលព្រៃឈើបានធ្វើការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃឈើត្រូវបានអនុវត្តដូចភ្លៀងរលឹម សំដៅកាត់បន្ថយបទល្មើស ។ ជាមួយគ្នានេះដែរ រឹបអូសមធ្យោបាយសម្ភារៈបម្រើឲ្យសកម្មភាពល្មើសច្បាប់ទុកជាសម្បត្តិរដ្ឋ ។

## ខ. ការវិភាគស្វត

| ភាពខ្លាំង | ឱកាស |
|---|---|
| - មានរចនាសម្ព័ន្ធថ្នាក់ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើច្បាស់លាស់<br>- មានក្រុមចល័ត និងកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ<br>- ប្រជាពលរដ្ឋមានចំណាប់អារម្មណ៍ក្នុងការការពារ និងអភិរក្សព្រៃឈើ<br>- អាជីវករមានការយល់ដឹងអំពីច្បាប់ស្តីពីព្រៃឈើ<br>- ព្រំប្រទល់ចម្ការឈើដាំ ចម្ការពូជនិងព្រៃសហគមន៍បានកំណត់លើទីវាល<br>- មានស្ថានីយ៍ស្តារ និងអភិវឌ្ឍព្រៃឈើសម្រាប់សិក្សាស្រាវជ្រាវ និងទេសចរកំសាន្ត<br>- រាជរដ្ឋាភិបាលបានបង្កើតឡើងនូវកម្មវិធីព្រៃឈើជាតិ ២០១០ ដល់២០២៩ដើម្បីគាំទ្រដល់ការអភិវឌ្ឍក្របខណ្ឌការងារ គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងដោយនិរន្តភាពនូវធនធានព្រៃឈើ<br>- ថ្នាលបណ្តុះកូនឈើសម្រាប់ដាំស្តារ និងចែកជូនប្រជាពលរដ្ឋ<br>- មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថភាពសម្រាប់គ្រប់គ្រង និងអភិវឌ្ឍព្រៃឈើ<br>- មានកម្មវិធីរុក្ខទិវារាល់ឆ្នាំ<br>- មានការគាំទ្រពីដៃគូអភិវឌ្ឍអនុវត្តគម្រោងកសិកម្មចម្រុះ គាំទ្រការស្រាវជ្រាវ គាំទ្រការគ្រប់គ្រងព្រៃឈើ | - មានបទដ្ឋានច្បាប់ស្តីពីព្រៃឈើ និងបទដ្ឋានច្បាប់ពាក់ព័ន្ធរឹងមាំសម្រាប់ពង្រឹងការអនុវត្តច្បាប់<br>- មានការផ្តល់ថវិកាពីរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យ ព្រៃឈើ (ដាំឈើ ល្បាតព្រៃសហគមន៍ ធ្វើព្រំប្រទល់ចម្ការពូជ)<br>- មានស្ថានីយ៍ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ព្រៃឈើសហគមន៍ ព្រៃឈើមានសក្តានុពលសម្រាប់ទេសចរ និងសួនលំហែ<br>- ថ្នាក់ជាតិផ្តល់គោលការណ៍ណែនាំបច្ចេកទេសលើការផ្គត់ផ្គង់ផលអនុផលព្រៃឈើសម្រាប់តម្រូវការប្រើប្រាស់។ |

| | |
|---|---|
| - មានរចនាសម្ព័ន្ធគណៈកម្មាធិការជាតិទប់ស្កាត់ឮ និងបង្ក្រាប បទល្មើសធនធានធម្មជាតិ<br>- មានថ្នាលបណ្តុះ ចែកចាយកូនឈើ ។ | |
| **ភាពខ្សោយ:** | **ការគំរាមកំហែង** |
| - ការកាប់រានទន្ទ្រានដីព្រៃឈើរបស់រដ្ឋធ្វើកម្មសិទ្ធិដោយ ខុសច្បាប់<br>- ជនខិលខូចឃុបឃិតចុះបញ្ជីដីព្រៃសហគមន៍ធ្វើកម្មសិទ្ធ<br>- ការដឹកជញ្ជូនផល អនុផលព្រៃឈើដោយខុសច្បាប់<br>- ការដុតចម្ការឈើដាំ និងចម្ការពូជឈើដើម្បីវាតយកដីធ្វើ កម្មសិទ្ធ<br>- ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនៅមូលដ្ឋានពុំ ទាន់ទូលំទូលាយ<br>- ខ្វះកញ្ចប់ថវិកាសម្រាប់ចំណាយក្នុងការទប់ស្កាត់ បទល្មើសព្រៃឈើ និងសត្វព្រៃ។ | - ភ្លើកគ្គាធម្មជាតិ (រាំងស្ងួតបង្កផលពិបាកក្នុងការដាំដុះលូតលាស់នៃដើមឈើ)<br>- ទីផ្សារដីមានតម្លៃបណ្តាលឱ្យមានការទន្ទ្រានដីព្រៃឈើធ្វើកម្មសិទ្ធិ<br>- អាជ្ញាធរមូលដ្ឋានភូមិ ឃុំ បញ្ជាក់លើលិខិតទិញលក់ដីក្នុងដីគម្របព្រៃឈើ<br>- កង្វះខាតប្រភពឈើស្របច្បាប់សម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់<br>- អ្នកមានធនធានញុះញង់ប្រជាពលរដ្ឋមូលដ្ឋាន និងជនចំណាកស្រុកឱ្យទន្ទ្រានដីដើម្បីគោលដៅពាណិជ្ជកម្ម។ |

### គ. តារាងស្ថិតិការងារព្រៃឈើក្នុងខេត្តតាកែវ

**តារាងទី 11 ÷ តារាងស្ថិតិការងារព្រៃឈើខេត្តតាកែវ (ឆ្នាំ២០១៤-២០១៨)**

| ការពណ៌នា | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | អត្រាផ្លាស់ប្តូរ (%) ២០១៤-២០១៨ |
|---|---|---|---|---|---|---|---|
| ចំនួនកូនឈើបណ្តុះ | ដើម | 98,345 | 100,178 | 107,274 | 102,024 | 78,502 | -20.17% |
| រុក្ខទិវា (ហត) | ហ.ត | 02 | 02 | 2.17 | 02 | 2.6 | 30% |
| ចំនួនសហគមន៍ | សហគមន៍ | 12 | 12 | 13 | 13 | 13 | 8.33% |
| ផ្ទៃដីសហគមន៍ | ហិកតា | 9,486 | 9,486 | 9,488 | 9,488 | 9,488 | 0.02% |

តាមរយៈតារាងខាងលើបង្ហាញថាអត្រាផ្លាស់ប្តូរចំនួនកូនឈើដែលត្រូវបានបណ្តុះក្នុង ឆ្នាំ២០១៤ មានប្រមាណ ៩៨ ៣៤៥ដើម មានការថយចុះ ប្រមាណ ៧៨ ៥០២ដើម ក្នុងឆ្នាំ២០១៨ ស្មើរនឹង២០,១៧%។ផ្ទៃដីដែលធ្វើបុណ្យរុក្ខទិវា មានការកើនឡើងពី ២ហិកតា នៅក្នុងឆ្នាំ២០១៤ មកត្រឹម ២,៦ហិកតា ក្នុងឆ្នាំ២០១៨ ស្មើរនឹង៣០%។ ចំនួនសហគមន៍ព្រៃឈើមាន១២សហគមន៍ក្នុងឆ្នាំ២០១៤ កើនដល់១៣សហគមន៍ក្នុងឆ្នាំ២០១៨ ស្មើរ ៨,៣៣%។ រីឯផ្ទៃដីសហគមន៍ព្រៃឈើកើនឡើងប្រមាណ ០,០២%ផងដែរដោយ ក្នុងឆ្នាំ២០១៤ មានប្រមាណ ៩ ៤៨៦ហិកតា មកត្រឹម ៩ ៤៨៨ ហិកតា ក្នុងឆ្នាំ២០១៨។

ផ្ទៃដីសហគមន៍ព្រៃឈើក្នុងខេត្ត (ឆ្នាំ២០១៤-២០១៨)




*ក្រាហ្វិក 14. ការវិវឌ្ឍន៍នៃផ្ទៃដីសហគមន៍ព្រៃឈើ*

## ១.២.១១ ផ្នែកនីតិកម្មកសិកម្ម និងការគ្រប់គ្រងសម្ភារៈកសិកម្ម

### ក. ការពណ៌នា

ការងារនីតិកម្មកសិកម្មក្នុងខេត្តតាកែវបានអនុវត្តតាមអនុក្រឹត្យ ៦៩ អនក្រ បកស្ដីពីបមាណី និងការគ្រប់គ្រងសម្ភារៈកសិកម្ម ដែលធ្វើការទៅលើការគ្រប់គ្រងទីតាំងធ្វើអាជីវកម្មសំភារៈកសិកម្ម ដោយចេញលិខិតអនុញ្ញាតលក់ដុំ លក់រាយសម្ភារៈកសិកម្ម តាមរយៈកិច្ចការនេះមន្ទីរបានធ្វើស្ថិតិក្រុមហ៊ុនមួយចំនួនដែលលក់ជីកសិកម្ម ថ្នាំកសិកម្ម ដោយស្របច្បាប់ និងល្មើសច្បាប់។ ចំពោះការលក់ដោយល្មើសច្បាប់គឺធ្វើឡើងដោយនាំចូលលួចលាក់ពីប្រទេសវៀតណាម តាមរយៈដេប៉ូក្រុមឈ្មួញ និងកសិករដែលធ្វើស្រែប្រាំងនៅតាមស្រុកជាប់ព្រំដែនដូចជា ស្រុកគីរីវង់ កោះអណ្ដែត បូរីជលសារ អង្គរបូរី និងព្រៃកប្បាសជាដើម។ ជីកសិកម្មដែលចែកចាយដោយក្រុមហ៊ុនស្របច្បាប់ភាគច្រើនមានស្លាកសញ្ញា ព័ត៌មានត្រឹមត្រូវតាមបច្ចេកទេស។ ដោយឡែកជីកសិកម្មមួយចំនួនដែលចែកចាយមិនស្របច្បាប់ ពុំមានស្លាកសញ្ញាពត៌មានត្រឹមត្រូវតាមបច្ចេកទេសដូចជា Urea Dam Camao (ផលិតផលរបស់ក្រុមហ៊ុនប្រទេសវៀតណាម) 16-16-8-13s (ចែកចាយដោយក្រុមហ៊ុនក្នុងស្រុក) 18-46-0 (ផលិតផលរបស់ក្រុមហ៊ុនប្រទេសចិន) Urea (សំបកបាវពណ៌លឿង ជាផលិតផលប្រទេសចិន និងវៀតណាម មិនមានបកប្រែជាភាសារខ្មែរ និងមិនមានលេខបញ្ជីការត្រឹមត្រូវ។ ក្រៅពីនេះការងារនីតិកម្មកសិកម្ម ក៏ធ្វើការផងដែរទៅលើការពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ច ការអប់រំសមត្ថភាពវិជ្ជាជីវៈ និងផ្សព្វផ្សាយច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំ និងជីកសិកម្មការណែនាំស្ដីពីការទិញការទុកដាក់និងការថែរក្សាជី និងថ្នាំកសិកម្មតាមបច្ចេកទេសជាពិសេសការងារ គៀងគរចំណូលជារៀងរាល់ឆ្នាំ ដែលចំណូលនេះចែកចេញជាពាគី ÷

- ចំណូលពីការកំរៃសេវាចេញលិខិតអនុញ្ញាតលក់ដុំ រាយសំភារៈកសិកម្ម
- ចំណូលពីការបង់កំរៃក្នុងដំណើការវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ
- ចំណូលពីការពិន័យអន្តរកាល។

### ខ. ការវិភាគស្វត

| ចំណុចខ្លាំង | ឱកាស |
|---|---|
| - មានការគាំទ្រ និងលើកទឹកចិត្តពីថ្នាក់ដឹកនាំ កសក នាយកដ្ឋាននីតិកម្មកសិកម្ម និងមន្ទីរ<br>- នាយកដ្ឋានជំនាញបានអភិវឌ្ឍន៍ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដល់មន្ត្រីជំនាញ (ផ្នែកច្បាប់ បច្ចេកទេសពិនិត្យគុណភាព និងការប្រើប្រាស់ជីថ្នាំកសិកម្ម)<br>- មានការបើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈក្នុងការគ្រប់គ្រងការធ្វើអាជីវកម្មសម្ភារៈកសិកម្ម<br>- អាជីវករយល់ពីច្បាប់ស្តីពីការគ្រប់គ្រងសម្ភារៈកសិកម្មចូលរួមអនុវត្ត និងគាំទ្រច្បាប់គ្រប់គ្រងជីថ្នាំកសិកម្ម<br>- ជីវករដាក់ពាក្យសុំធ្វើអាជីកម្មសម្ភារៈកសិកម្មមានការកើនឡើង<br>- មានការចងក្រងសៀវភៅស្ថិតិចុះបញ្ជីកាផលិតផលជីថ្នាំកសិកម្ម និងចរាចរធាតុចូលកសិកម្ម។ | - មានច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ស្តីពីការគ្រប់គ្រងជីថ្នាំកសិកម្ម<br>- ការប្រើប្រាស់ធាតុចូលកសិកម្ម ជាករណីចាំបាច់ក្នុងការជម្រុញកំណើនកសិផល<br>- វិស័យឯកជនចាប់អារម្មណ៍ និងវិនិយោគទុនក្នុងវិស័យជីថ្នាំកសិកម្ម<br>- បុគ្គលិកក្រុមហ៊ុនបានចូលរួមផ្សព្វផ្សាយវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ជីថ្នាំកសិកម្ម<br>- មានការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ<br>- តាមរយៈការប្រកួតប្រជែងទីផ្សារតំលៃជីថ្នាំកសិកម្មបានធ្លាក់ចុះមួយកម្រិត។ |
| **ចំណុចខ្សោយ** | **ការគំរាមកំហែង** |
| - មន្ត្រីបម្រើការងារនីតិកម្មមានចំនួនតិចហើយកម្រិតជំនាញទាប<br>- ខ្វះខាតឧបករណ៍តេស្តគុណភាពជីថ្នាំកសិកម្មពេលត្រួតពិនិត្យ<br>- ខ្វះមធ្យោបាយធ្វើដំណើរក្នុងត្រួតពិនិត្យ ស្រាវជ្រាវ និងបង្ក្រាបបទល្មើស<br>- ការយល់ដឹងពីបច្ចេកទេសប្រើប្រាស់ជីថ្នាំកសិកម្មតាមបទដ្ឋានដែលមានលើសំបកវេចខ្ចប់នៅមូលដ្ឋានមានកម្រិត<br>- ការយល់ដឹង និងការផ្តល់ភាពចាំបាច់ស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរលើសំបកវេចខ្ចប់ជីថ្នាំកសិកម្មនៅមានកម្រិត<br>- ខ្វះខាតបច្ចេកទេសទុកដាក់កាកសំណល់ថ្នាំកសិកម្មដែលបានប្រើប្រាស់រួច<br>- ខ្វះកិច្ចសហការថែទាំពីប្រជាពលរដ្ឋមួយចំនួនក្នុងការការពារកូនឈើដែលបានដាំរួចនៅតាមទីសាធារណៈ<br>- ការចុះផ្សព្វផ្សាយអំពីច្បាប់បញ្ជីសម្ភារៈដែលអនុញ្ញាត និងមិនអនុញ្ញាតនៅមិនទាន់បានទូលំទូលាយ<br>- ខ្វះថវិកាក្នុងការអនុវត្តសកម្មភាពការងារ។ | - មានការហូរចូលនូវផលិតផលកសិកម្មក្លែងបន្លំគុណភាព ដែលអាចធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរទៅលើគុណភាពដី ទឹក ដំណាំ សត្វ និងសុខភាពរបស់មនុស្ស<br>- អាជ្ញាធរមូលដ្ឋានមួយចំនួនពុំទាន់បានយល់ដឹងផ្នែកច្បាប់ក្នុងការគ្រប់គ្រងជីថ្នាំកសិកម្មដែលធ្វើឲ្យការចូលរួម និងសហការទប់ស្កាត់បទល្មើសនៅមានកម្រិត<br>- អង្គការគម្រោងកម្មវិធីមិនសហការ និងមិនផ្តោតលើជំនាញនីតិកម្មដែលចូលរួមធានាការប្រើប្រាស់ជីថ្នាំកសិកម្មប្រកបដោយសុវត្ថិភាព។ |

### គ. តារាងស្ថិតិការងារនីតិកម្មកសិកម្មក្នុងខេត្តតាកែវ

**តារាងទី 12 ÷ តារាងស្ថិតិការងារនីតិកម្មកសិកម្មខេត្តតាកែវ (ឆ្នាំ២០១៤-២០១៨)**

| បរិយាយ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| 1. ចំនួនអាជីវករលក់សម្ភារៈកសិកម្ម ដែលមានច្បាប់អនុញ្ញាត | 52 | 56 | 584 | 502 | 614 |
| 2. ចំនួនអាជីវករលក់សម្ភារៈកសិកម្ម ដែលគ្មានច្បាប់អនុញ្ញាត | 26 | 22 | 0 | 0 | 0 |
| 3. សិក្ខាសាលាផ្សព្វផ្សាយច្បាប់នីតិកម្ម កសិកម្ម ថ្នាក់ស្រុក/ឃុំ | 10 | 2 | 0 | 0 | 95 |

## ១.២.១២ ការងារផែនការ-គណនេយ្យ

### ក. ការពណ៌នា

រយៈពេល ០៥ឆ្នាំ (២០១៤-២០១៨) ការិយាល័យផែនការ-គណនេយ្យបានយកចិត្តទុកដាក់អនុវត្តនូវភារកិច្ចជាអាទិភាពមួយចំនួនពាក់ព័ន្ធទៅនឹងការរៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពរយៈពេលវែងខ្លីសម្របសម្រួលដល់ការិយាល័យជំនាញថ្នាក់ខេត្ត ការិយាល័យកសិកម្មក្រុង-ស្រុក លើដំណើរការកសាង និងអនុវត្តផែនការដែលបានដាក់ចុះ និងបានអនុវត្តសកម្មភាពមួយចំនួនទៀត ស្របតាមភារកិច្ចទទួលខុសត្រូវរបស់ការិយាល័យ។ ជាក់ស្តែងលទ្ធផលដែលសម្រេចបានមានដូចខាងក្រោម ÷

***ការងារផែនការ**

-បានចូលរួមប្រជុំពិគ្រោះយោបល់លើការងាររៀបចំកសាងផែនការអភិវឌ្ឍន៍វិស័យកសិកម្មខេត្តប្រចាំឆ្នាំ

-រៀបចំផែនការវិនិយោគ៣ឆ្នាំរំកិលរបស់ខេត្តឆ្នាំ២០១៦-២០១៨និងផែនការវិនិយោគ៣ឆ្នាំរំកិលបន្តឆ្នាំ ២០១៧-២០១៩

-រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្ត ឆ្នាំ២០១៤-២០១៨

-រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្ត ឆ្នាំ២០១៩-២០២៣

-ត្រៀមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មថ្នាក់ខេត្ត ឆ្នាំ២០២១-២០២៥

-រៀបចំផែនការសកម្មភាព និងបែងចែកថវិកាតាមកម្មវិធី (PB) របស់រដ្ឋាភិបាលដល់ថ្នាក់ស្រុក/ក្រុង ឆ្នាំ២០១៧។

***ការងារស្ថិតិ**

-បានប្រមូលពត៌មាន និងរបាយការណ៍ពីការិយាល័យជំនាញចំណុះឲ្យមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្តបូកសរុប និងផ្ញើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរពាក់ព័ន្ធ

-តាមដានវាយតម្លៃល្បឿនការងារបង្កបង្កើនផលគ្រប់មុខដំណាំរដូវវស្សា-ប្រាំងប្រចាំឆ្នាំ វាយតម្លៃតុល្យ ភាពស្បៀងប្រចាំឆ្នាំ និងធ្វើរបាយការណ៍ជាប្រចាំជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត

-រួមសហការជាមួយការិយាល័យជំនាញពាក់ព័ន្ធចុះពិនិត្យតាមដាន វាយតម្លៃផលប៉ះពាល់-ខូចខាតគ្រប់មុខដំណាំដោយសារសត្វល្អិត គ្រោះរាំងស្ងួតទឹកជំនន់ និងរៀបចំរបាយការណ៍ផ្ញើជូនថ្នាក់ដឹកនាំខេត្ត និងនាយកដ្ឋានសិត្ថិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ចុះអង្កេតវាស់ស្ទង់ទិន្នផលស្រូវរដូវវស្សា និងស្រូវរដូវប្រាំងប្រចាំឆ្នាំនីមួយៗទៅតាមផែនការជ្រើសរើសភូមិគ្រួសារ និងសំណាកគំរូចៃដន្យរបស់នាយកដ្ឋានផែនការ និងស្ថិតិ។

***ការងារទីផ្សារ**

-ចុះស្រង់តម្លៃកសិផលសំខាន់ៗ នៅតាមបណ្តាទីផ្សារនានាក្នុងខេត្ត និងផ្សព្វផ្សាយត្រឡប់ជូនកសិករ

-តាមដាននិន្នាការតម្លៃកសិផលតាមរដូវ និងធ្វើការព្យាការណ៍។

***ការងារប្រមូលចំណូលពីអាជីវកម្មពិឃាតសត្វ**

ប្រភពចំណូលថវិការបស់មន្ទីរ គឺបានតាមរយៈការផ្តល់កម្រៃសេវាកម្មចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មពិឃាតសត្វលក់សម្ភារៈកសិកម្ម ការត្រួតពិនិត្យអនាម័យសាច់សត្វគ្រប់ប្រភេទ និងការផាកពិន័យ។ នៅឆ្នាំ២០១៨ ចំណូលដែលប្រមូលបានត្រឹមតែប្រហែល ៨៩,៦៨លានរៀលនៅឆ្នាំ២០១៨។

### ខ. ការវិភាគស្វត

| ចំណុចខ្លាំង | ឱកាស |
|---|---|
| - មានរចនាសម្ព័ន្ធការិយាល័យ និងបែងចែកតួនាទីទទួលខុសត្រូវតាមផ្នែកនីមួយៗច្បាស់លាស់<br>- មន្ត្រីថ្នាក់ដឹកនាំមន្ទីរ និងការិយាល័យជំនាញខេត្តស្រុកមានបទពិសោធន៍ក្នុងការរៀបចំផែនការរយៈពេលវែង និងរយៈពេលខ្លី<br>- មានមធ្យោបាយ បរិក្ខា និងសម្ភារៈគ្រប់គ្រាន់ក្នុងកិច្ចការជាប្រចាំរបស់ការិយាល័យ<br>- មានការចូលរួមប្រកបដោយទទួលខុសត្រូវពីសំណាក់មន្ត្រីជំនាញ និងមន្ត្រីជំនាញនៃការិយាល័យពាក់ព័ន្ធ<br>- មានផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ ៣ឆ្នាំរំកិល ប្រចាំឆ្នាំរបស់មន្ទីរ<br>- ការចំណូល-ចំណាយបានរហូតដល់ ៩៧,៣៤%<br>- ទូទាត់ឯកសារ និងធ្វើផែនការឆ្នាំទាន់ពេលវេលា។ | - មានការចូលរួមថវិកាពីកម្មវិធីផ្សព្វផ្សាយបច្ចេកទេសថ្មីធន់នឹងការប្រែប្រួលអាកាសធាតុ ( ASPIRE )<br>- បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាស្តីពីការអនុវត្តការចំណាយជាមួយថ្នាក់ខេត្ត ក្រសួង និងផ្នែកពាក់ព័ន្ធនានា។ |
| **ចំណុចខ្សោយ** | **ការគំរាមកំហែង** |
| - សមត្ថភាពមន្ត្រីជំនាញមួយចំនួនមានកំរិតទាបនៅ ឡើយដែលធ្វើឲ្យខុសនីតិវិធីខ្លះ<br>- ពុំទាន់មានមន្ត្រីជំនាញគ្រប់គ្រាន់ដែលទទួលខុសត្រូវតាមគ្រប់ផ្នែកនៅឡើយ,មន្ត្រីម្នាក់ទទួលខុត្រូវច្រើនមុខងារ។ | - នីតិវិធីក្នុងការរៀបចំផែនការ និងថវិកា និងបែបផែនចំណាយ-ចំណូលមានភាពបត់បែន និងកែទម្រង់ថ្មីធ្វើឱ្យអ្នកអនុវត្តផ្ទាល់ជួបការលំបាក។ |

### គ. តារាងស្ថិតិការងារគណនេយ្យ

**តារាងទី 13 ÷ ការប្រមូលចំណូល (ឆ្នាំ២០១៤-២០១៨)**

| ប្រភពចំណូល (លាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | អត្រាផ្លាស់ប្តូរ(%) ២០១៤-២០១៨ |
|---|---|---|---|---|---|---|
| ប្រាក់អាករពិឃាដសត្វ | 53,947,000 | 64,011,500 | 67,321,000 | 69,508,500 | 78,016,500 | 44.62% |
| ប្រាក់អាករចលនាសត្វ | 49,694,000 | 33,998,000 | 57,004,000 | 132,093,000 | 143,052,000 | 187.87% |
| ច្បាប់អាជីវកម្ម | 29,840,000 | 32,880,000 | 34,240,000 | 40,160,000 | 38,960,000 | 30.56% |
| ប្រាក់ពិន័យ | 2,000,000 | 0 | 6,000,000 | 35,000,000 | 0 | -100.00% |
| **សរុប** | **135,481,000** | **130,889,500** | **164,565,000** | **276,761,500** | **260,028,500** | |

តាមតារាងខាងលើបានបង្ហាញថាប្រាក់អាករពិឃាតសត្វមានការកើនឡើងជារៀងរាល់ឆ្នាំ ដោយចំនួនសត្វដែលបានពិឃាតមានចំនួនកើនឡើងជាលំដាប់ ជាមួយគ្នានេះប្រាក់អាករចលនាសត្វក៏មានការកើនឡើងជារៀងរាល់ឆ្នាំ ដោយឡែកឆ្នាំ២០១៥ ចលនាសត្វមានការថយចុះដោយសារមានផ្ទុះជម្ងឺផ្តាសាយបក្សី។ ចំពោះប្រាក់ពិន័យក្នុងឆ្នាំ២០១៥ និង

ឆ្នាំ២០១៨ ពុំមានបទល្មើសកើតឡើង។ ចំណែកឯច្បាប់អាជីវកម្មឆ្នាំ២០១៨ ថយចុះដោយស្ថានភាពតម្លៃសត្វលើទីផ្សារធ្លាក់ចុះ (មានការប្រគួតប្រជែង និងការនាំចូល) ធ្វើឲ្យអាជីវកម្មចិញ្ចឹមសត្វមួយចំនួនផ្អាកដំណើរការ។

**ការប្រមូលចំណូល (២០១៤-២០១៨)**




*ក្រាហ្វិក 15. ការវិវឌ្ឍន៍នៃការប្រមូលចំណូល*

## ១.២.១៣ ការងាររដ្ឋបាល និងការគ្រប់គ្រងធនធានមនុស្ស

### ក. ការពណ៌នា

***ការងាររដ្ឋបាល**

-បានសម្របសម្រួលចរាចរឯកសាររដ្ឋបាលធ្វើលិខិតឆ្លើយឆ្លងផ្សេងៗ និងបានគ្រប់គ្រងទុកដាក់ឯកសារឲ្យបានល្អប្រសើរ

-ធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌ និងផ្ញើរជូននាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួង បានទៀងទាត់

-ធានាបានប្រសិទ្ធភាពការងារ សន្តិសុខ និងកិច្ចការផ្សេងៗ

-បានកែលម្អសោភ័ណ្ឌភាព និងអនាម័យក្នុងមន្ទីរបានល្អប្រសើរ

-បានគ្រប់គ្រងជីវប្រវត្តិ និងគ្រប់គ្រងស្ថានភាពមន្ត្រីបានល្អប្រសើរ

-បានរៀបចំការងារបៀវត្ស ដំឡើងថ្នាក់សម្រួលឯកសារផ្សេងៗសម្រាប់មន្ត្រីចូលនិវត្តន៍ និងការធានារ៉ាប់រងសង្គម ។

-រៀបចំបែបបទឯកសារ និងសម្របសម្រួលលើដំណើរការលើកសំណើសុំគ្រឿងឥស្សរយសជូនថ្នាក់ដឹកនាំមន្ទីរ ថ្នាក់ដឹកនាំការិយាល័យមន្ត្រីជំនាញថ្នាក់ខេត្ត-ក្រុង-ស្រុក

-សម្របសម្រួលកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

***ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស**

-ស្ថិតិមន្ត្រីកសិកម្មគិតត្រឹមឆ្នាំ២០១៤ មានចំនួន ១៦២នាក់ ស្រីមាន៣៨នាក់ មានការកើនឡើងរហូតដល់ ២២៦នាក់ ស្រី៤៨នាក់ នៅឆ្នាំ២០១៨។ កំណើនមានការប្រែប្រួលមិនទៀងបែបនេះដោយសារតែក្នុងរយៈពេលប្រាំឆ្នាំមកនេះមានតម្រូវការមន្ត្រីថ្មីបន្ថែម។ ការផ្ទេរចេញ និងផ្ទេរចូលរបស់មន្ត្រី មន្ត្រីចូលនិវត្តន៍ និងមរណភាពជាដើម។ ប៉ុន្តែកំណើននេះពុំឆ្លើយតបតាមតម្រូវការនៅតាមបណ្តាការិយាល័យជំនាញនៅឡើយដែលតម្រូវឲ្យមានមន្ត្រីបន្ថែមមួយចំនួនទៀត

-រៀបចំសំណើសុំមន្ត្រីជំនាញបន្ថែមប្រចាំឆ្នាំ (មន្ត្រីក្របខ័ណ្ឌ និងមន្ត្រីជាប់កិច្ចសន្យា ) ទៅនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានរៀបចំសម្រេងតម្រូវការវគ្គបណ្តុះបណ្តាលមន្ត្រី និងលើកសំណើទៅស្ថាប័ន អង្គការជាតិ និងអន្តរជាតិនានា ដើម្បីគាំទ្រ

-រៀបចំសំណើបែងចែក និងសម្រួលការងារមន្ត្រីឱ្យទទួលខុសត្រូវទៅតាមកម្រិតបទពិសោធន៍ កម្រិតជំនាញ សញ្ញាបត្រ និងទេព្យកោសល្យ។

### ខ. ការវិភាគស្វត

| ចំណុចខ្លាំង | ឱកាស |
|---|---|
| - មានកន្លែងសម្រាប់បំពេញការងារសមរម្យ<br>- មន្ត្រីក្នុងការិយាល័យមានឆន្ទៈបំពេញការងារ<br>- មានការគាំទ្រពីថ្នាក់ដឹកនាំមន្ទីរ និងស្ថាប័នពាក់ព័ន្ធ<br>- មានសាមគ្គីភាពផ្ទៃក្នុង និងសហការការងារបានល្អ<br>- មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់<br>- មានការលើកទឹកចិត្តនិងការសរសើរពីថ្នាក់ដឹកនាំ<br>- មានមធ្យោបាយ សម្ភារៈគ្រប់គ្រាន់បម្រើឱ្យការងារប្រចាំថ្ងៃ និងសម្របសម្រួលការងារ លិខិត ឯកសាររដ្ឋបាល និងធ្វើលិខិតឆ្លើយឆ្លងផ្សេងៗបានទាន់ពេល។ | - មានឯកសារគតិយុត្តិ សារាចរ និងគោលការណ៍ណែនាំគ្រប់គ្រាន់<br>- មានច្បាប់លិខិតបទដ្ឋានគតិយុត្តិជាត្រីវិស័យតម្រង់ទិស<br>- ការិយាល័យមានទីតាំងបំពេញការងារសមស្រប<br>- ថ្នាក់ដឹកនាំមានការលើកទឹកចិត្តមន្ត្រីឱ្យសិក្សាបន្ត<br>- មានការបែងចែកតួនាទីភារៈកិច្ចច្បាស់លាស់ធ្វើឱ្យការងារមានដំណើរការល្អ។ |
| **ចំណុចខ្សោយ** | **ការគំរាមកំហែង** |
| - ខ្វះមន្ត្រីជំនាញផ្នែកគ្រប់គ្រងរដ្ឋបាល<br>- ការទទួលខុសត្រូវរបស់មន្ត្រីទទួលបន្ទុកនៅមានកំរិត<br>- ពុំទាន់បានអនុវត្តនូវកិច្ចការ មួយចំនួនធំដែលបានកំណត់ក្នុងសហលក្ខ័ណមន្ត្រីរាជការ<br>- មន្ត្រីមួយចំនួនពុំទាន់គោរពបានល្អនូវបទបញ្ជាផ្ទៃក្នុងនិងវិន័យបានល្អ។ | - ការិយាល័យរដ្ឋបាលពុំសូវមានមន្ត្រីចង់មកបម្រើការងារ<br>- មន្ត្រីបម្រើការងារមានចំនួនតិច<br>- មន្ត្រីដែលមានសមត្ថភាពជំនាញបទពិសោធន៍លើការងាររដ្ឋបាល បានចូលនិវត្តជាបន្តបន្ទាប់ និងសុំផ្លាស់ចេញ<br>- មន្ត្រីថ្នាក់ស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ មិននៅក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម។ |

### គ. តារាងស្ថិតិមន្ត្រីរាជការរបស់មន្ទីរ

**តារាងទី 14 ÷ ចំនួនមន្ត្រីមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (ឆ្នាំ២០១៤-២០១៨)**

| បរិយាយ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | អត្រាផ្លាស់ប្តូរ (%) ២០១៤-២០១៨ |
|---|---|---|---|---|---|---|
| ចំនួនមន្ត្រី | 162 | 152 | 208 | 199 | 226 | 39.50% |
| ស្រី | 38 | 35 | 41 | 41 | 48 | 26.31% |

ចំនួនមន្ត្រីមានការប្រែប្រួលដោយចំនួនមន្ត្រីក្របខ័ណ្ឌថ្មីមានចំនួនតិចជាងចំនួនមន្ត្រីដែលចូលនិវត្សន៍ដោយឡែកចាប់ពីឆ្នាំ២០១៦ មានសន្ទុះកើនឡើងខ្ពស់ដោយបញ្ចូលមន្ត្រីខណ្ឌរដ្ឋបាលជល និងព្រៃឈើចូលមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តវិញ។




*ក្រាហ្វិក 16. ចំនួនមន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

### ១.២.១៤ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍

គម្រោងអភិវឌ្ឍកសិកម្ម និងជម្រុញកំណើនសេដ្ឋកិច្ច (PADEE) ជាគម្រោងដែលធ្វើការទាក់ទងទៅនឹងការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មដូចជាបច្ចេកទេសចិញ្ចឹមសត្វ ការដាំបន្លែជីវសុវត្ថិភាពចងក្រងក្រុមកសិករប្រើប្រាស់ទុនបង្វិលចែកទុនដល់សមាជិកក្រុមទុនបង្វិល បណ្តុះបណ្តាលគ្រូបង្គោល ការប្រើប្រាស់ទុនបង្វិល ព្រមទាំងបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយភូមិឲ្យប្រើប្រាស់ប្រព័ន្ធ MIS។ ក្រៅពីគម្រោងគម្រោងអភិវឌ្ឍន៍កសិកម្ម និងជម្រុញកំណើនសេដ្ឋកិច្ច(PADEE) នៅមានគម្រោងSRR និងសមាគមន៍ព្រៃឈើអង្គការចំរើនជាតិខ្មែរដែលធ្វើការដោយអនុវត្តសាលាស្រែកសិករនៅតាមបណ្តាស្រុកមួយចំនួនក្នុងខេត្ត ។ លើសពីនេះទៅទៀតនៅមានកម្មវិធីឡជីវឧស្ម័នខេត្តដែលធ្វើការសាងសង់ឡជីវឧស្ម័នជារៀងរាល់ឆ្នាំ ដែលមកដល់ពេលនេះបានចំនួន ៤ ៨១០ឡ គិតត្រឹមឆ្នាំ ២០១៦។ គម្រោងនេះបានបណ្តុះបណ្តាលជាងសាងសង់ឡថ្មីដោយសហការរវាងកម្មវិធីខេត្ត និងក្រុមហ៊ុនជាងទាំងបីប្រចាំខេត្ត ព្រមទាំងបានសាងសង់រោងជីបានចំនួន ៨៧ រោង។ ផ្នែករដ្ឋបាលជលផលក៏បានសហការជាមួយអង្គការ BIRDLIFE ការងារអភិរក្សសត្វ អង្គការចំរើនជាតិខ្មែរ CCK និងអង្គការ UNDP ទាក់ទងទៅនឹងការងារអភិរក្សសត្វ ការងារវារីវប្បកម្ម ការអភិវឌ្ឍន៍សហគមន៍ ពង្រឹងសហគមន៍ ។

## ១.៣ ការងារយេនឌ័រ និងកិច្ចការពារកុមារក្នុងវិស័យកសិកម្ម

### ១.៣.១ ការងារយេនឌ័រក្នុងវិស័យកសិកម្ម

ខេត្តតាកែវមានស្ត្រីប្រមាណ ៥១% នៃចំនួនប្រជាពលរដ្ឋសរុបក្នុងខេត្តដែលបានចូលរួមយ៉ាងសំខាន់ក្នុងសកម្មភាពផលិតស្បៀងសម្រាប់គ្រួសារ និងសកម្មភាពពលកម្មកសិកម្ម ផលិតកម្ម ការប្រមូលផលការកែច្នៃនូវផលិតផលកសិកម្មសម្រាប់លក់ដូរដើម្បីបង្កើនប្រាក់ចំណូលគ្រួសារ ការចូលរួមក្នុងកិច្ចការសហគមន៍កសិកម្ម។

កសិករជាស្ត្រីមួយចំនួនជាអនក្ខរជន ឬមានកម្រិតវប្បធម៌ទាបហើយការទទួលបានឱកាសពីការ ផ្តល់សេវាកម្មនានាក៏នៅមានកម្រិត និងប្រឈមជាមួយនឹងឧបសគ្គជាច្រើន ដែលទាមទារឱ្យមន្ទីរកសិកម្មខេត្ត អង្គភាពពាក់ព័ន្ធនានា និងដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវបង្កើនការយកចិត្តទុកដាក់ឱ្យបានខ្ពស់បន្ថែមទៀត។

ផ្អែកលើបរិបទនេះ និងយោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសគោលនយោបាយ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកន្លងមកមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទបានយកចិត្តទុកដាក់បញ្ជ្រាបសកម្មភាពយេនឌ័រក្នុងគ្រប់សកម្មភាពទាំងអស់របស់មន្ទីរ និងក្នុងគម្រោងអភិវឌ្ឍន៍នានាការផ្តល់បច្ចេកទេសកសិកម្មដោយផ្ទាល់ដល់ស្ត្រីដើម្បីឱ្យស្ត្រីទទួលបានចំណេះដឹង និងជំនាញបច្ចេកទេសកសិកម្មពេញលេញក្នុងការផលិតស្បៀងបង្កើនប្រាក់ចំណូលក្នុងគ្រួសារ និងទទួលបានសេវាផ្សេងៗទៀត។ ចំពោះមន្ត្រីរាជការដែលជាស្ត្រីកំពុងបម្រើការងារនៅការិយាល័យជំនាញថ្នាក់ខេត្ត និងស្រុកក៏ត្រូវបានយកចិត្តទុកដាក់ផងដែរលើការពង្រឹងសមត្ថភាពជំនាញ និងការជម្រុញស្ត្រីឱ្យមាននៅក្នុងជួរថ្នាក់ដឹកនាំនៃការិយាល័យដែលអនុវត្តកន្លងរួមមាន ៖

-បានបញ្ជ្រាបទស្សនទានស្តីពីយេនឌ័រក្នុងវិស័យកសិកម្ម តួនាទីបុរសស្ត្រី នៅក្នុងវគ្គបណ្តុះបណ្តាលនានា

-លើកទឹកចិត្ត និងបង្កលក្ខណៈឱ្យស្ត្រីជាកសិករចូលរួមឱ្យបានច្រើនក្នុងដំណើរការផ្តល់សេវាកម្មគាំទ្រនានា តាមរយៈការបណ្តុះបណ្តាលបច្ចេកទេសផ្សព្វផ្សាយទស្សនកិច្ចសិក្សាក្នុងនិងក្រៅខេត្ត និងការប្រជុំពិគ្រោះយោបល់ការផ្តល់ចំណេះដឹងផ្នែកទីផ្សារកសិកម្ម ការកែច្នៃកសិផលផ្សេងៗដើម្បីតម្រូវការទីផ្សារ។

-យកចិត្តទុកដាក់លើកកម្ពស់ស្ត្រីឱ្យមានតួនាទីក្នុងជួរថ្នាក់ដឹកនាំការិយាល័យថ្នាក់ខេត្ត និងថ្នាក់ស្រុក

-បានបញ្ជូនមន្ត្រីជាស្ត្រីឱ្យចូលរួមក្នុងក្រុមការងារយេនឌ័រក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទនិងក្នុងគណៈកម្មការស្ត្រី និងកុមារ និងបានបញ្ជូនមន្ត្រីជាស្ត្រីឱ្យចូលរួមវគ្គបណ្តុះបណ្តាលទស្សនកិច្ចសិក្សា កិច្ចប្រជុំ ផ្សេងៗក្នុង និងក្រៅខេត្ត។

### ១.៣.២ ការការពារកុមារក្នុងវិស័យកសិកម្ម

បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាក៏ដូចជា ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ បានយកចិត្តទុកដាក់ខ្ពស់ចំពោះផលប្រយោជន៍ដ៏ឧត្តុងឧត្តមរបស់កុមារ។ កុមារមានសិទ្ធិមានជីវិតរស់នៅសិទ្ធិទទួលការអប់រំរៀនសូត្រសិទ្ធិទទួលការគាំពារក្នុងស្ថានភាពមានសង្គ្រាមនិងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ចកាមគុណលើកុមារ។

ទោះបីជាមានការខិតខំប្រឹងប្រែងពីរាជរដ្ឋាភិបាល ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត ក៏ដូចជាសង្គមស៊ីវិលយ៉ាងណាក៏ដោយកុមារមួយចំនួននៅតែទទួលរងការរំលោភបំពាននិងកេងប្រវ័ញ្ចគ្រប់រូបភាពការប្រើប្រាស់កំលាំងពលកម្មកុមារក្នុងវិស័យកសិកម្មជាដើម។ ដើម្បីចូលរួមចំណែកទប់ស្កាត់ប្រឆាំងរាល់ការងារទាំងឡាយណាដែលប៉ះពាល់ដល់សិទ្ធិរបស់កុមារ មន្ទីរបានបញ្ចូលនូវខ្លឹមសារកិច្ចការពារកុមារទៅក្នុងសកម្មភាពផ្សព្វផ្សាយកសិកម្មនានារបស់មន្ទីរ។ ក្រុមការងារមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវដោយធ្វើការសហការជាមួយអង្គការដៃគូក្នុងខេត្ត និងវិស័យឯកជនធ្វើការគាំពារកុមារតាមគ្រប់រូបភាពពីការប្រើប្រាស់កំលាំងពលកម្មកុមាររួចចាកផុតពីការងាយរងគ្រោះក្នុងវិស័យកសិកម្ម ការកេងប្រវ័ញ្ចកំលាំងពលកម្មដោយធ្វើការអប់រំផ្សព្វផ្សាយដល់គ្រួសារប្រកបរបរកសិកម្ម និងក្រុមហ៊ុនដាំដំណាំកសិកម្មទាំងអស់ដែលពាក់ព័ន្ធវិស័យកសិកម្ម ឱ្យបានយល់ដឹងពីការចូលរួមកិច្ចគាំពារកុមារក្នុងវិស័យកសិកម្ម។ ពន្យល់ណែនាំដល់គ្រួសារកសិករដែលយកកសិកម្មជាមូលដ្ឋានឱ្យយល់ដឹងអំពីរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជាមាត្រាទី ៤៨ “ រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារជាពិសេសសិទ្ធិមានជីវិតរស់នៅសិទ្ធិទទួលការអប់រំរៀនសូត្រសិទ្ធិទទួលការគាំពារក្នុងស្ថានភាពមានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច កាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការ អប់រំ និងការរៀនសូត្ររបស់កុមារឬដែលនាំឱ្យអន្តរាយដល់សុខុមាលភាពរបស់កុមារ ” ។

### ១.៣.៣ សកម្មភាព

- កសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធពីកិច្ចគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម

- បើកវគ្គផ្សព្វផ្សាយស្តីពីកិច្ចគាំពារកុមារ និង អភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម
- លើកកម្ពស់ការយល់ដឹងពីកិច្ចគាំពារ និងអភិវឌ្ឍកុមារ ដល់មាតាបិតាអាណាព្យាបាល និងអ្នកថែរក្សាកុមារ
- បញ្ចូលខ្លឹមសារកិច្ចការពារកុមារក្នុងសកម្មភាពផ្សព្វផ្សាយកសិកម្មនានា
- ចុះពិនិត្យតាមដានការអនុវត្តសកម្មភាពគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម
- រៀបចំឲ្យមានជនបង្គោលសម្រាប់ការងារកុមារនៅតាមអង្គភាពក្រោមឱវាទ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ១.៤ ការប្រែប្រួលអាកាសធាតុ

### ១.៤.១ ផលប៉ះពាល់នៃគ្រោះមហន្តរាយ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

បច្ចុប្បន្នការប្រែប្រួលអាកាសធាតុគឺជាហានិភ័យមួយដែលកំពុងគំរាមកំហែងដល់ការអភិវឌ្ឍគ្រប់វិស័យ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសកសិករក្រីក្រ។ ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុមកលើវិស័យកសិកម្មក្នុងខេត្តបានធ្វើឲ្យប៉ះពាល់ និងខូចខាតផលដំណាំ និងការចិញ្ចឹមសត្វគ្រប់ប្រភេទ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ (២០១១៤-២០១៨) សង្កេតឃើញថាមានគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត និងសត្វល្អិតចង្រៃកើតឡើងជាញឹកញាប់ដែលទាមទារឲ្យអាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គភាពពាក់ព័ន្ធយកចិត្តទុកដាក់ប្រុងប្រយ័ត្ន និងត្រៀម ឧបករណ៍ សម្ភារៈចាំបាច់នានាដើម្បីទប់ទល់ និងស្តារការខូចខាត។ ផ្អែកតាមតារាងខាងក្រោមនេះបានបង្ហាញថាក្នុងរយៈពេល ០៥ឆ្នាំ (២០១៤-២០១៨) កន្លងទៅនេះ ខេត្តតាកែវរងនូវការខូចខាត និងប៉ះពាល់ដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួតជារៀងរាល់ឆ្នាំ និងមានផលប៉ះពាល់ខូចខាតតិចតួច។

**តារាងទី 15 ÷ ផ្ទៃដីខូចខាត និងផ្ទៃដីស្តារឡើងវិញ**

| ការពណ៌នា | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | អត្រាផ្លាស់ប្តូរ (%) ២០១៤-២០១៨ |
|---|---|---|---|---|---|---|---|
| ផ្ទៃដីខូចខាត | ហត | 939 | 1,252 | 336 | 717 | 1,296 | 38.01% |
| ផ្ទៃដីស្តារឡើងវិញ | ហត | 939 | 1,252 | 323 | 39 | 984 | 4.79% |

ផ្ទៃដីខូចខាតដោយទឹកជំនន់ឆ្នាំ២០១៧ និង ឆ្នាំ២០១៨ ផ្ទៃដីខូចខាតមួយចំនួនជាស្រូវដើមរដូវវស្សាធ្វើលើដីស្រូវប្រាំងដែលមិនអាចស្តាឡើងវិញបាន ក្នុងនោះឆ្នាំ២០១៧ ចំនួន៦៧៨ហិកតា និងឆ្នាំ២០១៨ ចំនួន៣១២ហិកតា។




*ក្រាហ្វិក 17. ផ្ទៃដីដំណាំស្រូវរងការខូចខាតដោយគ្រោះធម្មជាតិ និងផ្ទៃដីស្តាឡើងវិញ ឆ្នាំ២០១៤-២០១៨*

### ១.៤.២ សកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

ដើម្បីកាត់បន្ថយការខូចខាតដំណាំកសិកម្ម និងសត្វចិញ្ចឹមគ្រប់ប្រភេទ កន្លងទៅមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានយកចិត្តទុកដាក់អនុវត្តនូវសកម្មភាព និងវិធានការមួយចំនួនដូចខាងក្រោម ÷

លើកកម្ពស់ការយល់ដឹងរបស់កសិករអំពីការត្រៀមបង្ការការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមរយៈផ្សព្វផ្សាយដល់ប្រជាកសិករអំពីហានិភ័យនៃការប្រែប្រួលអាកាសធាតុ (កម្តៅ បរិមាណទឹកភ្លៀង ទឹក ជំនន់ រាំង ស្ងួត) ឲ្យកសិករប្រើប្រាស់ពូជស្រូវសុទ្ធល្អផ្តល់ទិន្នផលខ្ពស់ធន់ទៅនឹងទឹកជំនន់ និងគ្រោះរាំងស្ងួតមានដូចខាងក្រោម ÷

+កំណត់ប្រតិទិននៃការដាំដុះដំណាំគ្រប់ប្រភេទ ដើម្បីបញ្ចៀសការខូចខាតដោយសារទឹកជំនន់

+បង្វែរការដាំដុះស្រូវវស្សានៅតំបន់ដែលរងការលិចលង់ញឹកញាប់មកជាតំបន់ដាំដុះស្រូវដើមរដូវឬស្រូវប្រដេញទឹកវិញ

+ជម្រុញកសិករដាំដុះស្រូវនៅតំបន់ដែលមានទឹកគ្រប់គ្រាន់ (១-២ដង/ឆ្នាំ) នៅតំបន់ដែលខ្វះទឹក (ដីទួល) ជម្រុញឲ្យ កសិករដាំដុះដំណាំរួមផ្សំដែលធន់ទៅនឹងភាពរាំងស្ងួតជំនួសការដាំដុះដំណាំស្រូវវិញ

+បង្វែរការដាំដុះពូជស្រូវដែលមានអាយុវែង មធ្យម មកដាំដុះស្រូវដែលមានអាយុកាលខ្លី នៅតំបន់ដែលមានក្សេត្របរិស្ថានសមស្រប

+ជម្រុញឲ្យកសិករយកចិត្តទុកដាក់ចាក់វ៉ាក់សាំងសត្វគ្រប់ប្រភេទទៅតាមប្រតិទិនដែលកំណត់ដោយជំនាញបសុពេទ្យ

+បង្កើតក្រុមការងារថ្នាក់ខេត្ត ដើម្បីចុះតាមដានស្រង់ស្ថិតិ និងតាមដានវាយតម្លៃផលប៉ះពាល់ខូចខាតដោយគ្រោះរាំងស្ងួត និងទឹកជំនន់ដោយសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់

+ត្រៀមមធ្យោបាយឧបករណ៍សម្ភារៈនានាដើម្បីអន្តរាគមន៍ជួយសង្គ្រោះ និងស្តារការខូចខាតមានជាអាទិ៍ ÷ ស្រូវពូជ ប្រេងឥន្ធនៈ ជីគីមី និងថ្នាំពុលកសិកម្ម។ល។

+បញ្ជ្រាប និងបញ្ចូលបច្ចេកទេសកសិកម្ម ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (រាំងស្ងួត ជំនន់) ទៅក្នុងកម្មវិធីវិនិយោគឃុំ/ សង្កាត់ និងក្នុងកម្មវិធីនានា

+បានចុះធ្វើការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (VRA) នៅភូមិ-ឃុំ ដែលងាយរងគ្រោះដោយទឹកជំនន់ និង រាំងស្ងួត ។

## ១.៥ ភាពអំណោយផល និងបញ្ហាប្រឈម

សកម្មភាព និងលទ្ធផលសម្រេចបានតាមផ្នែកនៃវិស័យកសិកម្មក្នុងខេត្ត បានឆ្លុះបញ្ចាំងឱ្យឃើញនូវភាពអំណោយផល និងបញ្ហាប្រឈមមួយចំនួនក្នុងដំណើរការអនុវត្តសកម្មភាព។ ហើយភាពអំណោយផល និងបញ្ហាប្រឈមទាំងនោះរួមមាន៖

### ១.៥.១ ភាពអំណោយផល

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានយុទ្ធសាស្រ្តគោលនយោបាយច្បាស់លាស់

-រាជរដ្ឋាភិបាលបានបង្កភាពងាយស្រួល និងគោលនយោបាយលើកទឹកចិត្តដល់អ្នកវិនិយោគគ្រឿងយន្ត ឧបករណ៍ និង សម្ភារៈកសិកម្ម

-មានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ (ច្បាប់ស្តីពីអភិវឌ្ឍន៍សហគមន៍កសិកម្ម ច្បាប់គ្រប់គ្រងជី និង ថ្នាំពុលកសិកម្ម អនុក្រឹត្យ សារាចរណែនាំ ប្រកាស ) ជួយតម្រង់ទិសឱ្យមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ អនុវត្តការងារបានត្រឹមត្រូវ និង មានប្រសិទ្ធភាព។

-មានផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍រយៈពេលវែង មធ្យម និងប្រចាំឆ្នាំ

-ធនធានអ្នកបច្ចេកទេសបម្រើឲ្យផលិតកម្មកសិកម្មកាន់តែមានសមត្ថភាព និងបទពិសោធន៍ល្អប្រសើរដែលជាកត្តាអាចជួយបង្កើនសមត្ថភាពផ្តល់សេវាកម្មឲ្យបានកាន់តែមានប្រសិទ្ធភាព

-កសិករបានជឿជាក់លើសារៈសំខាន់នៃការអនុវត្តបច្ចេកទេសកសិកម្មទំនើប និងផ្លាស់ប្តូរទំលាប់លើការធ្វើកសិកម្មសម្រាប់ហូបចុកមកធ្វើកសិកម្មសម្រាប់លក់ដូរ

-មានថវិកាមធ្យោបាយ សម្ភារៈ ឯកសារបច្ចេកទេសបម្រើឱ្យការផ្តល់សេវាកម្ម និងការអភិវឌ្ឍន៍

-មានការកើនឡើងនៃការប្រើប្រាស់គ្រឿងយន្តកសិកម្ម និងសម្ភារៈកសិកម្ម (ពូជ ជីគីមី និងថ្នាំពុល)

-មានការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍ និងការចូលរួមពីផ្នែកឯកជនលើការវិនិយោគផ្នែកដាំដុះ ចិញ្ចឹមសត្វ និងការនាំចូលនូវសម្ភារៈ និងធាតុចូលកសិកម្មគ្រប់ប្រភេទ និងមានបមាណីយច្បាស់លាស់ត្រឹមត្រូវ

-ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យការងារកសិកម្ម ត្រូវបានកែលម្អជាបន្តបន្ទាប់

-មានទីផ្សារលក់ផលិតផល

-មានការគាំទ្រពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងមន្ទីរជំនាញដែលពាក់ព័ន្ធ

-ធនធានធម្មជាតិ អំណោយផលដល់ការដាំដុះដំណាំគ្រប់ប្រភេទ និងការចិញ្ចឹមសត្វ

-មានវិទ្យុ FM ប្រចាំខេត្ត ជួយសម្រួលដល់ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មជូនដល់កសិករ។

### ១.៥.២ បញ្ហាប្រឈម

ពិតមែនតែលក្ខណៈភូមិសាស្រ្តខេត្តតាកែវ មានលក្ខណៈអំណោយផលល្អប្រសើរដល់ការបង្កបង្កើនផល និងការចិញ្ចឹមសត្វ ហើយសេវាសាធារណៈត្រូវបានពង្រឹង និងពង្រីកយ៉ាងណាក៏ដោយក៏នៅមានការលំបាកជាច្រើនដែលធ្វើឱ្យការអភិវឌ្ឍវិស័យកសិកម្មពុំទាន់ឈានដល់កម្រិតសមស្របនៅឡើយ។ ការលំបាកដែលជួបប្រទះលើវិស័យកសិកម្មក្នុងខេត្តរួមមាន ៖

-ការប្រែប្រួលអាកាសធាតុ ភ្លៀងធ្លាក់ពុំទៀងទាត់ ពុំសព្វទីកន្លែង គ្រោះរាំងស្ងួតបានអូសបន្លាយ និងគ្រោះទឹកជំនន់តែងកើតឡើងជាញឹកញាប់ព្រមជាមួយការឡើងកំដៅបរិយាកាស និងសត្វល្អិតចង្រៃបំផ្លាញដំណាំ។

-ខ្វះកម្លាំងពលកម្មបម្រើឲ្យផលិតកម្មកសិកម្មក្នុងគ្រួសារ។

-ទុន និងថ្លៃដើមផលិតកម្មខ្ពស់ (ពូជ ជី ថ្នាំ ការភ្ជួររាស់ ឈ្នួលពលកម្ម...) ប៉ុន្តែតម្លៃកសិផលចុះថោក និងប្រែប្រួលពុំទៀងទាត់។

-អាងស្តុកទឹក ឬប្រភពទឹកមិនទាន់គ្រប់គ្រាន់សំរាប់ស្រោចស្រព

-ការចិញ្ចឹមសត្វតែងតែជួបប្រទះនូវជម្ងឺផ្សេងៗ និងខ្វះចំណីអាហារដែលធ្វើឲ្យសត្វឈឺ និងងាប់

-ទុនផលិតកម្មមានតម្លៃខ្ពស់ (ចំណី ថ្នាំ) និងតម្លៃសត្វរស់មានការប្រែប្រួលមិនទៀងទាត់។

-មធ្យោបាយ សម្ភារៈ ថវិកា នៅមានកម្រិតធ្វើឱ្យការជួយអន្តរាគមន៍ពុំទាន់ឆ្លើយតបបានទាំងស្រុង និងពុំទាន់មានប្រសិទ្ធភាពខ្ពស់នៅឡើយ។

-ចំនួនមន្ត្រីបច្ចេកទេសដែលកំពុងបម្រើការងារនៅតាមការិយាល័យមានចំនួនតិច ពុំទាន់ឆ្លើយតបតាមវិសាលភាពការងារ។ ជាក់ស្តែងនៅតាមការិយាល័យមួយចំនួនមានតែប្រធាន និងអនុប្រធានឬមានតែប្រធានមួយរូបបំពេញការងារគ្រប់បែបយ៉ាងនៅក្នុងការិយាល័យដែលទាមទារចាំបាច់នូវមន្ត្រីបច្ចេកទេសបន្ថែមយ៉ាងតិចណាស់ក៏ពី ៤-៥រូប ដើម្បីបំពេញការងារបានសមស្រប។

-ថ្នាំកសិកម្មជីគីមីគ្រប់ប្រភេទដែលដាក់តាំងលក់នៅលើទីផ្សារទីរួមខេត្ត ស្រុកសុទ្ធសឹងតែនាំចូលមកពីបរទេសហើយស្លាកសញ្ញាដែលបិទលើសំបកដប ធុង កំប៉ុងឬសំបកកញ្ចប់បាវមានសរសេរជាអក្សរខ្មែរតិចតួចដែលធ្វើឱ្យកសិករភាគច្រើនមិនអាចអាននូវព័ត៌មានស្លាកសញ្ញាទាំងនោះបាន។ ផលិតផលមួយចំនួនដែលកំពុងដាក់លក់លើទីផ្សារជាផលិតផលក្លែងគុណភាពពុំមានប្រភពច្បាស់លាស់ដែលធ្វើឱ្យកសិករទទួលបាននូវផលអវិជ្ជមាន ខាតបង់ថវិកាឥតប្រយោជន៍ដោយសារការប្រើប្រាស់ផលិតផលក្លែងបន្លំគុណភាពទាំងនោះធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្ស សត្វ ដំណាំ ទឹក និងដី។

-ធនធាន និងសមត្ថភាពមន្ត្រីគ្រប់គ្រងសម្ភារៈកសិកម្ម របស់ការិយាល័យនីតិកម្មនៅមានកម្រិតទាប។

-ខ្វះមធ្យោបាយ និងឧបករណ៍ ដើម្បីធ្វើតេស្ត សម្ភារៈកសិកម្ម ដែលកំពុងធ្វើចរាចរដាក់តាំងលក់

-បច្ចេកទេសក្រោយពេលប្រមូលផលនៅមានការអភិវឌ្ឍន៍យឺត

-ការបាត់បង់ក្រោយពេលប្រមូលផលមានអត្រាខ្ពស់

-តម្លៃកសិផលប្រែប្រួលពុំទៀងទាត់ និងធ្លាក់ចុះខ្លាំងនៅរដូវប្រមូលផល។

## ១.៦ ការវាយតម្លៃលទ្ធផល និងសេចក្តីសន្និដ្ឋាន

ផ្អែកតាមលទ្ធផលសម្រេចបានក្នុងរយៈពេល៥ឆ្នាំ (២០១៤-២០១៨) យើងអាចសន្និដ្ឋានបានថាការអភិវឌ្ឍន៍កសិកម្មក្នុងខេត្ត ទោះបីជាមានការប្រឈមទៅនឹងគ្រោះធម្មជាតិ (ភាពរាំងស្ងួត ទឹកជំនន់ និងសត្វល្អិតបំផ្លាញក្នុងឆ្នាំខ្លះ) ប៉ុន្តែដោយមានការយកចិត្តទុកដាក់ពីមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ និងការច្នៃប្រឌិតពីកសិករផ្ទាល់ធ្វើឱ្យកសិករបានទទួលផលល្អក្នុងការងារដាំដុះ និងធ្វើឲ្យផលិតកម្មកសិកម្មមានវឌ្ឍនភាពគួរជាទីមោទនៈ។

ផលិតកម្មស្រូវរយៈពេល ៥ឆ្នាំ (២០១៤-២០១៨) ពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងជាលំដាប់ទាំងផ្ទៃដីដាំដុះ ទិន្នផល បរិមាណផល និងអតិរេក ប៉ុន្តែដោយឡែកបរិមាណផលស្រូវសរុបឆ្នាំ ២០១៨-២០១៩ កើនដល់ត្រឹម ១ ១៨៣ ៨៩៨តោន គឺកើនច្រើនជាងឆ្នាំ២០១៤ ចំនួន៦៨ ១៧៦តោន។ចំពោះតុល្យភាពស្បៀងឆ្នាំ២០១៨-២០១៩ ខេត្តនៅសល់ស្រូវ

ស្បៀងសម្រាប់នាំចេញចំនួន៨០២ ៩៥០តោន គឺច្រើនជាងឆ្នាំ២០១៤ ចំនួន៤៥ ៩៩៨តោន ការកើនឡើងនេះគឺ បណ្ដាលមកពីអាកាសធាតុអំណោយផលជាងឆ្នាំមុន ការយល់ដឹងពីរបច្ចេកទេសកសិកម្មដែលកសិករភាគច្រើនបានទទួលការបណ្តុះបណ្ដាលបច្ចេកទេសពីរមន្ត្រីជំនាញនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ផលិតកម្មដំណាំរួមផ្សំ ដំណាំឧស្សាហកម្ម មានការរីកចម្រើនគួរឲ្យកត់សម្គាល់។ ជាក់ស្តែងក្នុងឆ្នាំ២០១៨ ផ្ទៃដីដាំដុះអំពៅ មានរហូតដល់ ៣៧៦ ហ.ត ដំឡូងមី ១ ៨១០ ហ.ត ពោត ២៧៦ ហ.ត និង បន្លែគ្រប់មុខ ២ ៦៦៨ ហ.ត។ ចំពោះផលិតកម្មសត្វ ជាពិសេសជ្រូក បក្សីមានការវិវឌ្ឍន៍ជាវិជ្ជមានគួរឲ្យកត់សម្គាល់។ ស្ថិតិគោ-ក្របី មានការប្រែប្រួលដោយសារ កសិករបានបង្វែរពីការប្រើប្រាស់គោ-ក្របីជាកំលាំងអូសទាញមកប្រើប្រាស់គ្រឿងយន្តកសិកម្មជំនួសវិញ។ ដោយឡែកការ ងារផលិតកម្ម និងបសុព្យាបាលក៏មានដំណើរការល្អដោយការចិញ្ចឹមមានការរីកចំរើនដែរប្រជាកសិករមានការកែប្រែទម្លាប់ ក្នុងការចិញ្ចឹមសត្វតាមបច្ចេកទេស និងការបង្កាត់សិប្បនិម្មិត ជ្រូក គោ ជាមួយគ្នានេះដែរក្នុងឆ្នាំ ២០១៨ ពុំមានកើតឡើង នូវជំងឺអ្វីគួរឲ្យកត់សម្គាល់ឡើយ ឯបរិមាណសត្វ និងស៊ុតសត្វអាចធានាបានការផ្គត់ផ្គង់ក្នុងខេត្ត និងនៅសល់សំរាប់នាំចេញទៅក្រៅខេត្តទៀតផង។

ចំពោះការគ្រប់គ្រងសម្ភារៈកសិកម្ម កសិករកាន់តែមានការយល់ដឹងក្នុងការប្រើប្រាស់សម្ភារៈកសិកម្ម តាមក្បួនខ្នាតដែលរួមចំណែកក្នុងការជម្រុញឱ្យផលិតកម្មមានការកើនឡើង។ដោយឡែកចំពោះការធ្វើអាជីវកម្មសម្ភារៈកសិកម្មចំនួនអាជីវករ ដែលមានច្បាប់អនុញ្ញាតមានការកើនឡើងជាលំដាប់ដែលបានឆ្លុះបញ្ចាំងឱ្យឃើញអំពីកាគ្រប់គ្រង សម្ភារៈកសិកម្មក្នុងខេត្ត កាន់តែមានភាពល្អប្រសើរដែរ។

ជាងនេះទៀតផ្នែកសេវាកម្ម និងការគាំទ្រតាមផ្នែកផ្សេងៗ ក៏សម្រេចបានលទ្ធផលការងារល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់។ ប៉ុន្តែទោះបីយ៉ាងណាក្តី មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត នៅមានកិច្ចការជាច្រើនដែលត្រូវអនុវត្តបន្តទៀតដើម្បីរួមចំណែកក្នុងកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល។

# ផ្នែកទី២
# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មខេត្តតាកែវ ឆ្នាំ២០១៩-២០២៣

## ២.១ សេចក្តីផ្តើម

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មរយៈពេលប្រាំឆ្នាំ ២០១៩-២០២៣ របស់មន្ទីរកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ បានរៀបចំឡើងស្របតាមទិសដៅ និងគោលនយោបាយរបស់រដ្ឋាភិបាល ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ខេត្ត កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខេត្ត និងជាពិសេសស្របតាមសក្តានុពលស្ថានភាពភូមិសាស្ត្រ សេចក្តីត្រូវការ និងបញ្ហាដែលកើតមានឡើងក្នុងវិស័យកសិកម្មខេត្ត។

ផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត នឹងផ្តោតលើទំនើបកម្មកសិកម្មឲ្យមានលក្ខណៈប្រកួតប្រជែងបរិយាប័ន្នធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាពបង្កើនប្រាក់ចំណូលដល់កសិករ វិបុលភាព និងសុខមាលភាពរបស់ប្រជាពលរដ្ឋតាមអភិក្រម និងវិសាលភាពថ្មីដើម្បីប្រែក្លាយវិស័យកសិកម្មពីដំណាក់កាលនៃការអភិវឌ្ឍន៍តាមបែបវិបុលកម្មគឺពឹងផ្អែកសំខាន់លើធនធានដែលមានស្រាប់ឈានទៅរកដំណាក់កាលថ្មី ដែលផ្តោតលើប្រពលវប្បកម្មគឺពឹងផ្អែកសំខាន់លើបច្ចេកទេស បច្ចេកវិទ្យាថ្មីកសិកម្មវៃឆ្លាតស្រាវជ្រាវ និងការអភិវឌ្ឍន៍យន្តូបនីយកម្ម ព្រមទាំងបង្កើនសមត្ថភាពស្រោចស្រពដើម្បីលើកកម្ពស់ផលិតភាព ពិពិធកម្មដំណាំដែលមានសក្តានុពល និងទីផ្សារ រួមទាំងការចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្ម។

ក្នុងន័យនេះដើម្បីសម្រេចបាននូវទិសដៅអភិវឌ្ឍន៍វិស័យកសិកម្មក្នុងអាណត្តិទី៦នេះមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត បានកំណត់ទិសដៅ និងផែនការយុទ្ធសាស្ត្របន្តជម្រុញកំណើនផលិតកម្មកសិកម្មប្រកបដោយការប្រកួតប្រជែងផលិតផលមានគុណភាពសុវត្ថិភាព និងអាហារូបត្ថម្ភព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដីព្រៃឈើ និងជលផលប្រកបដោយចីរភាព ។

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមានភារកិច្ចជាច្រើនដែលនឹងត្រូវអនុវត្តផែនការយុទ្ធសាស្ត្រនិងសម្រេចឲ្យបានលទ្ធផលជាក់ស្តែងនាពេលខាងមុខ ជាពិសេសដើម្បីសម្រេចបាននូវទិសដៅខាងលើគ្រប់ផ្នែក ជំនាញពាក់ពន្ធ័នានាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្មរុក្ខាប្រាមាញ់ និងនេសាទខេត្តត្រូវខិតខំអនុវត្តការងារឲ្យបានសកម្ម និងខ្លាំងក្លានូវសកម្មភាពទាំងឡាយដូចបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រនេះឲ្យសម្រេចបាននូវសមិទ្ធផល ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ។

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត អនុវត្ត និងប្រែក្លាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មនេះឲ្យទៅជាសកម្មភាពអនុវត្តជាក់ស្តែងតាមរយៈការខិតខំបង្កើន និងប្រើប្រាស់ធនធានដែលមានស្រាប់ព្រមទាំងគៀងគរធនធានពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជននានាក៏ដូចជាការធ្វើសមាហរណកម្មឲ្យតួអង្គពាក់ពន្ធ័សំខាន់ៗទាំងអស់ចូលរួមអនុវត្តឲ្យសម្រេចបាននូវសមិទ្ធផលប្របកដោយគុណភាពមានប្រសិទ្ធភាពខ្ពស់។

ក្នុងនាមមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្ត សង្ឃឹមយ៉ាងមុតមាំគ្រប់ស្ថាប័នពាក់ពន្ធ័អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ពិតជាចូលរួមសហការអនុវត្តសកម្មភាពការងារពិសេសដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនបន្តចូលរួមចំណែកទាំងធនធានហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីរួមចំណែកជួយទ្រទ្រង់ដល់ដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ នេះបានលទ្ធផលផ្លែផ្កាជាវិជ្ជមាន និងប្រកបដោយប្រសិទ្ធភាពតាមផែនការ និងការរំពឹងទុក ។

ទន្ទឹមនេះដែរសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រដល់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់មន្ត្រីរាជការទាំងអស់របស់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តដែលតែងតែយកចិត្តទុកដាក់ផ្ដល់ការគាំទ្រ និងចូលរួមចំណែកយ៉ាងសកម្មក្នុងការកសាងផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣នេះ និងប្ដេជ្ញាចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអនុវត្តដើម្បីសម្រេច បាននូវគោលដៅកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍ខេត្តនាពេលអនាគតប្រកបដោយជោគជ័យ ។

## ២.២ ចក្ខុវិស័យ

ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រធានាឲ្យមានស្បៀងអាហារគ្រប់គ្រាន់ ប្រកបដោយសុវត្ថិភាពសម្រាប់ពលរដ្ឋគ្រប់រូបតាមរយៈការធ្វើទំនើបកម្មការងារកសិកម្មផ្អែកលើអភិក្រមថ្មីមួយ និងការផ្លាស់ប្ដូរទៅលើវិសាលភាព និងជំហានដើម្បីពន្លឿនកំណើនសេដ្ឋកិច្ចវិស័យកសិកម្ម និងការគ្រប់គ្រងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

## ២.៣ បេសកកម្ម

គាំទ្រដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជាតាមរយៈការផ្ដល់សេវាប្រកបដោយគុណភាពខ្ពស់ដែលនាំឱ្យធានាបាននូវការផ្គត់ផ្គង់ស្បៀងអាហារប្រកបដោយសុវត្ថិភាពទិន្នផលកសិកម្មមានការកើនឡើង និងបន្ថែមតម្លៃក្រោមមូលដ្ឋានមួយប្រកបដោយនិរន្តរភាព មានប្រសិទ្ធភាព និងគុណភាពខ្ពស់ចំពោះវិស័យដែលមានមូលដ្ឋានផ្អែកលើកសិកម្ម ជលផល និងរុក្ខាប្រមាញ់។

## ២.៤ គោលដៅយុទ្ធសាស្ត្រ

ដើម្បីរួមចំណែកក្នុងការសម្រេចបានចក្ខុវិស័យ ដែលបានកំណត់ជាយុទ្ធសាស្ត្ររួមសំរាប់អនុវត្តគឺ ជម្រុញកំណើន ***កសិកម្មប្រកបដោយភាពប្រកួតប្រជែងផលិតផលមានគុណភាពសុវត្ថិភាព និងអាហារូបត្ថម្ភព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព។***

វិស័យកសិកម្ម នៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមការអភិវឌ្ឍន៍ជនបទ ជាពិសេសបានចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ កំណើនកសិកម្មត្រូវរីកលូតលាស់ និងត្រូវបានវាស់វែងដោយអត្រាកំណើនតម្លៃបន្ថែមសរុបរបស់វិស័យកសិកម្ម។

## ២.៥ គាំទ្រយុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្មក្រសួង

រួមចំណែកជម្រុញកំណើនផលិតកម្មកសិកម្មឱ្យបានក្នុងរង្វង់ប្រមាណ០៥%ក្នុងមួយឆ្នាំ តាមរយៈការលើកកម្ពស់ផលិតភាពពិពិធភាវូបនីយកម្ម និងការធ្វើពាណិជ្ជូបណីកម្មកសិកម្ម និងលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្មយកចិត្តទុកដាក់ខ្ពស់ទៅលើការការពារ និងគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រខាងលើ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត អនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ទាំង៥ រួមមាន ÷

**-កម្មវិធីទី ១ ÷ ការបង្កើនផលិតភាព ពិពិធកម្មកសិកម្ម និងកសិធុរៈកិច្ច**

**-កម្មវិធីទី ២÷ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ**

**-កម្មវិធីទី ៣÷ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍន៍វារីវប្បកម្ម**

**-កម្មវិធីទី ៤÷ ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ**

**-កម្មវិធីទី ៥÷ ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ៕**

## ២.៥.១ កម្មវិធីទី១÷ បង្កើនផលិតភាពពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច

### ២.៥.១.១ អនុកម្មវិធីទី១.៩ ÷ ការជម្រុញផលិតកម្មដំណាំកសិកម្ម និងកសិធុរកិច្ច

**ក. គោលបំណង÷**

ចូលរួមចំណែកជម្រុញខ្សែច្រវាក់ផលិតកម្ម តាមរយៈការបង្កើនផលិតភាព គុណភាពពិពិធកម្មដំណាំ ពាណិជ្ជូបនីយកម្មកសិកម្មគ្រប់ប្រភេទ និងជម្រុញកសិ-ឧស្សាហកម្មកែច្នៃដំណាំកសិកម្ម ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងបម្រើឲ្យការនាំចេញផលិតផលដំណាំកសិកម្ម តាមរយៈធ្វើផលិតកម្មតាមកិច្ចសន្យា។

**ខ. សូចនាករ**

**តារាងទី 16÷ សូចនាករ នៃអនុកម្មវិធីទី១ថ្នាក់ខេត្ត**

| សូចនាករ | ឯកតា | គោលដៅ (Target) | | | | |
|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| ១. ផលិតផលដំណាំកសិកម្ម | តោន | 1,493,060 | 1,509,814 | 1,526,652 | 1,543,574 | 1,560,582 |
| ២. អនុបាត (%) នៃពិពិធកម្មដំណាំ(3%) | % | 33.54 | 34.55 | 35.58 | 36.65 | 37.75 |
| ៣.ផលិតផលដំណាំកសិកម្មត្រូវបានកែច្នៃ | តោន | 9,118 | 9,574 | 10,053 | 10,556 | 11,083 |

**គ. ចង្កោមសកម្មភាពទី១÷ ១.៩.១.២១ ការលើកកម្ពស់ខ្សែច្រវាក់តម្លៃដំណាំកសិកម្ម**

**-គោលបំណង÷** ជម្រុញខ្សែច្រវាក់ផលិតកម្មដំណាំកសិកម្មតាមរយៈការបង្កើនផលិតកម្មដំណាំស្រូវ ដំណាំសាកវប្បកម្ម ដំណាំឧស្សាហកម្ម និងដំណាំកៅស៊ូឆ្នាំ។

**-សូចនាករ**

**តារាងទី 17÷ សូចនាករ នៃចង្កោមសកម្មភាព នៃអនុកម្មវិធីទី១**

| សូចនាករ | ឯកតា | គោលដៅ (Target) | | | | |
|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| ១. ផលិតកម្មដំណាំស្រូវ(1%) | តោន | 1,208,650 | 1,220,737 | 1,232,823 | 1,244,910 | 1,256,996 |
| ២. ផលិតកម្មដំណាំសាកវប្បកម្ម(2%) | តោន | 182,366 | 186,013 | 189,734 | 193,528 | 197,399 |
| ៣. ផលិតកម្មដំណាំឧស្សាហកម្ម(1%) | តោន | 102,044 | 103,064 | 104,095 | 105,136 | 106,187 |
| ៤. ផលិតកម្មដំណាំកៅស៊ូ | តោន | 0 | 0 | 0 | 0 | 0 |

**ឃ. សកម្មភាព**

**សកម្មភាពទី១ ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសក្នុងផលិតកម្មកសិកម្ម (នាក់)**

-ផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដុះដំណាំស្រូវតាមបែបពិពិធកម្ម នៅតំបន់ដែលមានប្រភពទឹក

-ផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដុះដំណាំរួមផ្សំគ្រប់ប្រភេទនៅតំបន់ដែលមានសក្តានុពល និងមានអំណោយផលល្អវិលជុំពេញមួយឆ្នាំ

-បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសទំនើបកម្មកសិកម្ម

-ផ្ដល់វគ្គបណ្ដុះបណ្ដាលអំពីបច្ចេកទេសគ្រប់គ្រងដីជាតិដី តាមរយៈការប្រើប្រាស់ជីលាមកសត្វកំទេចកំទីសំរាមជុំវិញផ្ទះ ការប្រើប្រាស់ជីគីមី ការដាំដំណាំឆ្លាស់ ដាំដំណាំចន្លោះរង និងដំណាំគ្របដី

-ផ្សព្វផ្សាយអំពីវិធានការការពា និងការកម្ចាត់សត្វល្អិតចង្រៃ និងជំងឺ

-ផ្សព្វផ្សាយអំពីប្រភេទពូជស្រូវទំនើបដែលមានសក្ដានុពលតាមការណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-រៀបចំបណ្ដុំកសិករ និងបើកវគ្គបណ្ដុះបណ្ដាលបច្ចេកទេសផលិតពូជស្រូវសម្រាប់នាំចេញ

-ផ្សព្វផ្សាយជូនប្រជាកសិករបច្ចេកទេសការផលិតជីកំប៉ុស្ដិ៍ និងការប្រើប្រាស់ជីកំប៉ុស្ដិ៍

-រៀបចំបណ្ដុំកសិករដាំបន្លែ និងបើកវគ្គផលិតកម្មបន្លែសរីរាង្គសម្រាប់នាំចេញនៅលើទីផ្សារ

-បណ្ដុះបណ្ដាលបច្ចេកទេសរៀបចំដីដោយគ្រឿងយន្តកសិកម្ម

-ធ្វើបង្ហាញការដាំបន្លែដោយប្រើបច្ចេកទេសប្រព័ន្ធដំណក់ទឹក និងផ្ទះសំណាញ់

-ធ្វើទិវាស្រែបង្ហាញ និងទស្សនកិច្ចសិក្សា

-ពង្រឹង និងបណ្ដុះបណ្ដាលកសិករគំរូឲ្យក្លាយទៅជាភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ

**សកម្មភាពទី២÷ ការផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលបច្ចេកទេសក្រោយពេលប្រមូលផល និងការកែច្នៃ (នាក់)**

-បណ្ដុះណ្ដាលបច្ចេកទេសក្រោយពេលប្រមូលផល

-ទស្សនកិច្ចសិក្សាពីការដាំដុះដែលធន់ទៅនឹងបំរែបំរួលអាកាសធាតុ (ដាំដុះបន្លែ ស្រូវ ពូជធន់)

-ប្រជុំផ្លាស់ប្ដូរបទពិសោធន៍កសិកម្ម ពីកសិករ ទៅកសិករ

-វគ្គកែឆ្នៃផលិតផលកសិកម្ម

**សកម្មភាពទី៣÷ ការពង្រឹងសមត្ថភាពសហគមន៍កសិកម្ម (ចំនួនសហគមន៍)**

-ផ្សព្វផ្សាយពីសារប្រយោជន៍នៃការបង្កើតសហគមន៍កសិកម្ម និងជម្រុញការបង្កើតសហគមន៍កសិកម្ម

-ពង្រឹងសហគមន៍កសិកម្មដែលមានស្រាប់តាមរយៈការប្រជុំប្រចាំខែ ត្រីមាស ប្រចាំឆ្នាំ និងបណ្ដុះ បណ្ដាលផែនការជំនួញភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងបញ្ជីស្នាម

-ចងក្រងសហគមន៍កសិកម្មឲ្យទៅជាសភាពសហគមន៍កសិកម្ម

**សកម្មភាពទី៤÷ ការសម្របសម្រួលយន្តការទីផ្សារ (ចំនួនកិច្ចសន្យា)**

-ផ្សព្វផ្សាយ និងបើកវគ្គបណ្ដុះបណ្ដាលផលិតកម្មតាមកិច្ចសន្យា

-វេទិការទីផ្សារ កសិកម្មថ្នាក់ខេត្ត និងថ្នាក់ស្រុក

-ជម្រុញការចុះការកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា

### ២.៥.២ កម្មវិធីទី២÷ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ

#### ២.៥.២.១ អនុកម្មវិធីទី២.៤ ÷ ការជម្រុញផលិតកម្មសត្វ និងសុខភាពសត្វ

**ក. គោលបំណង÷**

ចូលរួមចំណែកជម្រុញការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម ការធ្វើឱ្យប្រសើរឡើងនូវសុខភាពសត្វ និងជម្រុញការកែច្នៃផលិតផលសាច់សត្វ។

### ខ. សូចនាករ

**តារាងទី 18÷ សូចនាករ នៃអនុកម្មវិធីទី២ (ថ្នាក់ខេត្ត)**

| សូចនាករ | ឯកតា | គោលដៅ (Target) | | | | |
|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| ១. ផលិតផលសាច់សរុបកើន 0,44% ឆ្នាំ | តោន | 225 | 226 | 227 | 228 | 229 |
| ២. អត្រានៃការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មកើនឡើង | % | 50 | 55 | 60 | 65 | 70 |
| ៣. កាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅត្រឹម 3% | % | 3 | 3 | 3 | 3 | 3 |

### គ. ចង្កោមសកម្មភាពទី១ ÷ ២.៤.១.២១ ការជម្រុញការចិញ្ចឹមសត្វលើកកម្ពស់សុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល

**-គោលបំណង÷** បង្កើនផលិតកម្មសត្វជាលក្ខណៈពាណិជ្ជកម្ម ជម្រុញការចិញ្ចឹមគោកូនកាត់ដែលមានផលិតភាពខ្ពស់ការចាក់វ៉ាក់សាំង គោ ក្របី និងជម្រុញការកែលម្អសត្តឃាតដ្ឋានស្របតាមបទដ្ឋានបច្ចេកទេស។

**-សូចនាករ**

**តារាងទី 19÷សូចនាករ នៃចង្កោមសកម្មភាព នៃអនុកម្មវិធីទី២**

| សូចនាករ | ឯកតា | គោលដៅ (Target) | | | | |
|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| ១. ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មកើនឡើង | ក្បាល | 160,590 | 168,620 | 177,051 | 185,904 | 195,199 |
| ២. គោកូនកាត់មានផលិតភាពខ្ពស់កើនឡើង | ក្បាល | 224,825 | 236,067 | 247,870 | 260,264 | 273,277 |
| ៣. សត្តឃាតដ្ឋានដែលអនុវត្តតាមបទដ្ឋានបច្ចេកទេស (GAHP) | ចំនួនសត្តឃាត | 1 | 2 | 3 | 4 | 5 |

### ឃ. សកម្មភាព

**សកម្មភាពទី១÷ ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសផលិតកម្មសត្វ (បង្កាត់ ចំណី ...) (ចំនួននាក់)**

-បណ្តុះបណ្តាលបច្ចេកទេសដាំដំណាំចំណីសត្វ កែច្នៃ និងផ្សំចំណីសត្វ

-ផ្សព្វផ្សាយការបង្កាត់ពូជសត្វដែលមានផលិតភាពខ្ពស់ (សិប្បនិម្មិត)

-ចងក្រងក្រុមកសិករចិញ្ចឹមសត្វ និងបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វគ្រប់ប្រភេទ

**សកម្មភាពទី២÷ ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសបសុព្យាបាល (ចំនួននាក់)**

-ពង្រឹងសមត្ថភាពភ្នាក់ងារសុខភាពសត្វភូមិ

-បណ្តុះបណ្តាលអាជីវករលក់បសុឱសថ បរិក្ខាបសុពេទ្យ និងចំណីសត្វ

**សកម្មភាពទី៣÷ ការចុះអន្តរាគមន៍ការពារ និងទប់ស្កាត់ជម្ងឺឆ្លងសត្វ (ចំនួនលើក)**

-យុទ្ធនាការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វគ្រប់ប្រភេទ

-ចុះធ្វើជីវសុវត្ថិភាព

**សកម្មភាពទី៤÷ ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសអនាម័យសត្វ និងសាច់សត្វ (ចំនួននាក់)**

-ផ្សព្វផ្សាយដល់អាជីវករពិឃាដសត្វ និងលក់សាច់សត្វឲ្យអនុវត្តតាមបទដ្ឋានបច្ចេកទេសអនាម័យសាច់សត្វ

**សកម្មភាពទី៥÷ ការផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់ (ចំនួននាក់)**

-ផ្សព្វផ្សាយច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា។

-ចុះតាមដានការអនុវត្តកែលម្អសត្តឃាតដ្ឋានអនាម័យសាច់ និងកន្លែងតាំងលក់ស្របតាមបទដ្ឋានបច្ចេកទេស

-ផ្សព្វផ្សាយច្បាប់ និងចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វខ្នាតតូច និងមធ្យម

## ២.៥.៣ កម្មវិធីទី៣÷ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

### ២.៥.៣.១ អនុកម្មវិធីទី៣.៤÷ ការពង្រឹងការគ្រប់គ្រងធនធានជលផល និងការជម្រុញវារីវប្បកម្ម

**ក. គោលបំណង÷**

ចូលរួមចំណែកពង្រឹងការគ្រប់គ្រងនិងអភិរក្សធនធានជលផល ជម្រុញការអភិវឌ្ឍន៍វារីវប្បកម្ម និងសហគមន៍នេសាទ មានកម្រិតជីវភាពកាន់តែប្រសើរឡើង។

**ខ. សូចនាករ**

**តារាងទី 20÷ សូចនាករ នៃអនុកម្មវិធីទី៣ (ថ្នាក់ខេត្ត)**

| សូចនាករ | ឯកតា | គោលដៅ (Target) | | | | |
|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| ១. ផលនេសាទចាប់ពីធម្មជាតិ | តោន | 25,900 | 28,000 | 28,000 | 28,000 | 28,000 |
| ២. អត្រាកំណើនផលវារីវប្បកម្ម | % | 8 | 8 | 8 | 8 | 8 |
| ៣. ចំណូលរបស់សហគមន៍នេសាទ | % | 1 | 1 | 1 | 1 | 1 |

**គ. ចង្កោមសកម្មភាព១ ÷ ៣.៤.១.២១ ÷ ការការពារធនធានជលផល និងការអភិវឌ្ឍខ្សែច្រវាក់តម្លៃផលជលផល**

**-គោលបំណង÷** ជម្រុញការគ្រប់គ្រងនិងអភិរក្សធនធានជលផល បង្កើនផលវារីវប្បកម្ម និងជម្រុញការកែច្នៃផលជលផល។

**-សូចនាករ**

**តារាងទី 21÷សូចនាករ នៃចង្កោមសកម្មភាព នៃអនុកម្មវិធីទី៣**

| សូចនាករ | ឯកតា | គោលដៅ (Target) | | | | |
|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| ១. សហគមន៍នេសាទត្រូវបានពង្រឹង និងគ្រប់គ្រង | ចំនួន | 6 | 8 | 10 | 12 | 14 |
| ២. បរិមាណផលវារីវប្បកម្ម | តោន | 17,870 | 19,299 | 20,843 | 22,511 | 23,311 |
| ៣. បរិមាណផលកែច្នៃផលជលផល | តោន | 205 | 205 | 205 | 205 | 205 |

**ឃ.សកម្មភាព**

**សកម្មភាពទី១÷ ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសវារីវប្បកម្ម និងការកែច្នៃផលជលផល (ចំនួននាក់)**

-រៀបចំ និងពង្រឹងបណ្តាញកសិករផលិតពូជ

-បណ្តុះបណ្តាលកសិករផលិតពូជ និងចិញ្ចឹមបង្កង

-បណ្តុះបណ្តាលបច្ចេកទេសវារីវប្បកម្ម

-ចុះគាំទ្របច្ចេកទេសដល់កសិករធ្វើវារីវប្បកម្ម

-ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍

-ចុះត្រួតពិនិត្យ តាមដាន និងវាយតំលៃការអនុវត្តសកម្មភាព

-ធ្វើការគាំទ្រ និងស្វែងរកដៃគូប្រមូលទិញផលវារីវប្បកម្មតាមការធ្វើផលិតកម្មតាមកិច្ចសន្យា

**សកម្មភាពទី២÷ ផ្សព្វផ្សាយច្បាប់ស្តីពីជលផល (ចំនួននាក់)**

-ប្រជុំផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងបទដ្ឋានគតិយុតិពាក់ព័ន្ធ

**សកម្មភាពទី៣÷ ផ្សព្វផ្សាយការគ្រប់គ្រង និងអភិរក្សធនធានជលផល (ទប់ស្កាត់ បង្ក្រាបបទល្មើស អភិរក្ស... (ចំនួនលើក)**

-ចុះកំណត់ និងបោះបង្គោលព្រំប្រទល់ព្រៃលិចទឹក

-ចុះកំណត់ និងបោះបង្គោលព្រំប្រទល់កន្លែងអភិរក្ស

-ចុះល្បាត ការកាប់រានឈូសឆាយព្រៃលិចទឹក

-ការដាំដុះព្រៃលិចទឹកឡើងវិញ

-កែលម្អកន្លែងអភិរក្សជលផល និងជម្រកមេពូជ

-ផ្សព្វផ្សាយសារៈប្រយោជន៍ធនធានជលផលដែលកំពុងរងគ្រោះថ្នាក់

-រៀបចំស្លាកសញ្ញា និងប៉ាន់ណូផ្សព្វផ្សាយ កន្លែងអភិរក្ស

-ចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសធនធានជលផល

**សកម្មភាពទី៤÷ ពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ (ចំនួនសហគមន៍)**

-បណ្តុះបណ្តាលរៀបចំផែនការគ្រប់គ្រង

-បណ្តុះបណ្តាលពង្រឹងការគ្រប់គ្រងធនធានជលផល

-រៀបចំ និងកែលម្អរជំរកកន្លែងត្រីពូជរបស់សហគមន៍នេសាទ

-ចុះពិនិត្យតាមដានពីវឌ្ឍនភាពនៃការគ្រប់គ្រងសហគមន៍នេសាទ

-ចុះបញ្ជីសហគមន៍នេសាទ

-ប្រជុំរៀបចំគណៈកម្មការសហគមន៍ស្រះជំរកត្រី

### ២.៥.៤ កម្មវិធីទី៤÷ ការគ្រប់គ្រង និងអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ

#### ២.៥.៤.១ អនុកម្មវិធីទី៤.៤ ÷ ការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ

**ក. គោលបំណង÷**

ចូលរួមចំណែកជម្រុញការដាំឈើឡើងវិញពង្រឹង និងអភិវឌ្ឍន៍សហគមន៍ព្រៃឈើ និងទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ។

### ខ. សូចនាករ

**តារាងទី 22 ÷ សូចនាករ នៃអនុកម្មវិធីទី៤ (ថ្នាក់ខេត្ត)**

| សូចនាករ | ឯកតា | គោលដៅ (Target) | | | | |
|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| ១. បរិមាណផលឈើដាំត្រូវបានប្រមូល | ម៉ែត្រគូប | 4,580 | 4,580 | 4,580 | 4,580 | 4,580 |
| ២. អត្រាចំណូលសហគមន៍ព្រៃឈើត្រូវបានកើនឡើង | % | 2.50 | 2.50 | 2.50 | 2.50 | 2.50 |

### គ. ចង្កោមសកម្មភាព១÷ ៤.៤.១.២១÷ ការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធាន ព្រៃឈើ និងសត្វព្រៃ

**-គោលបំណង÷** លើកកម្ពស់ការដាំឈើ កសិ-រុក្ខកម្ម បង្កើនផលិតផលឈើក្នុងព្រៃសហគមន៍ និងពង្រឹងការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ។

**-សូចនាករ**

**តារាងទី 23 ÷សូចនាករ នៃចង្កោមសកម្មភាព នៃអនុកម្មវិធីទី៤**

| សូចនាករ | ឯកតា | គោលដៅ (Target) | | | | |
|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| ១. ទំហំផ្ទៃដីដាំឈើឡើងវិញ | ហិកតា | 115 | 110 | 110 | 110 | 110 |
| ២. អត្រាបទល្មើសព្រៃឈើថយចុះ | % | 5 | 5 | 5 | 5 | 5 |
| ៣. សហគមន៍ព្រៃឈើបានអនុវត្តការងារកសិ-រុក្ខកម្ម | ចំនួន | 1 | 2 | 3 | 4 | 5 |

### ឃ. សកម្មភាព

**សកម្មភាពទី១÷ អភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ (បណ្តុះកូនឈើ ដាំដើមឈើឡើងវិញ កសិ-រុក្ខកម្ម) ហិកតា /ចំនួនដើម)**

- ធ្វើការថែរក្សាចំការពូជកូនឈើ
- ធ្វើរុក្ខទិវាមួយឆ្នាំម្តងជាប្រចាំ
- ជម្រុញការដាំកូនឈើតាមទីសាធារណៈព្រមទាំងផ្តល់ពូជឈើដល់កសិករ
- ធ្វើការថែរក្សា និងបណ្តុះកូនឈើនៅស្ថានីយ៍បណ្តុះកូនឈើដោយធ្វើការផ្សព្វផ្សាយពូជឈើ
- ធ្វើបច្ចុប្បន្នភាពដីគម្របព្រៃឈើ និងធ្វើផែនទីគម្របព្រៃឈើ

**សកម្មភាពទី២÷ ផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ (ចំនួននាក់)**

- ចុះផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើដល់សមាជិកសហគមន៍ និង កសិករ

**សកម្មភាពទី៣÷ ពង្រឹងការគ្រប់គ្រងធនធានព្រៃឈើ (ទប់ស្កាត់ បង្ក្រាបបទល្មើស ...) (ចំនួនលើក)**

-បន្តចុះទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃគ្រប់រូបភាព

**សកម្មភាពទី៤÷ ពង្រឹងការគ្រប់គ្រងសហគមន៍ព្រៃឈើ (ចំនួនសហគមន៍)**

-បោះបង្គោលព្រៃព្រំប្រទល់សហគមន៍

-ធ្វើបច្ចុប្បន្នភាព និងចុះកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើដោយធ្វើការប្រជុំផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់សមាជិកសហគមន៍

- ធ្វើការពង្រឹងសមត្ថភាពដល់សហគមន៍ព្រៃឈើដែលមានស្រាប់ឲ្យមានសមត្ថភាពពេញលេញ។

### កម្មវិធីទី ៥÷ ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

#### ២.៥.៥. អនុកម្មវិធីទី៥.១៤ ÷ ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស

**ក. គោលបំណង÷**

ចូលរួមគាំទ្រក្នុងការអនុវត្តថវិកាកម្មវិធី និងពង្រឹងសមត្ថភាពធនធានមនុស្ស។

**ខ. សូចនាករ**

**តារាងទី 24÷ សូចនាករ នៃអនុកម្មវិធីទី៥ (ថ្នាក់ខេត្ត)**

| សូចនាករ | ឯកតា | គោលដៅ (Target) | | | | |
|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| ១. ប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី | % | 85.00 | 86.00 | 87.00 | 88.00 | 89.00 |
| ២. អត្រាមន្ត្រីត្រូវបានពង្រឹងសមត្ថភាព | % | 60 | 61 | 62 | 63 | 64 |

**គ. ចង្កោមសកម្មភាព១÷ ៥.១៤.១.២១ ÷ ការបង្កើនគុណភាពសេវាគាំទ្រ និងការអភិវឌ្ឍន៍ធនធានមនុស្ស**

**-គោលបំណង÷** ជម្រុញការអនុវត្តថវិកាកម្មវិធី និងបង្កើនសមត្ថភាពធនធានមនុស្ស។

**-សូចនាករ**

**តារាងទី 25÷ សូចនាករចង្កោមសកម្មភាពនៃអនុកម្មវិធីទី៥**

| សូចនាករ | ឯកតា | គោលដៅ (Target) | | | | |
|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| ១. លទ្ធផលនៃការអនុវត្តផែនការសកម្មភាព និងថវិកា បានអនុវត្ត | % | 98.20 | 98.30 | 98.40 | 98.50 | 98.60 |
| ២. មន្ត្រីពាក់ព័ន្ធក្នុងផ្នែកកសិកម្មទទួលបានចំណេះដឹងបច្ចេកទេសកសិកម្ម | នាក់ | 100 | 110 | 120 | 140 | 150 |
| ៣. សេវាប្រើប្រាស់ព័ត៌មានទីផ្សារកសិផល | នាក់ | 250 | 350 | 450 | 550 | 650 |

**ឃ. សកម្មភាព**

**សកម្មភាពទី១÷ រៀបចំផែនការ ការតាមដាន និងវាយតម្លៃថវិកាកម្មវិធី (លើក)**

-ចុះសម្របសម្រួលតាមដានត្រួតពិនិត្យ និងវាយតម្លៃល្បឿននៃការអនុវត្តផែនការ និងអនុកម្មវិធីនានា

-បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រី អំពីការរៀបចំផែនការ ការត្រួតពិនិត្យ និងវាយតម្លៃ

-គ្រប់គ្រងបញ្ជីការគណនេយ្យតាមពត៌មានវិទ្យា និងគ្រប់គ្រងបេឡាសាច់ប្រាក់

-លើកគម្រោងថវិកាប្រចាំឆ្នាំ និងតាមដានការអនុវត្ត

-បានចូលរួមប្រជុំពិគ្រោះយោបល់លើការងាររៀបចំកសាងផែនការអភិវឌ្ឍន៍វិស័យកសិកម្មខេត្តប្រចាំឆ្នាំ

-រៀបចំផែនការវិនិយោគ៣ឆ្នាំរំកិលរបស់ខេត្តឆ្នាំ២០១៦-២០១៨ និងផែនការវិនិយោគ៣ឆ្នាំរំកិលបន្តឆ្នាំ២០១៩-២០២១

-រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្ត ឆ្នាំ២០១៩-២០២៣

-រៀបចំផែនការសកម្មភាព និងបែងចែកថវិកាតាមកម្មវិធី (PB)

-វិភាគ និងកសាងផែនការអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលខ្លី មធ្យម វែង និងតាមដានការអនុវត្ត

-ប្រមូលចំណូល និងបង់ចូលថវិកាជាតិតាមគោលការណ៍ច្បាប់ហិរញ្ញវត្ថុ

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈបរិក្ខា និងធ្វើបញ្ជីសារពើភណ្ឌ

-ពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍អង្គការក្រៅរដ្ឋាភិបាល និងមន្ទីរពាក់ព័ន្ធដើម្បីកៀរគរប្រភពថវិកា ដើម្បីឆ្លើយតបទៅនិងផែនការយុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុក។

**សកម្មភាពទី២÷ អភិវឌ្ឍន៍ធនធានមនុស្ស និងបញ្ហាបយេនឌ័រ (នាក់)**

-ផ្សព្វផ្សាយ ស្តីពី យេនឌ័រក្នុងវិស័យកសិកម្ម ដល់កសិករ និង មន្ត្រីរាជការ

-ផ្តល់ភាពស្មើគ្នារវាងបុរស និងស្ត្រីក្នុងការចូលរួមវគ្គបំពាក់បំប៉នក្នុង និងក្រៅប្រទេស

**សកម្មភាពទី៣÷ អង្កេតស្ទង់ទិន្នផល និងផ្តល់ព័ត៌មានស្ថិតិកសិកម្ម (សំណាក)**

-ដឹកនាំការអង្កេតទូទៅ ការអង្កេតតាមផ្នែកលើការងារកសិកម្ម ប្រមូលព័ត៌មានស្ថិតិកសិកម្ម ចងក្រងបោះពុម្ពផ្សព្វ ផ្សាយ

-ពង្រឹងការងារអង្កេតស្ទង់ទិន្នន័យស្រូវវស្សាប្រាំង និងការប្រមូលព័ត៌មានស្ថិតិកសិកម្មដើម្បីវិភាគវាយតម្លៃការវិវឌ្ឍន៍វិស័យកសិកម្ម និងលើកទិសដៅអភិវឌ្ឍន៍នៅឆ្នាំក្រោយៗទៀត

-ចុះធ្វើអង្កេតវាស់ស្ទង់ទិន្នផលស្រូវរដូវវស្សា និងស្រូវរដូវប្រាំងប្រចាំឆ្នាំនីមួយៗទៅតាមផែនការជ្រើសរើសភូមិគ្រួសារ និង សំណាកគំរូចៃដន្យរបស់នាយកដ្ឋានផែនការ និងស្ថិតិ។

-បណ្តុះបណ្តាលមន្ត្រីជំនាញ អំពីការស្ទង់ទិន្នន័យផលដំណាំ និងការគ្រប់គ្រងទិន្នន័យស្ថិតិកសិកម្ម

-រួមសហការជាមួយការិយាល័យជំនាញពាក់ព័ន្ធចុះពិនិត្យតាមដានវាយតម្លៃផលប៉ះពាល់ខូចខាតគ្រប់មុខដំណាំដោយសារសត្វល្អិត គ្រោះរាំងស្ងួត ទឹកជំនន់ និងរៀបចំរបាយការណ៍ផ្ញើជូនថ្នាក់ដឹកនាំខេត្ត និងនាយកដ្ឋានស្ថិតិនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។

-តាមដានវាយតម្លៃល្បឿនការងារបង្កបង្កើនផលគ្រប់មុខដំណាំរដូវវស្សា-ប្រាំងប្រចាំឆ្នាំ វាយតម្លៃតុល្យភាពស្បៀងប្រចាំឆ្នាំ និងធ្វើរបាយការណ៍ជាប្រចាំជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត។

-ណែនាំតម្រង់ទិសជម្រុញដល់គ្រប់ការិយាល័យជំនាញឲ្យរៀបចំផែនការ និងអនុវត្តស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានប្រមូលពត៌មាន និងរបាយការណ៍ពីការិយាល័យជំនាញចំណុះឲ្យមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្តបូកសរុប និងផ្ញើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរពាក់ព័ន្ធ។

**សកម្មភាពទី៤÷ ពង្រឹងសេវាព័ត៌មានទីផ្សារកសិកម្ម (លើក)**

-ធ្វើរបាយការណ៍ពត៌មានតម្លៃកសិផល និងជីគីមីប្រចាំថ្ងៃរាយការណ៍តាមរយៈអ៊ីម៉េលជូនការិយាល័យទីផ្សារកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ធ្វើរបាយការណ៍តម្លៃ ផ្សព្វផ្សាយតាមវិទ្យុ FM ខេត្តប្រចាំថ្ងៃ

-បញ្ចូលទិន្នន័យក្នុងប្រព័ន្ធវិភាគទិន្នន័យ ធ្វើរបាយការប្រចាំខែជូនការិយាល័យទីផ្សារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បណ្តុះបណ្តាលសេវាព័ត៌មានទីផ្សារកសិកម្ម ដល់កសិករ និង អាជីវករ

-ចុះប្រមូលតំលៃកសិផលកសិកម្មនៅតាមផ្សារ

-ធ្វើសាលាទីផ្សារកសិករ

**សកម្មភាពទី៥÷ ជម្រុញការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម (នាក់)**

-ផ្សព្វផ្សាយជាប្រចាំនូវបទបញ្ញត្តិផ្សេងៗ ដែលពាក់ពន្ធ័ទៅនឹងចរាចរណែនាំឱ្យប្រើប្រាស់សម្ភារៈកសិកម្ម គ្រប់ប្រភេទ (ជីគីមី ថ្នាំកសិកម្ម) ជូនដល់អជីវករ អ្នកប្រើប្រាស់ និងអ្នកពាក់ពន្ធ័ដទៃទៀត

-ចុះត្រួតពិនិត្យជាប្រចាំនូវប្រភេទថ្នាំកសិកម្មជីកសិកម្មដែលបានដាក់តាំងលក់ និងធ្វើការផ្សព្វផ្សាយដល់អាជីវករ កសិករនូវប្រភេទថ្នាំកសិកម្មដែលក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានហាមឃាត់

-ធ្វើការទំនាក់ទំនងជាមួយស្ថាបន័ពាក់ពន្ធ័ក្នុងការចុះត្រួតពិនិត្យ និងចាត់វិធានការទៅលើអាជីករអ្នកប្រើប្រាស់សម្ភារៈកសិកម្មណាដែលល្មើសច្បាប់ និងបន្លំគុណភាព

-ជម្រុញឲ្យអាជីវករដែលពុំទាន់មានលិខិតអនុញ្ញាតិ ធ្វើអាជីវកម្មមកបំពេញបែបបទ ស្នើសុំលិខិតអនុញ្ញាតិតាមច្បាប់ជាធរមាន

-លើកសំណើសុំមន្រ្តីជំនាញបន្ថែម និងពង្រឹងសមត្ថភាពដល់មន្ត្រីទទួលបន្ទុកការងារនីតិកម្មកសិកម្ម

-ចុះប្រមូលទិន្នន័យពត៌មានលក់ដុំលក់រាយកសិផល និងជីគីមីជាប្រចាំនៅផ្សារក្រុងដូនកែវ កំពង់ទូក ដូនកែវ រោងម៉ាស៊ីនកិនស្រូវ ដេប៉ូលក់ជីគីមី

-ទំនាក់ទំនងជាមួយស្ថាបន័ពាក់ពន្ធ័ផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍លើការងារពង្រឹងសមត្ថភាពជំនាញគ្រប់គ្រងមុខ សម្ភារៈ និងការអនុវត្តច្បាប់។

-ប្រជុំផ្សព្វផ្សាយឱ្យបានទូលាយជូនដល់អាជីវករអំពីគុណវិបត្តិ និងគុណប្រយោជន៍ នៃការប្រើប្រាស់សម្ភារៈកសិកម្ម ជីគីមី ថ្នាំកសិកម្មពុំបានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើការចរាចរសម្ភារៈកសិកម្មក្នុងខេត្ត

**សកម្មភាពទី៦÷ សេវាគាំទ្រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

-រៀបចំផែនការបណ្តុះបណ្តាលនិងវាយតម្លៃសមត្ថភាពមន្ត្រីដើម្បីកំណត់តម្រូវការទាំងបរិមាណនិងគុណភាពជាប្រចាំ

-អនុវត្តឱ្យមានប្រសិទ្ធភាពនូវគោលការណ៍លើកទឹកចិត្តដល់មន្ត្រីបច្ចេកទេសដែលខិតខំអនុវត្តការងារបានល្អ

-បន្តលើកសំណើសុំបំពាក់បំប៉នដល់មន្ត្រីកសិកម្មគ្រប់ជាន់ថ្នាក់ នូវបច្ចេកទេសពាក់ព័ន្ធឱ្យសមស្របនឹង ការទទួលខុសត្រូវ និងស្របទៅនឹងនិន្នាការការងារបច្ចុប្បន្ន អនាគត (ផែនការ គ្រប់គ្រង កៀ្សត្រសាស្ត្រ ផលិតកម្ម និងបសុព្យាបាល កសិឧស្សាហកម្ម ការគ្រប់គ្រងទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ ។ល។

-ធានាប្រសិទ្ធភាពសុវត្ថិភាពការងាររដ្ឋបាលការពារសន្តិសុខ និងពិធីការផ្សេងៗ

-គ្រប់គ្រង និងប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវចលនទ្រព្យ និងអចលនទ្រព្យ។

## ២.៦ បញ្ហាដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា

### ២.៦.១ ការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម

#### ក. សូចនាករ

**តារាងទី 26 ÷ ការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម**

| សូចនាករ | ឯកតា | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ចំនួនមន្ត្រីរាជការស្ត្រីត្រូវបានដំឡើងតួនាទីក្នុងថ្នាក់ដឹកនាំ | នាក់ | 11 | 12 | 13 | 14 | 15 |
| ស្ត្រីដែលជាកសិករបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា | ភាគរយ | 65 | 65 | 65 | 65 | 65 |
| អត្រាស្ត្រីជាសមាជិកានៃសហគមន៍អភិវឌ្ឍន៍កសិកម្មមានការកើនឡើង | ភាគរយ | 25 | 30 | 35 | 40 | 45 |

#### ខ. សកម្មភាព

ដើម្បីចូលរួមចំណែកលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យកសិកម្ម និងដើម្បីឆ្លើយតបទៅ និងគោលនយោបាយបញ្ជ្រាបយេនឌ័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សកម្មភាពយុទ្ធសាស្ត្រមួយចំនួននឹងត្រូវបានយកចិត្តទុកដាក់សកម្មភាពទាំងនោះរួមមាន÷

-បញ្ជ្រាបការងារយេនឌ័រក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

-ពង្រឹងការយល់ដឹងយេនឌ័រក្នុងចំណោមមន្ត្រីរាជការទាំងអស់ នៅគ្រប់កម្រិតទាំងមន្ត្រីការិយាល័យជំនាញថ្នាក់ខេត្ត និងមន្ត្រីជំនាញនៃការិយាល័យកសិកម្ម។

-បង្កើនចំនួនស្ត្រីដែលមានសមត្ថភាព និងបុគ្គលិកលក្ខណៈសមស្របឲ្យមានតួនាទីក្នុងតួនាទីជាថ្នាក់ដឹកនាំ។

-ផ្តល់ឱកាសដល់មន្ត្រីរាជការជាស្ត្រីដើម្បីលើកកម្ពស់សមត្ថភាព និងការចូលរួមសកម្មភាពផ្សេងៗ

-កំណត់ឲ្យបានច្បាស់ពីតម្រូវការ និងផ្តល់វគ្គបណ្តុះបណ្តាលលើមុខជំនាញកសិកម្ម។

-ផ្តល់សិទ្ធិក្នុងការបញ្ចេញមតិយោបល់ក្នុងការងារអភិវឌ្ឍផ្សេងៗ

### ២.៦.២ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាដែលសកលលោកកំពុងជួបប្រទះ និងទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមានពីការប្រែប្រួលអាកាសធាតុនេះ។ ការប្រយុទ្ធប្រឆាំងទៅនឹងការប្រែប្រួលអាកាសធាតុនេះជាបញ្ហាអន្តរវិស័យដែលត្រូវចាប់ដៃគ្នាដើម្បីដោះស្រាយទៅតាមវិស័យរៀងៗខ្លួន។ ការប្រែប្រួលអាកាសធាតុនេះបានធ្វើឲ្យប៉ះពាល់ និងខូចខាតដល់វិស័យមួយចំនួនដូចជា វិស័យកសិកម្ម ធនធានទឹក សុខភាព និងជំងឺ បរិស្ថាន និងជីវចម្រុះ។ ចំពោះវិស័យកសិកម្មគឺមានផលប៉ះពាល់ទៅលើផលិតកម្មកសិកម្ម និងស្បៀងអាហារ ផ្ទៃដីប៉ះពាល់ និងខូចខាតលើដំណាំស្រូវ និងដំណាំរួមផ្សំមានការថយចុះធនធានជលផលដោយសារការប្រែប្រួលអាកាសធាតុធនធានព្រៃឈើក៏ទទួលរងនូវផលប៉ះពាល់ដោយកត្តានេះផងដែរដែលជះឥទ្ធិពល និងគំរាមកំហែងដល់ជីវភាពគ្រួសារជាពិសេសគ្រួសារក្រីក្រងាយរងគ្រោះ។

មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មានគោលការចម្បងៗក្នុងការរួមចំណែកកសាងភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដូចជាការកសាងសមត្ថភាពមន្ត្រីបច្ចេកទេស មន្ត្រីផ្សព្វផ្សាយកសិកម្ម ព្រមទាំងសហការជាមួយដៃគូអភិវឌ្ឍផ្សេងៗ អង្គការជាតិអន្តរជាតិដែលអនុវត្តន៍ក្នុងខេត្តទាក់ទងនឹងវិស័យកសិកម្ម និងសហគមន៍មូលដ្ឋាននានា ក្នុងការបញ្ជូល

នូវបច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗក្នុងការដាំដុះដំណាំ ការចិញ្ចឹមសត្វ ការធ្វើវារីវប្បកម្ម ការផ្សព្វផ្សាយពូជដែលធន់ទៅនឹងការបំរែបំរួលអាកាសធាតុដូចជា ទឹកជំនន់ ភាពរាំងស្ងួតឲ្យបានទូលំទូលាយទៅក្នុងមជ្ឍដ្ឋានកសិករក្នុងខេត្តតាកែវដែលស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**គ.សកម្មភាព**

ដើម្បីកាត់បន្ថយទៅនឹងឥទ្ធិពលអវិជ្ជមានទាំងឡាយនៅលើវិស័យកសិកម្មក្នុងខេត្ត ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុមន្ទីរកសិកម្មកំណត់ទិសដៅសកម្មភាពជាយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម÷

-ជម្រុញការបញ្ជ្រាបបច្ចេកទេសកសិកម្ម ដែលមានលទ្ធភាពបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការអភិវឌ្ឍន៍គ្រប់លំដាប់ថ្នាក់

-ពង្រឹងនិងពង្រីកការងារផ្សព្វផ្សាយបច្ចេកទេសបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុដូចជាជម្រុញឱ្យកសិករ ប្រើប្រាស់ពូជធន់ទៅនឹងទឹកជំនន់ និងការរាំងស្ងួត

-ជម្រុញការធ្វើប្រពលវប្បកម្ម និងពិពិធកម្មកសិកម្ម

-លើកកម្ពស់ការយល់ដឹងមន្ត្រីជំនាញ និងកសិករអំពីការប្រែប្រួលអាកាសធាតុ និងវិធានការឆ្លើយតប

-ពង្រឹងសមត្ថភាពមន្ត្រីជំនាញគ្រប់លំដាប់ថ្នាក់លើការធ្វើអន្តរាគមន៍ឆ្លើយតបនឹងគ្រោះមហន្តរាយ

-ត្រៀមមធ្យោបាយសម្ភារៈ ឧបករណ៍ ដើម្បីអន្តរាគមន៍ករណីមានគ្រោះមហន្តរាយ

-ពង្រឹងវិធានការ ការគ្រប់គ្រង ការឆ្លងរាលដាលនៃជំងឺឆ្លងសត្វគ្រប់ប្រភេទ

-បង្កើតក្រុមការងារតាមដានវាយតម្លៃផលប៉ះពាល់ខូចខាត និងអន្តរាគមន៍ពេលមានគ្រោះមហន្តរាយ

-ផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់ឧបករណ៍ និងសម្ភារៈដែលជួយសន្សំសំចៃទឹក និងកំលាំងពលកម្ម

-កំណត់តំបន់ដែលងាយរងគ្រោះ និងជម្រុញរៀបចំប្រតិទិនដាំដុះនៅតាមបណ្តាលឃុំនីមួយៗ

## ២.៦.៣ កិច្ចសហប្រតិបត្តិការអន្តរវិស័យ

ដើម្បីលើកកម្ពស់កំណើនវិស័យកសិកម្មក្នុងខេត្តតាកែវ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពិតជាមិនអាចខ្វះបាននូវកិច្ចសហការពីវិស័យផ្សេងៗទៀតក្នុងខេត្តដូចជា វិស័យធនធានទឹក និងឧតុនិយម វិស័យពាណិជ្ជកម្ម វិស័យអភិវឌ្ឍន៍ជនបទ។

វិស័យធនធានទឹក និងឧតុនិយម÷ ការអភិវឌ្ឍន៍កសិកម្ម ពិតជាមិនអាចខ្វះបានទេនូវកិច្ចសហការយ៉ាងស្អិតរមួតពីវិស័យធនធានទឹក និងឧតុនិយមដោយសារបច្ចុប្បន្នក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានដាក់ចេញគម្រោងសាងសង់ ប្រឡាយជើងក្អែបដែលនេះគឺត្រូវការជាចាំបាច់នូវកិច្ចសហការពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តតាកែវ។ ម្យ៉ាងទៀតការព្យាករណ៍នូវអាកាសធាតុក៏មានការចាំបាច់ដែរក្នុងកិច្ចការងារកសិកម្ម ពីព្រោះដើម្បីដឹងអំពីទឹកភ្លៀង ទឹកជំនន់ និងភាពរាំងស្ងួតដែលរាំងស្ទះដល់ការដាំដុះដំណាំកសិកម្ម ដើម្បីត្រៀមនូវវិធានការកាត់បន្ថយផ្សេងៗទប់ទល់ទៅនឹងកត្តាទាំងនោះ។

វិស័យពាណិជ្ជកម្ម÷ បច្ចុប្បន្នកសិករធ្វើស្រែចំការផ្សេងៗ តែងត្រូវការចាំបាច់នូវទីផ្សារកសិផលដែលទទួលបានតំលៃសមរម្យដើម្បីទូទាត់ថ្លៃចំណាយទៅលើជីថ្នាំកសិកម្មប្រេងឥន្ធនៈដែលមានតំលៃថ្លៃក៏ដូចជាទ្រទ្រង់នូវជីវភាពរស់នៅប្រចាំថ្ងៃ

ដែលកិច្ចលក់ដូរកសិផលនេះគឺពិតជាមានទំនាក់ទំនងទៅនឹងវិស័យពាណិជ្ជកម្ម។ កសិផលដែលផលិតបានមួយចំនួនត្រូវបានកែច្នៃជាកសិពាណិជ្ជកម្ម និងចុះជាផលិតកម្មតាមកិច្ចសន្យា។

វិស័យអភិវឌ្ឍន៍ជនបទ៖ បន្ទាប់ពីផលិតបាននូវកសិផល កសិពាណិជ្ជកម្ម កសិករក៏ត្រូវការផងដែរនូវហេដ្ឋារចនាសម្ព័ន្ធជនបទដ៏សំបូរបែបដើម្បីដឹកជញ្ជូនកសិផលកសិកម្មទៅកាន់ទីផ្សារប្រសិនបើគ្មានហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរទេនោះតំលៃកសិផលក៏មិនបានខ្ពស់ដែរដោយហេតុ ឈ្មួញចំណាយខ្ពស់ទៅលើការដឹកជញ្ជូនដែលជាហេតុ នាំឱ្យឈ្មួញបន្ថោកតំលៃកសិផល។ ដូច្នេះតំលៃកសិផលថ្លៃ ឬថោកពិតជាមានទំនាក់ទំនងជាមួយវិស័យអភិវឌ្ឍន៍ជនបទ។

## ២.៧ ផែនការថវិកា

**តារាងទី 27 ÷ តម្រូវការថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍កសិកម្មថ្នាក់ខេត្ត ឆ្នាំ២០១៩-២០២៣**

| ប្រភព | ចំនួនថវិកា ឆ្នាំ២០១៩ (លានរៀល) | ការព្យាករណ៍ថវិកា ឆ្នាំ២០១៩-២០២៣ (លានរៀល) | កម្មវិធីទី១ អនុកម្មវិធី ១.៩ (លានរៀល) | កម្មវិធីទី២ អនុកម្មវិធី ២.៤ (លានរៀល) | កម្មវិធីទី៣ អនុកម្មវិធី ៣.៤ (លានរៀល) | កម្មវិធីទី៤ អនុកម្មវិធី ៤.៤ (លានរៀល) | កម្មវិធីទី៥ អនុកម្មវិធី ៥.១៤ (លានរៀល) |
|---|---|---|---|---|---|---|---|
| រដ្ឋាភិបាល (ថវិកាកម្មវិធី) | 5,520.00 | 32,185.04 | 3,193.45 | 574.98 | 1,410.11 | 791.06 | 26,215.45 |
| កម្មវិធី ASPIRE | 1,430.49 | 1,869.40 | 1,664.67 | 104.42 | 39.23 | 61.08 | - |
| គម្រោង បដិភាគផ្សេងៗ | 800.00 | 4,500.00 | 900.00 | 900.00 | 900.00 | 900.00 | 900.00 |

**តារាងទី 28 ÷ ការប៉ាន់ប្រមាណធនធានសរុបដែលមានសម្រាប់អនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍កសិកម្មថ្នាក់ខេត្ត**

| អនុកម្មវិធី | តម្រូវការថវិកាឡើងវិញ (លានរៀល) | | | | | |
|---|---|---|---|---|---|---|
| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
| **សរុប** | **5,529.00** | **6,062.20** | **6,244.07** | **6,431.39** | **6,823.06** | **32,185.04** |
| អនុកម្មវិធី ១.៩ ÷ ការជម្រុញផលិតកម្មដំណាំកសិកម្ម និងកសិធុរកិច្ច | 471.80 | 601.50 | 619.55 | 638.13 | 676.99 | 3,193.45 |
| អនុកម្មវិធី ២.៤ ÷ ការជម្រុញផលិតកម្មសត្វ និងសុខភាពសត្វ | 125.70 | 108.30 | 111.55 | 114.90 | 121.89 | 574.98 |
| អនុកម្មវិធី ៣.៤÷ ការពង្រឹងការគ្រប់គ្រងធនធានជលផល និងការជម្រុញវារីវប្បកម្ម | 282.10 | 265.60 | 273.57 | 281.78 | 298.94 | 1,410.11 |
| អនុកម្មវិធី ៤.៤÷ ការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ | 209.80 | 149.00 | 153.47 | 158.07 | 167.70 | 791.06 |
| អនុកម្មវិធី ៥.១៤÷ ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស | 4,439.60 | 4,937.80 | 5,085.93 | 5,238.51 | 5,557.54 | 26,215.45 |

## ២.៨ ការត្រួតពិនិត្យ និងវាយតម្លៃ

ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃជាឧបករណ៍មួយយ៉ាងសំខាន់ សំរាប់វាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម រយៈពេលប្រាំឆ្នាំ (២០១៩-២០២៣) ថាតើការអុនុវត្តតាមកម្មវិធីនីមួយៗមានប្រសិទ្ធភាព និងប្រសិទ្ធផលបែបណា។ ហើយឆ្លើយតបទៅនឹងសូចនាករលទ្ធផលដែលកម្មវិធីនីមួយៗបានដាក់ក្នុងផែនការយុទ្ធសាស្ត្រតាមឆ្នាំនីមួយៗ។ ថែមទាំងឆ្លុះបញ្ចាំងពីគណនេយ្យភាព តម្លាភាព ស្របតាមបទដ្ឋានបច្ចេកទេស។ ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ បានបង្ហាញយ៉ាងច្បាស់រាល់ចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន ដែលមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ចាំបាច់ត្រូវតែធ្វើការកែលម្អជាបន្ទាន់ សំរាប់អនុវត្តបន្តទៅឆ្នាំខាងមុខ។

លទ្ធផលនៃប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ ផ្តល់ផលប្រយោជន៍ដល់ការអនុវត្តធ្វើសេចក្តីសម្រេចចិត្តពិសេសថ្នាក់ដឹកនាំមន្ទីរត្រូវមានវិធានការកែសម្រួលរាល់ចំណុចអវិជ្ជមានដល់ការិយាល័យ ខ័ណ្ឌ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរ។ លើសពីនេះរបាយការណ៍លទ្ធផលដែលបានមកពីការត្រួតពិនិត្យ និងវាលតម្លៃអាចឲ្យភាគីពាក់ព័ន្ធនានាធ្វើការសម្រេចចិត្តក្នុងការគាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលប្រាំឆ្នាំ (២០១៩-២០២៣) របស់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០១៩-២០២៣) របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។

មន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទទទួលយកប្រពន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃតាមរយៈសកម្មភាពរួមមាន÷

-បង្កើតក្រុមការងារត្រួតពិនិត្យតាមដាន និងវាយតម្លៃមួយនៅមន្ទីរ

-ត្រួតពិនិត្យតាមដាន និងវាយតម្លៃតាមរយៈការប្រើប្រាស់ទម្រង់ M1, M2, និងM3

-មានកម្មវិធីប្រជុំប្រចាំខែ, ត្រីមាស, ឆមាស និងប្រចាំឆ្នាំដើម្បីបូកសរុបលទ្ធផលការងារប្រចាំឆ្នាំរកចំណុចអវិជ្ជមានដែលកើតឡើង និងធ្វើការកែលម្អ។

<u>លំហូរការងាររបាយការណ៍</u>



## ២.៩ សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្តតាកែវ ២០១៩-២០២៣ ត្រូវបានរៀបចំឡើងយ៉ាងយកចិត្តទុកដាក់ដោយបង្ហាញពីលទ្ធផលសម្រេចបានក្នុងរយៈពេល ០៥ឆ្នាំ ២០១៤-២០១៨ ព្រមទាំងបង្ហាញនូវចំណុចខ្លាំងបញ្ហាប្រឈមឱកាស និងការគំរាមកំហែងដែលជាឧបសគ្គចម្បងៗក្នុងការរាំងស្ទះដល់ការអនុវត្តនូវសកម្មភាពរយៈពេល០៥ឆ្នាំកន្លងមក។ ផែនការនេះក៏បានរំលេចផងដែរនូវការរួមចំណែកឧបត្ថម្ភគាំទ្រពីស្ថាប័នរដ្ឋ មន្ទីរជំនាញពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍ទាំងអស់ដែលមានក្នុងខេត្តលើសពីនេះទៅទៀតផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្តតាកែវ ២០១៩-២០២៣ ក៏បានបង្ហាញផងដែរនូវក្របខ័ណ្ឌដែលអនុវត្តន៍បន្តដោយផ្អែកតាមកម្មវិធីកំណែទម្រង់របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើបញ្ហាដែលនៅសេសសល់កន្លងមកដែលពុំទាន់បានដោះស្រាយ ព្រមទាំងបង្ហាញនូវទស្សនៈវិស័យបេសកកម្ម និងគោលដៅយុទ្ធសាស្ត្ររបស់កម្មវិធីទាំង ០៥ របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងសូចនាករនានាដែលជាឧបករណ៍សម្រាប់វាស់វែងនូវលទ្ធផលដែលក្រសួងសម្រេចបានរយៈពេល ០៥ឆ្នាំកន្លងមក (២០១៤-២០១៨)។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្តតាកែវ ២០១៩-២០២៣ ពិតជាមានសារសំខាន់ណាស់ក្នុងការបង្ហាញឲ្យឃើញអំពីទិសដៅ និងសកម្មភាពដែលត្រូវអនុវត្តដើម្បីសម្រេចបាននូវលទ្ធផលស្របតាមការចង្អុរណែនាំក្រោមក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្តតាកែវ ២០១៩-២០២៣ និងផ្តល់តម្លាភាពនិងភាពគួរឲ្យទុកចិត្តបានសម្រាប់ដៃគូអភិវឌ្ឍន៍ក៏ដូចជាបណ្តាអ្នកផ្តល់ជំនួយផ្សេងៗ ដើម្បីចូលរួមចំណែកផ្តល់ធនធានសម្ភារៈទាំងបច្ចេកទេស និងថវិកាក្នុងការអនុវត្តបណ្តាសកម្មភាព អាទិភាពសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្មក្នុងខេត្តតាកែវ ក៏ដូចជាវិស័យកសិកម្មទូទាំងប្រទេស។ ផែនការយុទ្ធសាស្ត្រនេះក៏បានបង្ហាញផងដែរនូវកត្តាអវិជ្ជមាន និងឧបសគ្គនានាដែលនឹងអាចរាំងស្ទះក្នុងការបង្កើនផលិតភាពពិពិធកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្មពិសេសផលិតកម្មដំណាំស្រូវ ផលិតកម្មសត្វ ដំណាំ ឧស្សាហកម្ម និងដំណាំរួមផ្សំដូចជាគ្រោះធម្មជាតិដែលអាចកើតមានឡើងដូចជាគ្រោះរាំងស្ងួត ទឹកជំនន់ កត្តាបំផ្លិចបំផ្លាញពីសមាសភាគចង្រៃសត្វល្អិតនានា។ល។ ដែលជាកត្តាខាងក្រៅដែលយើងមិនអាចគ្រប់គ្រងបានប៉ុន្តែយើងអាចកាត់បន្ថយបានតាមរយៈការត្រៀមបង្ការទុកជាមុន និងការតាំងចិត្តខ្ពស់ដើម្បីឲ្យកសិកររមានភាពបន្សាំនិងកត្តានានានៃឥទ្ធិពលប្រែប្រួលអាកាសធាតុ និងការបណ្តុះបណ្តាលជំនាញ និងបច្ចេកទេសថ្មីៗនានាដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីទទួលបានលទ្ធផលល្អប្រសើរក្នុងការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយចីរភាពដែលផ្តល់ប្រាក់ចំណូលខ្ពស់ដល់ កសិកររដើម្បីបង្កើនជីវភាពគ្រួសារ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១÷ គោលការណ៍បច្ចេកទេសក្នុងការរៀបចំផែនការអភិវឌ្ឍន៍កសិកម្មខេត្ត

ដំណើរការរៀបចំផែនការអភិវឌ្ឍន៍កសិកម្មក្នុងខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយកចិត្តទុកដាក់ និងអនុលោមទៅតាមគោលការណ៍ណែនាំបច្ចេកទេស ដែលបានរៀបចំដោយនាយកដ្ឋានផែនការនិងស្ថិតិ និងសហការជាមួយក្រុមហ៊ុនទីប្រឹក្សា YDRC ដើម្បីធានាបាននូវផែនការយុទ្ធសាស្ត្រមួយប្រកបដោយសុក្រិតភាព និងឆ្លើយតបនឹងការប្រឈមនិងតម្រូវការរបស់កសិករនិងបណ្ដាអ្នកពាក់ព័ន្ធ។ ជំហាននៃដំណើរការរៀបចំផែនការទាំងនោះ រួមមាន÷

- ការពិគ្រោះយោបល់ និងកិច្ចប្រជុំណែនាំពីគោលការណ៍រៀបចំផែនការ និងការតាមដានវឌ្ឍនភាពនៃដំណើរការរៀបចំផែនការ
- ការប្រមូលទិន្នន័យ និងស្ថិតិកសិកម្មតាមបណ្ដាអនុវិស័យ ដើម្បីវិភាគសមិទ្ធផល ការប្រឈម និងការវិភាគស្វតតាមការិយាល័យជំនាញ
- ការរៀបចំផែនការយុទ្ធសាស្ត្រ ស្របគ្នានឹងទិសដៅនៃផែនការអភិវឌ្ឍន៍ខេត្ត កម្មវិធីវិនិយោគខេត្ត និងជាពិសេសស្របនឹងកម្មវិធីចំបង៥នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១៩-២០២៣
- ការកំណត់ ចង្កោមសកម្មភាព សកម្មភាពអាទិភាព និងការកំណត់ចំណុចដៅសូចនាករតាមអនុកម្មវិធី ដើម្បីសម្រេចបានក្នុងរយៈពេល៥ឆ្នាំ។ មន្ទីរក៏បានគិតគូរពីការចូលរួមចំណែកក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ និងធានាបាននូវសមភាពរវាងស្ត្រី និងបុរស ព្រមទាំងកុមារក្នុងវិស័យកសិកម្ម
- កិច្ចប្រជុំពិគ្រោះយោបល់បានអនុវត្ត នៅកម្រិតខេត្ត និងថ្នាក់ជាតិ ស្របនឹងវិធានការទប់ស្កាត់ការឆ្លងជម្ងឺកូវីដ ដើម្បីប្រមូលធាតុចូល អនុសាសន៍ ពិនិត្យនូវសង្គតិភាព និងផ្ដល់សុពលភាពលើផែនការអភិវឌ្ឍន៍កសិកម្មខេត្ត។

**ដំណើរការ និងយន្តការក្នុងការរៀបចំផែនការអភិវឌ្ឍន៍កសិកម្មខេត្ត**

ដំណើរការរៀបចំផែនការអភិវឌ្ឍន៍កសិកម្មខេត្ត ២០១៩-២០២៣ គឺជាដំណើរការដែលមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធក្នុងខេត្តដូចជាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលខេត្ត ការិយាល័យកសិកម្មស្រុក មន្ទីរជុំវិញខេត្ត អង្គការសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា តាមរយៈការចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ និងកិច្ចប្រជុំដាច់ដោយឡែកដើម្បីវិភាគបញ្ហា ពិភាក្សា និងផ្ដល់យោបល់លើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍កសិកម្មខេត្ត ២០១៩-២០២៣។ ការចូលរួមដ៏សំខាន់បំផុតក្នុងការរៀបចំផែនការនេះ គឺការផ្ដល់ធាតុចូល និងមតិយោបល់លើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍កសិកម្មខេត្ត ២០១៩-២០២៣ ជាច្រើនដំណាក់កាល។

ការរៀបចំផែនការអភិវឌ្ឍន៍កសិកម្មខេត្ត ២០១៩-២០២៣នេះ បានរួមបញ្ចូលនូវលើឯកសាររបាយការណ៍ស្រាវជ្រាវ និងការអង្កេតនិងវិភាគស្ថិតិកសិកម្ម ធនធានធម្មជាតិ សេដ្ឋកិច្ចសង្គម ការប្រែប្រួលអាកាសធាតុ យេនឌ័រ

ព្រមទាំងការស្រាវជ្រាវឯកសារវិភាគលើការប្រកួតប្រជែងទីផ្សារ ការវិនិយោគថ្មីៗលើវិស័យកសិកម្មក្នុងខេត្ត និងតម្រូវការរបស់កសិករក្នុងខ្សែច្រវាក់តម្លៃផលិតផលកសិកម្មផងដែរ។

## គំនូសបំព្រួញសង្ខេប នៃយន្តការសម្របសម្រួលរៀបចំផែនការអភិវឌ្ឍន៍កសិកម្មខេត្ត ២០១៩-២០២៣




ដំណើរការ នៃការរៀបចំផែនការអភិវឌ្ឍន៍កសិកម្មខេត្ត ២០១៩-២០២៣ នេះត្រូវបានអនុវត្តជា ៤ ជំហាន ដូចខាងក្រោម÷

- ជំហានទី១÷ កិច្ចប្រជុំនៅតាមមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទតាមខេត្ត ១ថ្ងៃ សម្រាប់ណែនាំចាប់ផ្តើមដំណើរការរៀបចំផែនការ ការប្រមូល និងវិភាគទិន្នន័យ សម្រាប់ផ្នែកទី១ និងផ្នែកទី២ នៃឯកសារផែនការ។
- ជំហានទី២÷ រៀបចំសេចក្តីព្រាងផែនការតាមទម្រង់ និងគោលការណ៍ណែនាំ ដោយប្រមូលចងក្រងទិន្នន័យតាមអនុវិស័យ ការវិភាគសមិទ្ធផលនិងការប្រឈម និងការកំណត់ចំណុចដៅសូចនាករនិងចង្កោមសកម្មភាពតាមអនុកម្មវិធី។
- ជំហានទី៣÷ ការពិគ្រោះយោបល់ថ្នាក់ខេត្តចុងក្រោយដើម្បីសុក្រិត្យភាពលើឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មខេត្ត ២០១៩-២០២៣។
- ជំហានទី៤÷ សិក្ខាសាលាថ្នាក់ជាតិដើម្បីគាំទ្រជាផ្លូវការដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ការចែករម្លែកបទពិសោធន៍ និងមេរៀននៃរបៀបធ្វើផែនការ និងផ្សព្វផ្សាយអនុវត្ត។

# ឧបសម្ព័ន្ធ ២៖ ក្រុមការងាររៀបចំផែនការថ្នាក់ខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
ខេត្តតាកែវ

លេខ ........៤៥៦........ ម ក សិ.តាក .

ថ្ងៃ[illegible]ខែ.ជេស្ឋ ឆ្នាំជូតទោស័ក ព.ស ២៥៦៤
តាកែវ.ថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ ២០២០

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម**
**ឆ្នាំ ២០១៩-២០២៣ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ**

-បានឃើញប្រកាស លេខ ២២០ប្រក.កសក.ប ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់មន្ទីរកសិកម្ម រាជធានី/ខេត្ត

-បានឃើញប្រកាស លេខ ៦០៩ ប្រក ក ស ក ចុះថ្ងៃទី ២៧ ខែកញ្ញាឆ្នាំ ២០១៦ របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្មរាជធានី/ខេត្តនិងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើនិងខណ្ឌរដ្ឋបាលជលផលឱ្យស្ថិតនៅក្រោមមន្ទីរកសិកម្ម រាជធានី/ខេត្ត

-បានឃើញប្រកាស លេខ ៨៥២ ប្រក កសក ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការផ្ទេរធនធាន និងក្របខណ្ឌមន្ត្រីរាជការស៊ីវិលនៃក្របខណ្ឌផ្នែក សង្កាត់ រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី/ខេត្ត

-បានឃើញប្រកាសលេខ ៣២៦ ប្រក កសក ប ចុះថ្ងៃអង្គារ ១៣រោច ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនិងថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការផ្ទេរ សម្រួលភារកិច្ចនិងតែងតាំងមន្ត្រីរាជការ

-យោង លិខិតលេខ ៣៧១៨/២៣៩ កសក សជ ចុះថ្ងៃ អង្គារ ៧ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣ ត្រូវនិងថ្ងៃទី២៨ខែមេសា ឆ្នាំ ២០២០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០១៩-២០២៣ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី/ខេត្ត ។

**ប្រការ ១** បង្កើតក្រុមការងាររៀបចំកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ ២០១៩-២០២៣ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត តាកែវ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក សុខ ចាន់សុផល | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | ប្រធាន |
| ២-លោក ម៉េង សុធី | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | អនុប្រធាន |
| ៣-លោកស្រី ង៉ែត សុភា | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | អនុប្រធាន |
| ៤-លោក សេង ម៉េង | ប្រធានការិយាល័យផែនការ គណនេយ្យ | លេខាធិការ |
| ៥-លោក ស៊ឹម ឡាប៉ុង | នាយខណ្ឌ រដ្ឋបាលព្រៃឈើ | សមាជិក |
| ៦-លោក សៅ កុសល | នាយខណ្ឌ រដ្ឋបាលជលផល | សមាជិក |
| ៧-លោក ពី ស៊ា | ប្រធានការិយាល័យ រដ្ឋបាលបុគ្គលិក | សមាជិក |
| ៨-លោក ថៃ លី | ប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាល | សមាជិក |
| ៩-លោក សោ សារឿង | ប្រធានការិយាល័យគ្រឿងយន្តកសិកម្ម | សមាជិក |
| ១០-លោក លឹម ចាន់ណា | ប្រធានការិយាល័យ នីតិកម្មកសិកម្ម | សមាជិក |

| | | |
|---|---|---|
| ១១-លោកស្រី មិុល ចន្ទ័ទេវី | ប្រធានការិយល័យក្សេត្រសាស្ត្រនិងផលិតភាពកសិកម្ម | សមាជិក |
| ១២-លោកស្រី គយ សុខុម | ប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម | សមាជិក |
| ១៣-លោកស្រី ហង់ ណាវី | ប្រធានការិយាល័យកសិឧស្សាហកម្ម | សមាជិក |
| ១៤-លោក អ៊ុច សេរត្នី | ប្រធានស្តីទី ការិយល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម | សមាជិក |
| ១៥-លោក ប៉ុន ភារ៉ា | អនុប្រធានការិយាល័យកៅស៊ូ | សមាជិក |
| ១៦-លោក វ៉ែន វត្នី | អនុប្រធានការិយាល័យផែនការគណនេយ្យ | សមាជិក |
| ១៧-លោក ស៊ុន ពិល | មន្ត្រីការិយាល័យផែនការ គណនេយ្យ | សមាជិក |

**ប្រការ** ២ ក្រុមការងាររៀបចំកសាងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍនិវិស័យកសិកម្ម ឆ្នាំ ២០១៩-២០២៣ របស់មន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្តតាកែវមានភារកិច្ចដូចខាងក្រោម៖

ពិនិត្យមើលគោលការណ៍ណែនាំនិងប្រមូលព័តមានធាតុចូល ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍនិវិស័យកសិកម្មរាជធានី/ខេត្តសម្រាប់ឆ្នាំ២០១៩-២០២៣ ដើម្បីរៀបចំកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍនិវិស័យកសិកម្មឆ្នាំ ២០១៩-២០២៣ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្តតាកែវ ។

រៀបចំ និង ដឹកនាំប្រជុំជាមួយអ្នកពាក់ពន្ធ័នានារួមមានការិយាល័យពាក់ពន្ធ័នៃមន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទខេត្តតាកែវ អង្គការដៃគូ វិស័យឯកជន សហគមន៍កសិកម្ម ដើម្បីប្រមូលព័តមានសម្រាប់កសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០១៩-២០២៣

រៀបចំឯកសារយុទ្ធសាស្ត្រអភិវឌ្ឍនិវិស័យកសិកម្មឆ្នាំ២០១៩-២០២៣ ដើម្បីដាក់ជូនអ្នកពាក់ពន្ធ័ផ្តល់យោបល់បន្ថែម មុននឹងដាក់ឯកសារជាផ្លូវការជូនប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពិនិត្យ សម្រេច ចុងក្រោយដើម្បីផ្ញើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងអ្នកពាក់ព័ន្ធ នានា។

រៀបចំនិងធ្វើសិក្ខាសាលាផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍនិវិស័យកសិកម្មឆ្នាំ២០១៩-២០២៣ របស់មន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្ត ដល់អ្នកពាក់ពន្ធ័នានា នៅថ្នាក់ខេត្ត។

រៀបចំនិងដឹកនាមប្រជុំបន្ទាន់ ដើម្បីធ្វើបច្ចុប្បន្នភាពកែសម្រួលផែនការយុទ្ធសាស្ត្រអភិវឌ្ឍនិវិស័យកសិកម្ម ឆ្នាំ២០១៩-២០២៣ ក្នុងករណីចាំបាច់របស់ថ្នាក់ដឹកនាំ។

**ប្រការ** ៣ ខណ្ឌរដ្ឋបាលព្រៃឈើ ខណ្ឌរដ្ឋបាលជលផល និង ការិយាល័យជំនាញទាំងអស់របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ មានភារៈកិច្ចអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព និង ការទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្ត**

ញ៉ឹប - ស្រ៊ន

ចម្លងជូន
-ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ
-រដ្ឋបាលសាលាខេត្តតាកែវ
-រដ្ឋបាលក្រុង/ស្រុក
-ដើម្បីជូនជ្រាប-
-សាមីខ្លួន -ដើម្បីអនុវត្ត-
-ឯកសារ - កាលប្បវត្តិ

## ឧបសម្ព័ន្ធ៣៖ អង្គការលេខថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត

